*<u>សេចក្តីព្រាង</u>*

*ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២១*

**រាជរដ្ឋាភិបាលកម្ពុជា**

# គោលនយោបាយ
# រដ្ឋាភិបាលឌីជីថលកម្ពុជា
# ២០២១-២០៣៥



# “កសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់
# គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ
# តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ”

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ

ថ្ងៃទី ខែ ឆ្នាំ២០២១

រៀបចំដោយ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# បុព្វកថា

# អារម្ភកថា

# មាតិកា


**បុព្វកថា** ....... i
**អារម្ភកថា** ....... ii
**ខ្លឹមសារសង្ខេប** ....... v
**បញ្ជីពាក្យកាត់** ....... viii
**១- សេចក្តីផ្តើម** ....... ១
**២- ទស្សនទានរដ្ឋាភិបាលឌីជីថល** ....... ២
២.១- និយមន័យ ....... ២
២.២- គោលការណ៍អនុវត្ត ....... ៣
២.៣- បច្ច័យវិជ្ជមាននៃរដ្ឋាភិបាលឌីជីថល ....... ៤
២.៤- បទពិសោធនិងឧត្តមានុវត្តន៍រដ្ឋាភិបាលឌីជីថល ....... ៥
**៣- ស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា** ....... ៨
៣.១- ដំណើរវិវត្ត ....... ៨
៣.២- កត្តាអំណោយផលនិងប្រឈម ....... ១២
**៤- ចក្ខុវិស័យ** ....... ១៩
**៥- គោលបំណង** ....... ១៩
**៦- គោលដៅនិងយុទ្ធសាស្ត្រ** ....... ១៩
**៧- សកម្មភាពអាទិភាព** ....... ២១
៧.១- យុទ្ធសាស្ត្រ៖ ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល ....... ២១
៧.២- យុទ្ធសាស្ត្រ៖ ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ ២២
៧.៣- យុទ្ធសាស្ត្រ៖ ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល ....... ២៣
៧.៤- យុទ្ធសាស្ត្រ៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មានភស្តុភារកម្មប្រៃសណីយ៍ ....... ២៣
៧.៥- យុទ្ធសាស្ត្រ៖ ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល ....... ២៣
៧.៦- យុទ្ធសាស្ត្រ៖ ការធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាលនិងសេវាសាធារណៈ ....... ២៧
៧.៧- យុទ្ធសាស្ត្រ៖ ការកសាងមូលធនមនុស្សឌីជីថល ....... ៣០
៧.៨- យុទ្ធសាស្ត្រ៖ ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល ....... ៣១
៧.៩- យុទ្ធសាស្ត្រ៖ ការរៀបចំកិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ....... ៣១
៧.១០- យុទ្ធសាស្ត្រ៖ ការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល ....... ៣២
**៨- យន្តការដឹកនាំ សម្របសម្រួល អនុវត្ត តាមដាននិងវាយតម្លៃ** ....... ៣៣

៨.១- យន្តការដឹកនាំ សម្របសម្រួល និងអនុវត្ត ...... ៣៣
៨.២- យន្តការតាមដាននិងវាយតម្លៃ...... ៣៧
**៩- ការបញ្ចៀស កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់ និងការគ្រប់គ្រងហានិភ័យ** ...... ៣៩
៩.១- ការបញ្ចៀស កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់ពាក់ព័ន្ធនឹងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម...... ៣៩
៩.២- ហានិភ័យពាក់ព័ន្ធនឹងការសម្របសម្រួលស្ថាប័ន ...... ៣៩
៩.៣- ហានិភ័យពាក់ព័ន្ធនឹងការផ្លាស់ប្តូររបៀបរបបការងារ ...... ៣៩
៩.៤- ហានិភ័យពាក់ព័ន្ធនឹងមូលធនមនុស្សនិងហិរញ្ញវត្ថុ...... ៤០
៩.៥- ហានិភ័យពាក់ព័ន្ធនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា...... ៤០
៩.៦- ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថលនិងការគ្រប់គ្រងក្នុងពេលប្រធានសក្តិ...... ៤០
**១០- សេចក្តីសន្និដ្ឋាន** ...... ៤២
**ឧបសម្ព័ន្ធ១ តារាងសកម្មភាពអាទិភាពនៃក្របខណ្ឌយុទ្ធសាស្ត្រដែលទទួលបន្ទុកដោយគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល**...... ៤៣
**ឧបសម្ព័ន្ធ២ របាយការណ៍សិក្សាអំពីស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា**...... ៦០
**ឧបសម្ព័ន្ធ៣ សទ្ទានុក្រម**...... ៩០

## ខ្លឹមសារសង្ខេប

តាមការចង្អុលបង្ហាញក្នុង **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** ជាមួយចក្ខុវិស័យកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថលរស់រវើក *ការកសាងរដ្ឋាភិបាលឌីជីថល* គឺជាសសរស្តម្ភចាំបាច់ដែលត្រូវចាប់ផ្តើមធ្វើបរិវត្តកម្មឌីជីថលជាមុន ដើម្បីជំរុញឱ្យធុរជននិងប្រជាពលរដ្ឋចាប់យកវិស័យឌីជីថល។

បរិវត្តកម្មឌីជីថលរដ្ឋាភិបាលមានការរៀបចំស្របទៅតាម*និន្នាការពិភពលោក* ដោយផ្តោតលើការពង្រឹងសេវាសាធារណៈតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាស្នូល។ កិច្ចការនេះគឺជារបៀបវារៈដ៏សំខាន់ក្នុងការជំរុញកំណែទម្រង់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតបរិយាកាសប្រកបដោយបរិយាបន្ន សំដៅជំរុញការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

បច្ចុប្បន្ន ការវិវត្តនៃរដ្ឋាភិបាលឌីជីថលកម្ពុជាស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ ដោយហេតុថា ឌីជីថលនីយកម្មតាមក្រសួងស្ថាប័នមិនទាន់បានធ្វើសមាហរណកម្មជាមួយគ្នា ភាគច្រើនផ្តោតសំខាន់លើការអភិវឌ្ឍកម្មវិធីសម្រាប់សម្រួលដល់ការងារ ដោយពុំមានយុទ្ធសាស្ត្រសម្រាប់បរិវត្តកម្មឌីជីថលរយៈពេលវែង និងការគិតគូរជាសំខាន់ពីប្រសិទ្ធភាពនិងប្រសិទ្ធផលដែលអាចកើតចេញពីទិន្នន័យប្រមូលផ្តុំបាន។

ដោយនិន្នាការបរិវត្តកម្មឌីជីថលក្នុងពិភពលោកនៅតែបន្តល្បឿនទៅមុខយ៉ាងឆាប់រហ័ស ជាពិសេស ការរីកចម្រើន និងនវានុវត្តន៍នៃបច្ចេកវិទ្យាឌីជីថលនិងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ កម្ពុជាត្រូវរៀបចំខ្លួនជាស្រេចសម្រាប់ បរិវត្តកម្មឌីជីថលរដ្ឋាភិបាល *ឱ្យទាន់ពេលវេលា* ដើម្បីទាញយកប្រយោជន៍ឱ្យអស់លទ្ធភាពពីបច្ចេកវិទ្យាឌីជីថល។ ក្នុងដំណាក់កាលនេះ កត្តាអំណោយផលសំខាន់បំផុត គឺ*ឆន្ទៈនយោបាយនិងការគាំទ្រខ្ពស់* ក្នុងការជំរុញការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ ការគាំទ្រពីថ្នាក់ដឹកនាំកំពូលនឹងធ្វើឱ្យមានការសម្របសម្រួលជាឆ្លុងមួយលើផ្នែកនយោបាយ កិច្ចសហការរវាងក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការប្រើប្រាស់ថវិកាមានប្រសិទ្ធភាពនិងចំគោលដៅ ការចូលរួមពីវិស័យឯកជន លំហូរនៃការវិនិយោគផ្ទាល់ពីបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ទន្ទឹមនឹងនេះ កម្ពុជាក៏មានកត្តាអំណោយផលចំបងដទៃទៀតដូចជា មានយុវជនច្រើនដែលមានការអប់រំនិងងាយទទួលយកបច្ចេកវិទ្យាឌីជីថលយ៉ាងឆាប់រហ័ស មន្ត្រីមានបទពិសោធនិងជំនាញក្នុងការរៀបចំរដ្ឋាភិបាលឌីជីថល ការបង្កើតបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជាសម្រាប់ជំរុញការកសាងសមត្ថភាពឌីជីថល កំណើន*អ្នកប្រើប្រាស់អ៊ីនធឺណិតនិងអាជីវកម្មប្រើប្រាស់បច្ចេកវិទ្យាឌីជីថល* ព្រមទាំង*ក្រុមហ៊ុនធុរកិច្ចឌីជីថល*។

ទន្ទឹមនឹងកត្តាអំណោយផលខាងលើ ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជា បាននិងកំពុងជួបកត្តាប្រឈមជាច្រើនផងដែរ ដោយយន្តការថ្នាក់ជាតិនិងស្ថាប័នមិនទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់សម្របសម្រួល ដឹកនាំ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងផែនការមេ។ កន្លងមកវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមិនទាន់ត្រូវបានចាត់ទុកជាវិស័យអាទិភាព ការរៀបចំនិងអភិវឌ្ឍរដ្ឋាភិបាលឌីជីថលបានជួបការលំបាកជាបន្តបន្ទាប់។ គោលនយោបាយឬយន្តការនៃការរៀបចំផែនការនិងថវិកាសម្រាប់គាំទ្រគម្រោងឌីជីថលនីយកម្មផ្ទៃក្នុងរដ្ឋាភិបាល ដូចជា មជ្ឈមណ្ឌលទិន្នន័យ ប្រព័ន្ធព័ត៌មានឌីជីថលជាដើម នៅពុំទាន់មានលក្ខណៈជាប្រព័ន្ធរួមនៅឡើយ។ កត្តាប្រឈមមួយទៀត គឺនៅមិនទាន់មានសង្គតិភាពរវាងចំណាយវិនិយោគលើប្រព័ន្ធព័ត៌មានឌីជីថល និងការកើនឡើងនៃសេវាសាធារណៈផ្តល់ដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ចក្ខុវិស័យនៃគោលនយោបាយនេះគឺ *កសាងរដ្ឋាភិបាលឌីជីថលដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋតាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ*។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ឯកសារគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥ ដាក់ចេញនូវយុទ្ធសាស្ត្រចំនួន១០ គឺ *ទីមួយ* ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល ដែលមានសកម្មភាពអាទិភាពចំនួន៦ *ទីពីរ* ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធ

ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ ដែលមានសកម្មភាពអាទិភាពចំនួន១ *ទីបី* ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល ដែលមានសកម្មភាពអាទិភាពចំនួន៣ *ទីបួន* ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានភស្តុភារកម្មប្រៃសណីយ៍ ដែលមានសកម្មភាពអាទិភាពចំនួន១ *ទីប្រាំ* ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល ដែលមានសកម្មភាពអាទិភាពចំនួន២៦ *ទីប្រាំមួយ* ការធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាលនិងសេវាសាធារណៈ ដែលមានសកម្មភាពអាទិភាពចំនួន២៩ *ទីប្រាំពីរ* ការកសាងមូលធនមនុស្សឌីជីថល ដែលមានសកម្មភាពអាទិភាពចំនួន១២ *ទីប្រាំបី* ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល ដែលមានសកម្មភាពអាទិភាពចំនួន៣ *ទីប្រាំបួន* ការរៀបចំកិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ដែលមានសកម្មភាពអាទិភាពចំនួន៣ និង *ទីដប់* ការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល ដែលមានសកម្មភាពអាទិភាពចំនួន២ ។

ដើម្បីអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាពខាងលើ *គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល*ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវបានរៀបចំឡើង និងមានតួនាទីដឹកនាំនិងសម្របសម្រួលក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើបរិវត្តកម្មឌីជីថល ក្នុងនោះ មានការរៀបចំសេចក្តីណែនាំ ផែនការសកម្មភាព ការជំរុញការអនុវត្ត ការពិនិត្យ ការតាមដាន និងការវាយតម្លៃ ដើម្បីធានានូវប្រសិទ្ធភាព អន្តរប្រតិបត្តិការ និងសុវត្ថិភាពនៃប្រព័ន្ធព័ត៌មានឌីជីថលរបស់រាជរដ្ឋាភិបាលទាំងមូល។ ក្រោមការសម្របសម្រួលពីគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានតួនាទីស្នូលក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលដូចជា *កសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលរួម គ្រប់គ្រងថ្នាលបច្ចេកវិទ្យារួម កំណត់ស្តង់ដាបច្ចេកទេស* សុសវែរ ហាដវែរ និងសន្តិសុខឌីជីថល និង*រៀបចំកម្មវិធីបណ្តុះបណ្តាល*ជំនាញឌីជីថល។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវបង្កើត*អង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថល* ដែលមានតួនាទីជំរុញបរិវត្តកម្មឌីជីថលនៃស្ថាប័នរបស់ខ្លួន ដើម្បីចូលរួមអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល។

ដើម្បីធានាបាននូវតុល្យភាពរវាងការចំណាយនិងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល រាជរដ្ឋាភិបាលសម្រេចផ្តល់នូវកញ្ចប់ថវិកាមួយ ស្របទៅនឹងបច្ច័យវិជ្ជមាននៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល ដូចឧត្តមានុវត្តន៍នៅតាមបណ្តាប្រទេសមួយចំនួនដែលមានការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្រិតខ្ពស់។ ក្នុងន័យខាងលើនេះ រាជរដ្ឋាភិបាលត្រូវធ្វើវិភាជន៍*ថវិកាអាទិភាពប្រចាំឆ្នាំ* ពីចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ ដែលបានមកពីវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងត្រូវការជ្រើសរើសបន្ថែម*មន្ត្រីជំនាញបច្ចេកវិទ្យាឌីជីថល* ក្នុងចំនួនសមស្របមួយ ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់ក្នុងរយៈពេលអភិវឌ្ឍ ៣ឆ្នាំដំបូង ដើម្បីអនុវត្តសកម្មភាពអាទិភាពនៅក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥។ ក្រៅពីថវិកាខាងលើ ក៏អាចមានថវិកាបន្ថែមដែលមានប្រភពពីវិស័យឯកជន ជំនួយឥតសំណង និង/ឬហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលមានភារកិច្ចរៀបចំយន្តការតាមដាន និងវាយតម្លៃ ការអនុវត្តសកម្មភាពអាទិភាព ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ទុនវិនិយោគលើការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ ជាមួយគ្នានេះ យន្តការបញ្ចៀស កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់ និងការគ្រប់គ្រងហានិភ័យ នឹងត្រូវរៀបចំឡើង សំដៅដោះស្រាយហានិភ័យផ្សេងៗដែលអាចកើតមានឡើង ពាក់ព័ន្ធនឹងទិដ្ឋភាពសេដ្ឋកិច្ចនិងសង្គម ការសម្របសម្រួលក្រសួងស្ថាប័ន ការផ្លាស់ប្តូររបៀបរបបការងារ មូលធនមនុស្សនិងហិរញ្ញវត្ថុ ការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា សន្តិសុខឌីជីថលនិងប្រធានសក្តិ។

ជារួម ការជ្រើសរើសសកម្មភាពអាទិភាពក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល បានបង្ហាញនូវភាពប្រទាក់ក្រឡាគ្នាជួយបំពេញគ្នាទៅវិញទៅមក ស៊ីជម្រៅ និងស្របតាមយុទ្ធសាស្ត្រច្បាស់លាស់ ទៅតាមគោលបំណង និងគោលដៅជាក់លាក់ឆ្ពោះទៅរកការធ្វើបរិវត្តកម្មឌីជីថលពេញលេញ ដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់សម្រាប់ឆ្នាំ២០៣៥។

បន្ថែមលើនេះ ការអនុវត្តសកម្មភាពអាទិភាពទាំងនោះនឹងធ្វើឡើងទៅតាមផែនការមេជាមួយនឹង ផែនទីបង្ហាញផ្លូវច្បាស់លាស់ក្នុងឆន្ទៈនយោបាយដ៏មោះមុត សំដៅសម្រេចឱ្យបានជោគជ័យ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ក្នុងស្មារតីប្រាកដប្រជា រាល់សកម្មភាពអាទិភាពនីមួយៗនឹងត្រូវភ្ជាប់ជាមួយនូវសូចនាករវាស់វែងព្រមជាមួយក្រសួងស្ថាប័នទទួលបន្ទុកអនុវត្ត។ គួបផ្សំនឹងវិធានការដោះស្រាយទុកជាមុននូវផលប៉ះពាល់អវិជ្ជមានផ្សេងៗ ព្រមទាំងការរៀបចំយន្តការគ្រប់គ្រងហានិភ័យទាំងឡាយដែលអាចកើតមានឡើងក្នុងដំណើរការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥ គឺជាឯកសារមួយដែលមានគុណភាពពេញលេញ និងគ្រប់គ្រាន់សម្រាប់យកជាមគ្គុទ្ទេសក៍ក្នុងការអនុវត្តដើម្បីចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ដែលប្រជាពលរដ្ឋទទួលបាននូវគុណភាពជីវិតខ្ពស់ ទំនុកចិត្ត និងការជឿជាក់លើរាជរដ្ឋាភិបាល។

# បញ្ជីពាក្យកាត់

| | |
|---|---|
| 4G | ប្រព័ន្ធទូរសព្ទចល័តជំនាន់ទី៤ ( $4^{th}$ Mobile Generation ) |
| 5G | ប្រព័ន្ធទូរសព្ទចល័តជំនាន់ទី៥ ( $5^{th}$ Mobile Generation ) |
| AI | បញ្ញាសិប្បនិម្មិត ( Artificial Intelligence ) |
| AAE-1 | ខ្សែកាបក្រោមបាតសមុទ្រអាស៊ី-អាហ្វ្រិក-អឺរ៉ុប ( Asia-Africa-Europe 1 ) |
| CA | វិញ្ញាតធរហត្ថលេខាឌីជីថល ( Certificate Authority ) |
| CamDX | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ( Cambodia Data Exchange ) |
| EGDI | សន្ទស្សន៍អភិវឌ្ឍរដ្ឋាភិបាលឌីជីថល ( E-Government Development Index ) |
| e-Government | រដ្ឋាភិបាលអេឡិចត្រូនិក ( Electronic Government ) |
| G2G | ការផ្តល់សេវាពីរដ្ឋាភិបាលទៅរដ្ឋាភិបាល ( Government to Government ) |
| G4C | ការផ្តល់សេវាសាធារណៈពីរដ្ឋាភិបាលដើម្បីប្រជាពលរដ្ឋ ( Government for Citizen ) |
| G2B | ការផ្តល់សេវាសាធារណៈពីរដ្ឋាភិបាលទៅធុរកិច្ច ( Government to Business ) |
| GAIS | ប្រព័ន្ធព័ត៌មានរដ្ឋបាលរដ្ឋាភិបាល ( Government Administrative Information System ) |
| GDP | ផលិតផលក្នុងស្រុកសរុប ( Gross Domestic Products ) |
| MCT | ខ្សែកាបក្រោមបាតសមុទ្រម៉ាឡេស៊ី កម្ពុជា ថៃ ( Malaysia Cambodia Thailand ) |
| NiDA | អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ( National Information Communication Technology Development Authority ) |
| OECD | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច ( Organisation for Economic Co-operation and Development ) |
| PAIS | ប្រព័ន្ធព័ត៌មានរដ្ឋបាលខេត្ត ( Provincial Administrative Information System ) |
| PKI | ហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ ( Public Key Infrastructure ) |
| RCEP | ភាពជាដៃគូគ្រប់ជ្រុងជ្រោយតំបន់ ( Regional Comprehensive Economic Partnership ) |
| Root CA | វិញ្ញាតធរហត្ថលេខាឌីជីថលមេ ( Root Certificate Authority ) |
| UN-DESA | នាយកដ្ឋានសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ United Nations Department of Economic and Social Affairs |

## ១- សេចក្តីផ្តើម

ស្របតាមនិន្នាការពិភពលោក ការកសាងរដ្ឋាភិបាលឌីជីថលគឺជារបៀបវារៈដ៏សំខាន់ក្នុងការជំរុញកំណែទម្រង់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតបរិយាកាសប្រកបដោយបរិយាបន្ន សំដៅជំរុញការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ និន្នាការនៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល មានការវិវត្តប្រសើរឡើងជាលំដាប់នៅគ្រប់តំបន់ក្នុងសកលលោក។ លទ្ធផលនៃការវាយតម្លៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលដោយ នាយកដ្ឋានសេដ្ឋកិច្ចនិងសង្គមនៃអង្គការសហប្រជាជាតិ(UN-DESA) បានបង្ហាញថា តម្លៃមធ្យមនៃសន្ទស្សន៍អភិវឌ្ឍរដ្ឋាភិបាលឌីជីថលបានកើនឡើងពី០,៥៥ក្នុងឆ្នាំ២០១៨ ដល់០,៦០ក្នុងឆ្នាំ២០២០ នៅប្រទេសចំនួន១២៦ ក្នុងចំណោម១៩៣ប្រទេស។ ក្នុងបរិបទតំបន់ ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ត្រូវបានកំណត់ជាគោលដៅអាទិភាពសំខាន់មួយក្នុងផែនការមេឌីជីថលអាស៊ានឆ្នាំ២០២៥ ជាមូលដ្ឋានក្នុងការផ្តល់សេវាសាធារណៈឌីជីថលដែលមានគុណភាពខ្ពស់ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសក្នុងតំបន់។

តាមការចង្អុលបង្ហាញ ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ការកសាងរដ្ឋាភិបាលឌីជីថល ជាសសរស្តម្ភចាំបាច់ និងត្រូវបោះជំហានមុន ដើម្បីជំរុញល្បឿនក្នុងការកសាងពលរដ្ឋនិងធុរកិច្ចឌីជីថល និងជានាភាពជោគជ័យខ្ពស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលទាំងមូល។ រដ្ឋាភិបាលឌីជីថលគឺជាប្រព័ន្ធថ្មីមួយក្នុងការរៀបចំ គ្រប់គ្រង និងការផ្តល់សេវាសាធារណៈ តាមរយៈការធ្វើបរិវត្តកម្មឌីជីថលនៃការគ្រប់គ្រងនិងរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន ដែលនាំឱ្យប្រជាពលរដ្ឋនិងធុរកិច្ចចាប់យកនិងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីបង្កើននូវប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព ការបើកចំហ ក៏ដូចជាការជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។

នាពេលបច្ចុប្បន្ន ប្រព័ន្ធព័ត៌មានឌីជីថលនិងការគ្រប់គ្រងទិន្នន័យត្រូវបានអភិវឌ្ឍនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនានា មានលក្ខណៈដាច់ដោយឡែកពីគ្នា ឬច្រំដែល ទោះស្ថិតក្រោមស្ថាប័នតែមួយ ឬរវាងស្ថាប័នផ្សេងគ្នា។ បើទោះបីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានមជ្ឈមណ្ឌលទិន្នន័យជាតិ ក៏បញ្ហាប្រឈមខាងលើនេះហាក់មិនទាន់កាត់បន្ថយបាននៅឡើយ។ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានកង្វះខាតនូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ភាពជាម្ចាស់លើប្រព័ន្ធដែលបានស្រាប់ ការការពារសន្តិសុខឌីជីថល និងមូលធនមនុស្សលើបច្ចេកវិទ្យាឌីជីថល សម្រាប់អភិវឌ្ឍ និងគាំទ្រដល់ប្រព័ន្ធព័ត៌មានឌីជីថលនិងការគ្រប់គ្រងទិន្នន័យ ឱ្យបានពេញលេញ និងមានសុវត្ថិភាព។ ការអភិវឌ្ឍប្រព័ន្ធនានាពុំមានការធ្វើផែនការ និងពុំមានការផ្តល់ហិរញ្ញប្បទានជាលក្ខណៈប្រព័ន្ធដែលធ្វើឱ្យការអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថលនិងការគ្រប់គ្រងទិន្នន័យមួយចំនួនមានភាពយឺតយ៉ាវ ឬត្រូវបានផ្អាកក្រោយពីដំណើរការមួយរយៈ។

ដូចនេះ ការរៀបចំគោលនយោបាយរដ្ឋាភិបាលឌីជីថល គឺជាការចាំបាច់ និងបន្ទាន់ ក្នុងការដោះស្រាយនូវបញ្ហាប្រព័ន្ធព័ត៌មានឌីជីថល ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ អភិបាលកិច្ចទិន្នន័យ និងមូលធនមនុស្ស ដើម្បីជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមឱ្យមានភាពស៊ីសង្វាក់គ្នា ក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ២០២១-២០៣៥ ប្រកបដោយជោគជ័យ។ រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥ ដើម្បីបំពេញលើឯកសារក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដែលជាផែនទីមេចង្អុលបង្ហាញ ដោយមិនរាប់បញ្ចូលសកម្មភាពអាទិភាពមួយចំនួនដែលបែងចែកទៅគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល និងគណៈកម្មាធិការសន្តិសុខឌីជីថល។ ឯកសារនេះរៀបចំឡើងដោយចែកចេញ ជា១១ផ្នែកៈ ផ្នែកទី១ពីសេចក្តីផ្តើម ផ្នែកទី២ពីទស្សនាទានរដ្ឋាភិបាលឌីជីថល ផ្នែកទី៣ពីស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា ផ្នែកទី៤ពីចក្ខុវិស័យ ផ្នែកទី៥ពីគោលបំណង ផ្នែកទី៦ពីគោលដៅនិងយុទ្ធសាស្ត្រ ផ្នែកទី៧ពីយុទ្ធសាស្ត្រនិងសកម្មភាពអាទិភាព ផ្នែក៨ពីយន្តការដឹកនាំ សម្របសម្រួល អនុវត្ត តាមដាននិងវាយតម្លៃ ផ្នែកទី៩ពីការបញ្ចៀសកាត់បន្ថយ និងដោះស្រាយផលប៉ះពាល់ និងការគ្រប់គ្រងហានិភ័យ និងផ្នែកទី១០ពីសេចក្តីសន្និដ្ឋាន។

# ២- ទស្សនទានរដ្ឋាភិបាលឌីជីថល

## ២.១- និយមន័យ

នៅក្នុងយុគសម័យឌីជីថល ការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យាឌីជីថលដែលមានជាអាទិ៍ កុំព្យូទ័រ អ៊ីនធឺណិត បច្ចេកវិទ្យាចល័ត ឧបករណ៍ឌីជីថលចល័ត និងបច្ចេកវិទ្យាសម្រាប់ការវិភាគទិន្នន័យ បាននិងកំពុង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ អត្ថិភាពនៃយុគសម័យថ្មីនេះបានធ្វើឱ្យមានការផ្លាស់ប្ដូររបៀបរស់នៅប្រចាំថ្ងៃ ព្រមទាំងបានជំរុញឱ្យរដ្ឋាភិបាលនានាធ្វើការផ្លាស់ប្ដូរការបម្រើសេវា ការប្រាស្រ័យទាក់ទងជាមួយនឹងប្រជាពលរដ្ឋនិងផ្នែកធុរកិច្ច ពីរបៀបតាមបែបប្រពៃណីមកបែបទំនើបតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលហៅថា *រដ្ឋាភិបាលឌីជីថល* ។ តាមនិយមន័យកំណត់ដោយអង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច(OECD) រដ្ឋាភិបាលឌីជីថល គឺជាដំណើរការនៃការធ្វើទំនើបកម្ម និងសមាហរណកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាលនិងសេវាសាធារណៈ ក្នុងគោលបំណងបង្កើតនិងធ្វើឱ្យប្រសើរឡើងនូវ *គុណតម្លៃសាធារណៈ*(Public Value) សំដៅលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ និងផ្ដល់អត្ថប្រយោជន៍សម្រាប់សង្គម ដូចជា *ទីមួយ* ការផ្ដល់សេវាដែលបំពេញសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ *ទីពីរ* ការឆ្លើយតបទៅនឹងការរំពឹងទុករបស់ប្រជាពលរដ្ឋដោយយុត្តិធម៌ សមធម៌ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្ន *ទីបី* ស្ថាប័នសាធារណៈដែលមានសណ្ដាប់ធ្នាប់ល្អនិងផលិតភាពខ្ពស់ដែលឆ្លុះបញ្ចាំងពីបំណងប្រាថ្នានិងតម្រូវការរបស់ប្រជាពលរដ្ឋ *ទីបួន* ការបែងចែកធនធានប្រកបដោយសមធម៌និងប្រសិទ្ធភាព *ទីប្រាំ* ការប្រើប្រាស់ធនធានដោយស្របច្បាប់ដើម្បីសម្រេចគោលបំណងសាធារណៈ និង *ទីប្រាំមួយ* នវានុវត្តន៍និងលទ្ធភាពសម្របខ្លួនទៅនឹងតម្រូវការដែលតែងតែផ្លាស់ប្ដូរ។

រដ្ឋាភិបាលឌីជីថលអាស្រ័យលើការទ្រទ្រង់ដ៏រឹងមាំពីប្រព័ន្ធអេកូឡូស៊ីមួយ ដែលតម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធ ដូចជាក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ វិស័យធុរកិច្ច អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ និងប្រជាពលរដ្ឋ ដែលជួយគាំទ្រដល់ការផលិតនិងការទទួលបានទិន្នន័យ សេវាកម្ម និងមាតិកា តាមរយៈអន្តរសកម្មជាមួយរដ្ឋាភិបាល។ ការកសាងរដ្ឋាភិបាលឌីជីថលត្រូវឈរលើប្រព័ន្ធអភិបាលកិច្ចឯកភាពរួមមួយ (Whole-of-government) ដែលគ្រប់ក្រសួងស្ថាប័នទាំងអស់ជាផ្នែកមួយនៃប្រព័ន្ធនេះ។ ក្រសួងស្ថាប័ននីមួយៗអាចរៀបចំនិងអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថលសម្រាប់ផ្ដល់សេវាផ្ទៃក្នុងនិងសេវាសាធារណៈរបស់ខ្លួន ហើយប្រព័ន្ធទាំងនេះត្រូវធ្វើការទំនាក់ទំនងគ្នា ចែករំលែកទិន្នន័យ និងបំពេញមុខងារជាប្រព័ន្ធរដ្ឋាភិបាលឌីជីថលរួម។ តាមការកំណត់របស់ក្រុមហ៊ុនហ្គាតណឺ(Gartner) ដែលជាក្រុមហ៊ុនល្បីល្បាញពិភពលោក ផ្ដោតលើការស្រាវជ្រាវនិងប្រឹក្សាយោបល់លើវិស័យឌីជីថល រដ្ឋាភិបាលឌីជីថលត្រូវបានបែងចែកជា៥កម្រិត ៖

- **កម្រិតទី១** : *រដ្ឋាភិបាលអេឡិចត្រូនិក*(e-Government) ជាដំណាក់កាលដំបូងនៃរដ្ឋាភិបាលឌីជីថល។ ក្នុងដំណាក់កាលនេះ ការអភិវឌ្ឍនិងការប្រើប្រាស់ប្រព័ន្ធឌីជីថលផ្ដោតលើការផ្លាស់ប្ដូរការផ្ដល់សេវាទៅតាមប្រព័ន្ធអនឡាញក្នុងន័យផ្ដល់ភាពងាយស្រួលដល់ការប្រើប្រាស់និងសន្សំសំចៃថវិកា។ ប្រព័ន្ធឌីជីថល និងការផ្ទុកទិន្នន័យនៅក្នុងដំណាក់កាលដំបូងមានសភាពដាច់ដោយឡែកពីគ្នា។

- **កម្រិតទី២** : *រដ្ឋាភិបាលបើកចំហ* (Open Government) ជាដំណាក់កាលបើកចំហ ដែលប្រព័ន្ធព័ត៌មានឌីជីថលត្រូវបានបង្កើតឡើង ដើម្បីទទួលមតិយោបល់និងមានអន្តរសកម្មជាមួយអ្នកទទួលសេវា។ នៅក្នុងកម្រិតទី២ ព័ត៌មានរបស់រដ្ឋាភិបាលត្រូវបានបើកចំហដល់សាធារណជន ដើម្បីធានាតម្លាភាព និងគណនេយ្យភាព។

- **កម្រិតទី៣** : *រដ្ឋាភិបាលផ្ដោតលើទិន្នន័យ* (Data-centric Government) ជាការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ដែលផ្ដោតលើទិន្នន័យជាទ្រព្យសំខាន់និងចាំបាច់។ ការអភិវឌ្ឍកម្មវិធីលែងជាចំណុចអាទិភាព ផ្ទុយទៅវិញការប្រមូល ប្រើប្រាស់និងវិភាគទិន្នន័យគឺជាយុទ្ធសាស្ត្រសំខាន់របស់រដ្ឋាភិបាល។ ប្រព័ន្ធដំណើរការរបស់អង្គភាពក្រោម

ចំណុះរដ្ឋាភិបាលត្រូវបានធ្វើសមាហរណកម្មជាបណ្តើរៗ ហើយការអនុវត្តការងារនឹងដំណើរការលើថ្នាលឌីជីថលរួមមួយរបស់រដ្ឋាភិបាល (Government as a Platform)។

- **កម្រិតទី៤** : *រដ្ឋាភិបាលបរិវត្តកម្មពេញលេញ* (Fully Transformed Government) ជាដំណាក់កាលដែលក្រសួងស្ថាប័នធ្វើបរិវត្តកម្មឌីជីថលពេញលេញ ដោយប្រព័ន្ធព័ត៌មានទាំងអស់ត្រូវបានធ្វើសមាហរណកម្មជាប្រព័ន្ធរួមមួយ ហើយការប្រើប្រាស់ ការគ្រប់គ្រង និងការការពារទិន្នន័យ ព្រមទាំងការផ្តល់សេវា មានលក្ខណៈល្អប្រសើរ។

- **កម្រិតទី៥** : *រដ្ឋាភិបាលឆ្លាត* (Smart Government) ជាដំណាក់កាលដែលការប្រមូលនិងវិភាគទិន្នន័យកើតឡើងដោយស្វ័យប្រវត្តិ សម្រាប់ជំនួយដល់ការសម្រេចចិត្ត និងការឆ្លើយតបចំពោះបញ្ហា។ នវានុវត្តន៍នៃសេវាកម្មដោយប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ មានជាអាទិ៍ បញ្ញាសិប្បនិម្មិត អ៊ីនធឺណិតនៃវត្ថុ ទិន្នន័យធំ ប្លុកឆេន ក្លោដ អាចកើតមានឡើងពេញលេញនៅក្នុងដំណាក់កាលនេះ។

**រូបភាពទី១ : កម្រិតនៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល**

រដ្ឋាភិបាលអេឡិចត្រូនិក (e-Government) → រដ្ឋាភិបាលបើកចំហ (Open Government) → រដ្ឋាភិបាលផ្តោតលើទិន្នន័យ (Data-centric Government) → រដ្ឋាភិបាលបរិវត្តកម្មពេញលេញ (Fully Transformed Government) → រដ្ឋាភិបាលឆ្លាត (Smart Government)

## ២.២- គោលការណ៍អនុវត្ត

តាមបទពិសោធបណ្តាប្រទេសមួយចំនួននៅលើពិភពលោក ដើម្បីកសាងរដ្ឋាភិបាលឌីជីថលមួយដែលមានមុខងារពេញលេញប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ត្រូវឈរលើគោលការណ៍អនុវត្តជាមូលដ្ឋាន ចំនួន៣៖

**(១) គោលការណ៍តែមួយលើក** (The Once-Only Principle)

គោលការណ៍តែមួយលើក គឺជាគោលការណ៍អភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថលដែលតម្រូវឱ្យក្រសួងស្ថាប័ន នីតិបុគ្គល និងប្រជាពលរដ្ឋ *ផ្តល់ទិន្នន័យតែមួយលើក* ដល់អាជ្ញាធរមានសមត្ថកិច្ច ដោយមិនស្នើសុំ ឬតម្រូវឱ្យផ្តល់ទិន្នន័យដដែលៗ ម្តងហើយម្តងទៀតច្រើនលើកច្រើនសានោះទេ។ គោលការណ៍នេះជួយកាត់បន្ថយការបញ្ចូលទិន្នន័យដែលគ្មានសង្គតិភាពនឹងគ្នា ហើយកាត់បន្ថយការចំណាយរដ្ឋបាលនិងបន្ទុកការងាររបស់អាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធក្នុងការប្រមូល រក្សាទុក និងប្រើប្រាស់ទិន្នន័យ។

**(២) គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ** (Interoperability as an Ecosystem Principle)

គោលការណ៍នេះធានាថាគ្រប់ប្រព័ន្ធព័ត៌មានឌីជីថលទាំងអស់ក្នុងក្របខណ្ឌរដ្ឋាភិបាលអាចមានប្រតិបត្តិការឯករាជ្យ ហើយក៏អាចធ្វើប្រតិបត្តិការជាមួយគ្នាបានប្រកបដោយសុវត្ថិភាពជាមួយប្រព័ន្ធដទៃទៀត ក្នុងលក្ខណៈជាប្រព័ន្ធអេកូឡូស៊ីមួយ ដើម្បីបំពេញមុខងារឱ្យគ្នាទៅវិញទៅមក ក្នុងការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព។ ក្នុងន័យនេះ ប្រព័ន្ធព័ត៌មានឌីជីថលដែលប្រើប្រាស់ដោយក្រសួងស្ថាប័ន ត្រូវមាន *អន្តរប្រតិបត្តិការ* រវាងគ្នាក្នុងការទាញយកទិន្នន័យទៅវិញទៅមកដើម្បីបំពេញមុខងាររបស់ខ្លួន។ ម្យ៉ាងទៀត គោលការណ៍នេះអនុញ្ញាតឱ្យប្រព័ន្ធព័ត៌មានឌីជីថលរបស់រដ្ឋាភិបាល អាចធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធព័ត៌មានឌីជីថលវិស័យឯកជន ដើម្បីជំរុញនវានុវត្តន៍និងអភិបាលកិច្ចទិន្នន័យ ក្នុងន័យបង្កើនប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្មរបស់ វិស័យឯកជន។

**(៣) គោលការណ៍ចាប់ផ្តើមនិងពង្រីកដើម្បីប្រសិទ្ធផល** (Land and Expand for Efficiency Principle)

គោលការណ៍នេះបើកលទ្ធភាពដល់ក្រសួងស្ថាប័ន ក្នុងការផ្តួចផ្តើមរៀបចំអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថល ដោយ *ចាប់ផ្តើមពីតូចនិងពង្រីកទៅធំដើម្បីប្រសិទ្ធផល* សម្រាប់បំពេញតម្រូវការក្នុងការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈរបស់ខ្លួនឈរលើមូលដ្ឋាននិងក្របខណ្ឌកំណត់មួយ ស្របតាមគោលការណ៍ទាំង២ខាងលើ។ ក្នុងន័យនេះ ការផ្តួចផ្តើមរៀបចំប្រព័ន្ធព័ត៌មានឌីជីថល ត្រូវផ្តោតលើចំណុចអាទិភាពចាំបាច់និងប្រសិទ្ធផលជាគន្លឹះ រួចទើបអាចពង្រីកវិសាលភាពតាមរយៈការប្រើប្រាស់ សមាសធាតុដែលមានស្រាប់(Reusability) ឬពង្រីកដើម្បីចែករំលែកការប្រើប្រាស់ជាមួយប្រព័ន្ធផ្សេងៗទៀតនៃប្រព័ន្ធអេកូឡូស៊ីរដ្ឋាភិបាលឌីជីថល ដោយធានាបាននូវប្រសិទ្ធផលនិងសន្តិសុខនៃប្រព័ន្ធទាំងមូល។

**រូបភាពទី២ : គោលការណ៍អនុវត្តនៃការអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថល**




## ២.៣- បច្ច័យវិជ្ជមាននៃរដ្ឋាភិបាលឌីជីថល

តាមរបាយការណ៍អភិវឌ្ឍពិភពលោកនៃធនាគារពិភពលោកឆ្នាំ២០១៦ កំណើនអ៊ីនធឺណិតល្បឿនលឿនអចល័ត១០% នឹងជំរុញកំណើនផលិតផលក្នុងស្រុកសរុប(GDP) ប្រមាណ១,២១% ក្នុងប្រទេសអភិវឌ្ឍ និងប្រមាណ១,៣៨% ក្នុងប្រទេសកំពុងអភិវឌ្ឍ ជាពិសេសសម្រាប់ករណីប្រទេសចិន កំណើនផលិតផលក្នុងស្រុកសរុបបានកើនឡើងប្រមាណ២,១៤% ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ តាមរយៈការកាត់បន្ថយចំណាយទំនាក់ទំនង និងបង្កើនប្រសិទ្ធភាពក្នុងការធ្វើអាជីវកម្មតាមថ្នាលពាណិជ្ជកម្មអេឡិចត្រូនិក។

ការវាស់វែងបច្ច័យវិជ្ជមាននៃវិស័យឌីជីថលរបស់ស្ថាប័នស្រាវជ្រាវសេដ្ឋកិច្ចអុកស្វដអេកូណូមិច(Oxford Economics) ឆ្នាំ២០១៧ បានបង្ហាញថា ការចាប់យកនិងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បាននាំមកនូវកំណើនផលិតភាពនិងសេដ្ឋកិច្ច មិនត្រឹមតែកំណើនផលិតកម្មប៉ុណ្ណោះទេ។ ក្នុងរយៈពេលបីទសវត្សកន្លងមកនេះ ការវិនិយោគលើបច្ចេកវិទ្យាឌីជីថលចំនួន១ដុល្លារអាមេរិក បាននាំមកនូវកំណើនផលិតផលក្នុងស្រុកសរុបចំនួន២០ដុល្លារអាមេរិក ធៀបនឹងការវិនិយោគលើវិស័យផ្សេងទៀត ដែលនាំមកនូវកំណើនត្រឹមតែ៣ដុល្លារអាមេរិកប៉ុណ្ណោះ ក្នុងរយៈពេលវិនិយោគដូចគ្នា។ លទ្ធផល

នេះបញ្ជាក់ច្បាស់ថាការវិនិយោគជាមធ្យមចំនួន១ដុល្លារអាមេរិកលើវិស័យឌីជីថល នាំមកនូវកំណើន ៦,៧ដងខ្ពស់ជាងការវិនិយោគលើវិស័យផ្សេងទៀត។

ការបង្កើនថវិកាវិនិយោគលើការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលនឹងជំរុញកំណើនផលិតផលក្នុងស្រុកសរុប ដោយផ្អែកលើសូចនាករមួយចំនួនដូចជា *ការបង្កើនផលិតភាពការងារក្នុងវិស័យសាធារណៈ កំណើនទិន្នផលសរុបរបស់វិស័យសាធារណៈ* និង *ប្រសិទ្ធផលរដ្ឋបាលសាធារណៈ*។ តាមការសិក្សារបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលរបស់ប្រទេសជាសមាជិកនៃសហភាពអឺរ៉ុបនីមួយៗបានជួយជំរុញឱ្យមានកំណើនផលិតផលក្នុងស្រុកសរុប ចំនួន២% ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០។ ឯកសារណែនាំពីរដ្ឋាភិបាលឌីជីថលសាធារណរដ្ឋកូរ៉េឆ្នាំ២០២០ បានបង្ហាញថា រដ្ឋាភិបាលឌីជីថលបានចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម គិតជាថវិកាចំនួន១,៣ពាន់លានដុល្លារអាមេរិក ដូចជាតាមរយៈការកាត់បន្ថយការបញ្ចេញកាបូន (Carbon Emission Reductions) ចំនួន២២ពាន់តោន ដែលជាបច្ច័យពីការផ្ដល់សេវាឌីជីថលក្នុងឆ្នាំ២០២០។ ទោះជាយ៉ាងនេះក្ដី ក៏កត្តាជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមពីការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល អាស្រ័យលើស្ថានភាពរបស់បណ្ដាប្រទេសអភិវឌ្ឍនិងប្រទេសកំពុងអភិវឌ្ឍ ដែលក្នុងនោះ ប្រទេសកំពុងអភិវឌ្ឍទទួលបានអត្ថប្រយោជន៍ច្រើនជាងលើការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមពីរដ្ឋាភិបាល ឌីជីថល។

លើសពីនេះទៅទៀត រដ្ឋាភិបាលឌីជីថលនឹងចូលរួមកសាងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការរីកលូតលាស់នៃបច្ចេកវិទ្យាឌីជីថល ដែលនឹងនាំមកនូវបច្ច័យវិជ្ជមានដល់កំណើនសេដ្ឋកិច្ចទាំងមូល ដូចជាតាមរយៈភាពប្រសើរឡើងនៃផលិតភាពរបស់កត្តាផលិតកម្ម ការចែកចាយផលិតផលកាន់តែឆាប់រហ័ស ការប្រកួតប្រជែងផ្នែកធុរកិច្ចកាន់តែស្មើភាព ការកាត់បន្ថយចំណាយនិងពេលវេលា កំណើននៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការលើកកម្ពស់នវានុវត្តន៍ក្នុងវិស័យឯកជន។

នៅក្នុងបរិបទនេះ ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជា គឺជាកិច្ចការអាទិភាពមួយសម្រាប់រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ននិងអនាគត និងជាឃ្នាស់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ និងចូលរួមជំរុញចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០។

## ២.៤- បទពិសោធនិងឧត្តមានុវត្តន៍រដ្ឋាភិបាលឌីជីថល

តាមបទពិសោធនិងឧត្តមានុវត្តន៍នៃបណ្ដាប្រទេសមួយចំនួននៅលើពិភពលោក ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ ត្រូវមានការគិតគូរទៅលើ *ការកសាងគោលនយោបាយនិងក្របខណ្ឌគតិយុត្តរដ្ឋាភិបាលឌីជីថល ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការពង្រឹងសេវារដ្ឋាភិបាលឌីជីថល ការជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល ការលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋនិងឯកជន និងការកំណត់ប្រភពហិរញ្ញប្បទានគាំទ្រ*។

*ការកសាងគោលនយោបាយ និងក្របខណ្ឌគតិយុត្តរដ្ឋាភិបាលឌីជីថល* ជាមូលដ្ឋានមួយដ៏សំខាន់នៃបរិវត្តកម្មរដ្ឋាភិបាលឌីជីថល។ ជាក់ស្ដែង ប្រទេសអេស្តូនី សាធារណរដ្ឋកូរ៉េ និងសិង្ហបុរី ដែលជាប្រទេសមានការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្រិតខ្ពស់ សម្រេចបានការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយជោគជ័យ ផ្អែកលើការរៀបចំគោលនយោបាយនិងក្របខណ្ឌគតិយុត្តរដ្ឋាភិបាលឌីជីថល ការមានឆន្ទៈនយោបាយនិងការគាំទ្រខ្ពស់ ការរៀបចំផែនការទៅតាមការវិវឌ្ឍនៃសេដ្ឋកិច្ចនិងការរីកចម្រើននៃបច្ចេកវិទ្យា ព្រមទាំងការបង្កើតស្ថាប័នសម្របសម្រួលរដ្ឋាភិបាលឌីជីថល។ល។ នៅសាធារណរដ្ឋកូរ៉េ អភិក្រមកសាងរដ្ឋាភិបាលឌីជីថលត្រូវបានរៀបចំពីលើមកក្រោម និងមានលក្ខណៈជាចម្រុះបែបមជ្ឈការដែលស្ថាប័ននីតិបញ្ញត្តិ ក្រសួងស្ថាប័នថ្នាក់ជាតិ និងតុលាការ ត្រូវរៀបចំផែនការមេអភិវឌ្ឍរដ្ឋាភិបាលឌីជីថលក្នុងរយៈពេល៥ឆ្នាំម្ដង ដូចជាការកសាងមជ្ឈមណ្ឌលទិន្នន័យជាតិ និងបែបវិមជ្ឈការដែលរដ្ឋបាលថ្នាក់ក្រោមជាតិ

អាចរៀបចំផែនការសកម្មភាពអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថល ដូចជាការផ្តល់សេវាសាធារណៈក្នុងរដ្ឋបាលរបស់ខ្លួន ហើយធ្វើការតភ្ជាប់ជាមួយនឹងប្រព័ន្ធរដ្ឋាភិបាលឌីជីថលបាន។ ប្រទេសអេស្តូនី បានកសាងរដ្ឋាភិបាលឌីជីថលតាមប្រព័ន្ធវិមជ្ឈការ។ ប្រព័ន្ធបែបនេះជាធម្មតាត្រូវបានប្រឈមមុខដោយបញ្ហានៃការតភ្ជាប់ពីអន្តរប្រព័ន្ធរបស់ក្រសួងស្ថាប័ន។ ប្រព័ន្ធបច្ចេកវិទ្យា X-Road ត្រូវបានបង្កើតឡើងជាហេដ្ឋារចនាសម្ព័ន្ធទិន្នន័យថ្មី សម្រាប់ការតភ្ជាប់បែបវិមជ្ឈការ។

លើសពីនេះ ការរៀបចំនិងកែលម្អ *ហេដ្ឋារចនាសម្ព័ន្ធឌីជីថល* ជាមូលដ្ឋានគ្រឹះចាំបាច់ សម្រាប់គាំទ្រ រដ្ឋាភិបាលឌីជីថល ដែលទាមទារឱ្យមានការគិតគូរគ្រប់ជ្រុងជ្រោយ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធឌីជីថលនេះ ត្រូវផ្តោតទាំងទៅលើគុណភាព និងវិសាលភាព ដែលរួមមានការកសាងហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតល្បឿនលឿន បណ្តាញតភ្ជាប់ មជ្ឈមណ្ឌលទិន្នន័យ ថ្នាលផ្លាស់ប្តូរទិន្នន័យ ហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារទូទាត់សងប្រាក់ថ្នាក់ជាតិសម្រាប់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល ដើម្បីផ្តល់ទំនុកចិត្តនិងភាពជឿជាក់លើរដ្ឋាភិបាលឌីជីថល។

ទន្ទឹមនឹងនេះ ការពង្រឹង*សេវាសាធារណៈ* ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលគឺជាកត្តាជំរុញដ៏សំខាន់ឱ្យសេវានេះខិតទៅជិតប្រជាពលរដ្ឋនិងធុរកិច្ចប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព។ នៅប្រទេសមួយចំនួន សេវាសាធារណៈត្រូវបានផ្តល់តាមរយៈវិបផតថល(Web Portal)ថ្នាក់ជាតិ និងកម្មវិធីទូរសព្ទចល័ត ដែលជាច្រកចេញចូលតែមួយ អាចឱ្យប្រជាពលរដ្ឋនិងធុរកិច្ចទទួលបានព័ត៌មាន ធ្វើអន្តរសកម្មជាមួយរដ្ឋាភិបាលយ៉ាងងាយស្រួល និងធ្វើប្រតិបត្តិការទូទាត់ប្រកបដោយសុវត្ថិភាព នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ ជាឧទាហរណ៍ សាធារណរដ្ឋកូរ៉េ បានដាក់ប្រព័ន្ធលទ្ធកម្មអេឡិចត្រូនិករួម ឱ្យប្រើប្រាស់សម្រាប់កិច្ចការលទ្ធកម្មតាមអនឡាញ ដែលរាប់បញ្ចូលមុខងារដាក់ដេញថ្លៃ ការរៀបចំកិច្ចសន្យា និងការទូទាត់។ លើសពីនេះ ប្រព័ន្ធពន្ធដារជាតិអេឡិចត្រូនិកនិងប្រព័ន្ធពន្ធគយត្រូវបានដាក់ឱ្យប្រើប្រាស់ ដែលមាននីតិវិធីស្វ័យប្រវត្តិក្នុងការធ្វើប្រតិវេទន៍គយ និងការបង្វិលសងវិញនៃពន្ធនិងអាករ ក្នុងគោលបំណងលើកកម្ពស់ការផ្តល់សេវាសាធារណៈពីរដ្ឋាភិបាលទៅធុរកិច្ច(G2B)។ ម្យ៉ាងទៀត ដើម្បីបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល ការទំនាក់ទំនង ការគ្រប់គ្រង និងការផ្តល់សេវាពីរដ្ឋាភិបាលទៅរដ្ឋាភិបាល(G2G) រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េបានបង្កើតថ្នាលសហការ (Collaboration platform)សម្រាប់កិច្ចការរដ្ឋបាល អ៊ីមែល ប្រព័ន្ធគ្រប់គ្រងព័ត៌មានឯកសារអេឡិចត្រូនិក និងប្រព័ន្ធផ្តល់សច្ចានុម័តអេឡិចត្រូនិក។

ជាមួយគ្នានេះ *ការជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល* គឺជាផ្នែកដ៏សំខាន់ដើម្បីគាំទ្រដល់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ ប្រទេសដែលមានការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្រិតខ្ពស់ ផ្តោតលើការពង្រឹងភាពជាអ្នកដឹកនាំនិងសមត្ថភាពជំនាញឌីជីថល ក៏ដូចជាអក្ខរកម្មឌីជីថលរបស់គ្រប់តួអង្គនៃរដ្ឋាភិបាលឌីជីថល ជាពិសេស មន្ត្រីរាជការគ្រប់ស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សិស្ស និស្សិត ទាំងក្នុងកម្រិតចំណេះដឹងទូទៅ កម្រិតជំនាញបច្ចេកវិទ្យាឌីជីថល និងជំនាញដទៃទៀត និងប្រជាពលរដ្ឋ។ បន្ថែមលើនេះការវិនិយោគលើការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថលក៏ត្រូវបានជំរុញ ដើម្បីបណ្តុះបណ្តាលជំនាញគាំទ្រដល់រដ្ឋាភិបាលឌីជីថល និងជំរុញការស្រាវជ្រាវ និងនវានុវត្តន៍នៅតាមគ្រឹះស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ និងវិស័យឯកជន ដូចមានក្នុងបទពិសោធនៅប្រទេសថៃ និងអង់គ្លេសជាដើម។ ចំពោះប្រទេសអេស្តូនី ការបញ្ចូលកម្មវិធីអក្ខរកម្មឌីជីថលក្នុងប្រព័ន្ធអប់រំរដ្ឋនិងឯកជន ត្រូវបានដាក់ជារបៀបវារៈឌីជីថលអេស្តូនី ២០២០(Estonia Digital Agenda 2020) ដែលមានភាពស៊ីចង្វាក់គ្នាជាមួយយុទ្ធសាស្ត្រអប់រំពេញមួយជីវិត ២០២០ តាមរយៈការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធអប់រំ ការអភិវឌ្ឍសមត្ថភាព ក៏ដូចជាការលើកទឹកចិត្តដល់គ្រូបង្រៀននិងថ្នាក់ដឹកនាំស្ថាប័នអប់រំ ការផ្លាស់ប្តូរយុទ្ធសាស្ត្របង្រៀនបែបឌីជីថល និងការចាប់យកនូវវប្បធម៌ឌីជីថលក្នុងការសិក្សារៀនសូត្ររបស់សិស្សនិស្សិត ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនិងចីរភាពនៃសង្គមឌីជីថល។ បន្ថែមនេះ ប្រទេសដែលមានការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្រិតខ្ពស់ បានដាក់ចេញនូវការ

ប្រើប្រាស់ ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យាឈានមុខចុងក្រោយដូចជា ទិន្នន័យធំ បញ្ញាសិប្បនិម្មិត ប្លុកឆេន មជ្ឈមណ្ឌលទិន្នន័យក្លោដ និងអ៊ីនធឺណិតនៃវត្ថុជាដើម។

ម៉្យាងទៀត *ការលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋនិងឯកជន* ជាបទពិសោធដ៏ល្អសម្រាប់ជំរុញការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ ភាពជាដៃគូនេះផ្តោតលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធឌីជីថលនិងការរៀបចំប្រព័ន្ធអេកូឡូស៊ី សម្រាប់ទ្រទ្រង់ដំណើរការរដ្ឋាភិបាលឌីជីថល រួមមាន ការប្រតិបត្តិ ការថែទាំ ការបណ្តុះបណ្តាល ការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍។ ជាឧទាហរណ៍ នៅសាធារណរដ្ឋកូរ៉េ ភាពជាដៃគូវិនិយោគរវាងរដ្ឋនិងឯកជន ដោយការសហការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញនិងមជ្ឈមណ្ឌលទិន្នន័យតាមរយៈយន្តការវិនិយោគជាមុនទូទាត់ជាក្រោយ ត្រូវបានជំរុញ និងអនុវត្តក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ។

ការកំណត់ប្រភពហិរញ្ញប្បទានគាំទ្រក៏ជាកត្តាចម្បងមួយ ក្នុងការធានានូវការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយជោគជ័យ ដែលរួមមានប្រភពពីថវិកាជាតិ ភាពជាដៃគូជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងប្រភពស្របច្បាប់ផ្សេងៗទៀត។ ជាឧទាហរណ៍ នៅប្រទេសមួយចំនួន ប្រភពថវិកាសំខាន់មួយគឺរដ្ឋាភិបាលកំណត់កញ្ចប់ថវិកាជាតិប្រចាំឆ្នាំក្នុងអត្រាមួយនៃផលិតផលក្នុងស្រុកសរុប ដើម្បីធានាដល់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។

ទោះជាយ៉ាងណាក៏ដោយ បណ្តាប្រទេសក្នុងតំបន់មួយចំនួន ដូចជា ថៃ ម៉ាឡេស៊ីជាដើម នៅតែប្រឈមនឹងបញ្ហាដូចដែលប្រទេសឈានមុខគេក្នុងដំណើរការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្រិតខ្ពស់ធ្លាប់ជួបនៅដំណាក់កាលដំបូង ជាអាទិ៍ បញ្ហាមូលធនមនុស្ស ដោយការសម្របខ្លួនចាប់យកបច្ចេកវិទ្យាព័ត៌មានពីមន្ត្រី និងប្រជាពលរដ្ឋមានភាពយឺតយ៉ាវ ហើយស្ទាក់ស្ទើរក្នុងការផ្លាស់ប្តូរនៅក្នុងដំណាក់កាលដំបូង ដោយសារផ្នត់គំនិតនិងការជឿជាក់លើប្រព័ន្ធ កង្វះជំនាញ ការលើកទឹកចិត្ត និងការបណ្តុះបណ្តាល។ ថវិកាវិនិយោគរបស់រដ្ឋនៅមានកម្រិតសម្រាប់ការអភិវឌ្ឍនិងថែទាំប្រព័ន្ធព័ត៌មានឌីជីថលធំៗ ដោយសារខ្វះការចូលរួមពីវិស័យឯកជន។ ការចែករំលែកទិន្នន័យនិងព័ត៌មាន និងការធ្វើសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ជាបញ្ហាប្រឈមមួយដែលកើតឡើងដោយសារមិនមានលិខិតបទដ្ឋានគតិយុត្ត និងយន្តការច្បាស់លាស់ និងឆន្ទៈរបស់មន្ត្រីដែលពាក់ព័ន្ធ ជាហេតុធ្វើឱ្យមានការរាំងយ៉ាងខ្លាំងដល់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ បន្ថែមពីលើនេះ វប្បធម៌លាក់បាំងទិន្នន័យបានបង្កើតឱ្យមានភាពលំបាកក្នុងការភ្ជាប់ ការចូលដំណើរការ និងការប្រើប្រាស់ទិន្នន័យនៅក្នុងរដ្ឋាភិបាល។

ក្រៅពីនេះ សន្តិសុខឌីជីថលជាបញ្ហាប្រឈមមួយក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ដែលត្រូវដាក់បញ្ចូលនូវគោលនយោបាយនិងយុទ្ធសាស្ត្រសន្តិសុខឌីជីថលជាអាទិភាព។ ជាក់ស្តែង នៅខែមេសា ឆ្នាំ២០០៧ ប្រទេសអេស្តូនីបានទទួលរងការវាយប្រហារតាមអ៊ីនធឺណិតយ៉ាងខ្លាំងក្លា ដោយបានធ្វើឱ្យគេហទំព័រក្រសួងស្ថាប័ននិងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតទូទាំងប្រទេសមិនដំណើរការ រាប់បញ្ចូលទាំងប្រតិបត្តិការធនាគារ បណ្តាញទូរសព្ទចល័ត និងប្រព័ន្ធផ្សព្វផ្សាយនានា។

# ៣- ស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា

## ៣.១- ដំណើរវិវឌ្ឍ

នៅឆ្នាំ២០០០ ការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានឌីជីថលនៅប្រទេសកម្ពុជា បានចាប់ផ្តើមឡើងជាដំបូង តាមរយៈការបង្កើតឱ្យមាន**អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** (NiDA) ដែលស្ថិតក្រោមទីស្តីការគណៈរដ្ឋមន្ត្រី។ អាជ្ញាធរនេះទទួលបានការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុពីសាធារណរដ្ឋកូរ៉េ ហើយបានស្ថាបនាបណ្តាញហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ ដែលចាប់ផ្តើមដំបូងពីការតភ្ជាប់ក្រសួងស្ថាប័នក្នុងរាជធានីភ្នំពេញ និងបន្ទាប់មកនៅខេត្តអាទិភាពចំនួន៩ រួមមានខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង ហើយមានមជ្ឈមណ្ឌលទិន្នន័យចំនួន៣ គឺរាជធានីភ្នំពេញ ក្រុងព្រះសីហនុ និងក្រុងសៀមរាប និងបានអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថលចំនួន៣ រួមមានប្រព័ន្ធចុះបញ្ជីយានយន្ត ប្រព័ន្ធចុះបញ្ជីអចលនវត្ថុ និងប្រព័ន្ធចុះបញ្ជីស្នាក់នៅ។

នៅឆ្នាំ២០១៣ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវបានផ្ទេរមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ហើយបណ្តាញហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិដែលបានអភិវឌ្ឍដោយអាជ្ញាធរនេះ នៅបន្តការប្រើប្រាស់ដើម្បីផ្តល់សេវាដល់ក្រសួងស្ថាប័នរហូតដល់ពេលបច្ចុប្បន្ន។ បន្ទាប់មកទៀត រាជរដ្ឋាភិបាលកម្ពុជាបានខិតខំអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដោយបានដាក់ចេញនូវឯកសារគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលខ្លឹមសារគោលនៃឯកសារទាំងនេះ មានសង្គតិភាពជាមួយឧត្តមានុវត្តន៍អន្តរជាតិ និងបានរំលេចនូវភាពជាដៃគូស្អិតរមួតរវាងរដ្ឋាភិបាលនិងវិស័យឯកជន។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ពីឆ្នាំ២០១៣ដល់ឆ្នាំ២០១៨ បានគូសបញ្ជាក់ដំបូងអំពីតម្រូវការចាំបាច់ក្នុងការបន្តអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិក (e-Government) និងជំរុញវិស័យឯកជនឱ្យធ្វើការវិនិយោគកាន់តែច្រើនលើផ្នែកបច្ចេកវិទ្យានិងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។

នៅឆ្នាំ២០១៤ ***ផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានកម្ពុជាឆ្នាំ២០២០*** ត្រូវបានអនុម័តក្នុងគោលបំណងជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងពង្រឹងការអភិវឌ្ឍមូលធនមនុស្ស ការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត សន្តិសុខឌីជីថល និងសេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក។ បន្ទាប់មកទៀត ***ច្បាប់ស្តីពីទូរគមនាគមន៍*** ត្រូវបានប្រកាសឱ្យប្រើប្រាស់ក្នុងឆ្នាំ២០១៥ ក្នុងគោលបំណងធានាការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញ ផ្តល់សេវាទូរគមនាគមន៍ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព គុណភាព ភាពអាចទុកចិត្តបាន និងតម្លៃសមរម្យ ជំរុញនិងលើកទឹកចិត្តដល់វិស័យឯកជនឱ្យចូលរួមក្នុងការអភិវឌ្ឍវិស័យនេះ និងធានាការប្រកួតប្រជែងដោយសុចរិត និងការពារអ្នកប្រើប្រាស់។

នៅឆ្នាំ២០១៤នេះដែរ រាជរដ្ឋាភិបាលបានបង្កើតវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីជាសេនាធិការរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងការរួមចំណែក បណ្តុះបណ្តាលមូលធនមនុស្សជំនាញឌីជីថល ការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលដល់មន្ត្រីរាជការ ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល។ គិតត្រឹមឆ្នាំ២០២០ វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (NIPTICT) បានបណ្តុះបណ្តាលធនធានជំនាញឌីជីថលប្រមាណ៥០០នាក់ រៀបចំការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលដល់មន្ត្រីរាជការប្រមាណ១០០០នាក់ក្នុងមួយឆ្នាំ ពីគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ បណ្តុះបណ្តាលអក្ខរកម្មឌីជីថល

ដល់សិស្សានុសិស្ស និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតំបន់ដាច់ស្រយាលបានប្រមាណ២០០០នាក់ក្នុងមួយឆ្នាំ ព្រមទាំងធ្វើការស្រាវជ្រាវលើបច្ចេកវិទ្យាឌីជីថលដូចជាបច្ចេកវិទ្យាភាសាខ្មែរនិងបញ្ញាសិប្បនិម្មិត និងចូលរួមជំរុញនវានុវត្តន៍ឌីជីថលនិងការកសាងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីឌីជីថល។

នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្ម ***ផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានកម្ពុជាឆ្នាំ២០២០*** និងបានអនុម័ត ***គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឆ្នាំ២០២០*** ដោយបានដាក់ចេញនូវវិធានការគោលនយោបាយនិងកំណត់គោលដៅក្នុងការពង្រឹងមូលដ្ឋាននៃការអភិវឌ្ឍវិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ពង្រឹងសន្តិសុខឌីជីថល ជំរុញការអភិវឌ្ឍឧស្សាហកម្ម និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ លទ្ធផលនៃការអនុវត្តគោលនយោបាយនេះនៅមានកម្រិត មិនទាន់សម្រេចបានតាមគោលដៅដែលបានដាក់ចេញ ដោយសារកង្វះធនធានផ្សេងៗជាច្រើន ជាពិសេសធនធានថវិកានិងធនធានមនុស្ស។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានចាត់ទុកការអភិវឌ្ឍឌីជីថលជាវិស័យអាទិភាពយ៉ាងសំខាន់មួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៣ ដោយបានដាក់ទិសដៅបង្កើតឱកាសការងារថ្មីៗ និងការពង្រឹងរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនតាមរយៈការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនិងការទាញយកប្រយោជន៍ពីបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ ជាមួយគ្នានេះដែររាជរដ្ឋាភិបាលបាននិងកំពុងរៀបចំគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្ត ដើម្បីដាក់ចេញនូវកម្មវិធីសម្រាប់ការផ្តល់ព័ត៌មានសេវាឌីជីថលប្រកបដោយគុណភាព និងការតភ្ជាប់ប្រជាពលរដ្ឋទៅនឹងការសម្រេចចិត្តផ្នែកគោលនយោបាយសាធារណៈនានា ជាពិសេស តាមរយៈប្រព័ន្ធបណ្តាញសង្គមក៏ដូចជាការបង្កើនប្រសិទ្ធភាពនៃរាជរដ្ឋាភិបាលតាមរយៈការបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំរដ្ឋាភិបាលឌីជីថល ជាអាទិ៍ បច្ចេកវិទ្យាក្លោដ(Cloud Technology) និម្មាបនកម្មសហគ្រាស(Enterprise Architecture) ព្រមទាំងវិបផតថល(Web Portal) របស់រាជរដ្ឋាភិបាលដែលអនុញ្ញាតឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ អាចបង្ហោះនិងផ្សព្វផ្សាយសេវាសាធារណៈរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

នៅចុងឆ្នាំ២០១៩ កម្ពុជាបានអនុម័ត ***ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក*** ដែលកំណត់អំពីយថាភូតភាព សុក្រឹតភាព សុវត្ថិភាព និងភាពអាចជឿទុកចិត្តបាននៃទម្រង់និងទំនាក់ទំនងអេឡិចត្រូនិក និង ***ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់*** ដើម្បីការពារអ្នកប្រើប្រាស់និងចូលរួមលើកកម្ពស់ការប្រកួតប្រជែងដោយសុចរិត។ ជាមួយគ្នានោះដែរ កម្ពុជាក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងក្របខណ្ឌតំបន់ដូចជា ភាពជាដៃគូគ្រប់ជ្រុងជ្រោយតំបន់(RCEP) និងកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានកំណត់នូវកាតព្វកិច្ចមួយចំនួនសម្រាប់កម្ពុជាក្នុងការអនុវត្តកិច្ចព្រមព្រៀងទាំងនោះ។ ក្រៅពីនេះ រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំ ***សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន*** ក្នុងគោលដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យាព័ត៌មាន ***សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ*** ដើម្បីកំណត់គោលការណ៍ និងយន្តការបង្ការ គ្រប់គ្រង និងឆ្លើយតបចំពោះការគំរាមកំហែងសន្តិសុខឌីជីថលនិងឧប្បត្តិហេតុសន្តិសុខឌីជីថល ព្រមទាំង ***សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន*** ក្នុងគោលបំណងធានាដល់សាធារណជនគ្រប់រូបនូវសិទ្ធិសេរីភាពក្នុងការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

នៅឆ្នាំ២០២០ មានគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនិងប្រព័ន្ធព័ត៌មានឌីជីថលជាច្រើន ដូចជាការរៀបចំមជ្ឈមណ្ឌលទិន្នន័យចំនួន៣និងបន្ទប់សេវ៉ូបករណ៍នៅតាមក្រសួងស្ថាប័នចំនួន២០ តែមិនទាន់មានមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យនៅឡើយ ហើយសមត្ថភាពផ្នែកសន្តិសុខឌីជីថលក៏នៅមានកម្រិតទាប។ ម្យ៉ាងទៀត មានតែក្រសួងស្ថាប័នចំនួន៨%ប៉ុណ្ណោះដែលមានម៉ាស៊ីនភ្លើងសម្រាប់ដំណើរការមជ្ឈមណ្ឌលទិន្នន័យនៅពេលដាច់ភ្លើង ហើយចំនួន

២៤%មានប្រព័ន្ធការពារការបាត់បង់មូលទិន្នន័យ តែគ្រប់ក្រសួងស្ថាប័នទាំងអស់មិនទាន់មានយន្តការដែលអាចធានាបាននូវនិរន្តរភាពនៃប្រតិបត្តិការរដ្ឋាភិបាលឌីជីថលនៅឡើយទេ។ ក្រសួងស្ថាប័នមានរៀបចំបណ្តាញផ្ទៃក្នុងប្រើប្រាស់និងបណ្តាញអ៊ីនធឺណិតដែលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានផ្តល់ជូន ឬសេវាដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត តែបណ្តាញនិងសេវាទាំងអស់មិនបានតភ្ជាប់ទៅគ្រប់នាយកដ្ឋានឬផ្នែកទាំងអស់របស់ក្រសួងស្ថាប័នទេ ដែលទាមទារឱ្យមានការរៀបចំនិងកែលម្អឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ ដើម្បីធានាបាននូវការតភ្ជាប់និងការផ្តល់សេវាឱ្យកាន់តែល្អប្រសើរសម្រាប់គ្រប់ក្រសួងស្ថាប័ន។

នៅឆ្នាំ២០២០នេះដែរ នៅកម្ពុជា មានអ្នកប្រើប្រាស់សេវាអ៊ីនធឺណិតប្រមាណ១៥,៣៧លាន ក្នុងនោះ អ្នកប្រើប្រាស់សេវាអ៊ីនធឺណិតចល័តមានប្រមាណ១៥,១២លាន។ ការប្រើប្រាស់អ៊ីនធឺណិតមានភាពខុសគ្នាខ្លាំង រវាងសេវាអ៊ីនធឺណិតចល័តធៀបនឹងអចល័ត ទាំងចំនួនអ្នកប្រើប្រាស់ ទាំងចំណែកទីផ្សារ(ដូចមានក្នុងតារាងទី១)។ ម្យ៉ាងវិញទៀត កម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍គ្របដណ្តប់ស្ទើរទូទាំងផ្ទៃប្រទេស មានបណ្តាញខ្សែកាបអុបទិកឆ្អឹងខ្នងប្រមាណ៤១ពាន់គីឡូម៉ែត្រ និងបណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រចំនួន២ ក្នុងនោះ ខ្សែកាបអុបទិកក្រោមបាតសមុទ្រទី១ឈ្មោះ MCT(Malaysia-Cambodia-Thailand) បានតភ្ជាប់កម្ពុជាទៅនឹងប្រទេសថៃនិងប្រទេសម៉ាឡេស៊ី រីឯខ្សែទី២ឈ្មោះ AAE-1(Asia-Africa-Europe 1) បានតភ្ជាប់កម្ពុជាទៅនឹងប្រទេសចំនួន១៧ក្នុងទ្វីបអាស៊ី អាហ្វ្រិក និងអឺរ៉ុប។ បណ្តាញទូរសព្ទចល័តជំនាន់ទី៤(4G) បានផ្តល់សេវាគ្របដណ្តប់ដល់ប្រជាជនប្រមាណ៨០% ហើយបណ្តាញទូរសព្ទចល័តជំនាន់ទី៥(5G) ត្រូវបានដាក់ឱ្យធ្វើការសាកល្បងផងដែរ។

**តារាងទី១ : អត្រាអ្នកប្រើប្រាស់សេវាអ៊ីនធឺណិតនិងសេវាទូរគមនាគមន៍គ្របដណ្តប់ឆ្នាំ២០២០**

| **អត្រាអ្នកប្រើប្រាស់សេវាអ៊ីនធឺណិត** | | | |
|---|---|---|---|
| **ប្រតិបត្តិករ** | **ចំនួនអ្នកប្រើប្រាស់** | **អត្រាក្នុង១០០នាក់** | **ចំណែកទីផ្សារ** |
| សេវាអ៊ីនធឺណិតចល័ត(៥ក្រុមហ៊ុន) | ១៥ ១២៧ ០៣១ | ៩១,៦៥ | ៩៨,៣៦% |
| សេវាអ៊ីនធឺណិតអចល័ត(៣៥ក្រុមហ៊ុន) | ២៥២ ២១៦ | ១,៥៣ | ១,៦៤% |
| សរុប | ១៥ ៣៧៩ ២៤៧ | ៩៣,១៨ | ១០០% |

| **សេវាទូរគមនាគមន៍គ្របដណ្តប់** | | |
|---|---|---|
| **បរិយាយ** | **កម្រិតគ្របដណ្តប់ធៀបនឹងប្រជាជនសរុប(%)** | **កម្រិតគ្របដណ្តប់ធៀបនឹងផ្ទៃដីសរុប** |
| ការគ្របដណ្តប់នៃសេវាទូរសព្ទចល័ត 2G | ៩២,៣% | ៧៩,៥% |
| ការគ្របដណ្តប់នៃសេវាទូរសព្ទចល័ត 3G | ៨៥,២% | ៦៦,២% |
| ការគ្របដណ្តប់នៃសេវាទូរសព្ទចល័ត 4G | ៨២,៥% | ៦០,៤% |

*ប្រភព : និយ័តករទូរគមនាគមន៍កម្ពុជាឆ្នាំ២០២០*

ក្រៅពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងផ្តល់សេវាសាធារណៈចំនួន ១ ៥០៨ គិតត្រឹមខែតុលា ឆ្នាំ២០២០ ក្នុងនោះ មានសេវាដែលអាចទាញយកពាក្យស្នើសុំតាមអនឡាញ តែមិនអាចដាក់ពាក្យស្នើសុំតាមអនឡាញចំនួន៣៧២ ស្មើនឹង១០,៦០%, សេវាដែលអាចទាញយកពាក្យស្នើសុំនិងដាក់ពាក្យស្នើសុំតាមអនឡាញចំនួន៤១៦ ស្មើនឹង១១,៨៦% និងសេវាដាក់ពាក្យស្នើសុំដោយផ្ទាល់ពីការិយាល័យច្រកចេញចូលតែមួយចំនួន២ ៧២០ ស្មើនឹង៧៧,៥៤%។ ប្រព័ន្ធព័ត៌មានឌីជីថលផ្តល់សេវារបស់រាជរដ្ឋាភិបាលកម្ពុជាសរុបមានចំនួន១៨២ ជាអាទិ៍ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់មន្ត្រីរាជការស៊ីវិល ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ

ថ្នាលផ្លាស់ប្តូរទិន្នន័យ ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ ប្រព័ន្ធចុះបញ្ជីពន្ធដារ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ប្រព័ន្ធអេឡិចត្រូនិកកត់ត្រានិងគ្រប់គ្រងទិន្នន័យអ្នកជំងឺ ប្រព័ន្ធគ្រប់គ្រងផលិតកម្មនិងលិខិតឆ្លងដែន កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងនិងផ្តល់សេវានៅក្នុងអង្គភាពនិងការិយាល័យច្រកចេញចូលតែមួយ ប្រព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម ប្រព័ន្ធគ្រប់គ្រងដីធ្លី ប្រព័ន្ធគ្រប់គ្រងអ៊ីមែល និងប្រព័ន្ធចុះបញ្ជីយានយន្តនិងគ្រប់គ្រងបណ្ណបើកបរ។ ក្នុងចំណោមប្រព័ន្ធព័ត៌មានឌីជីថលនោះ មាន៥៦ប្រព័ន្ធ(៣០,៨%)សម្រាប់ផ្តល់សេវាសាធារណៈពីរដ្ឋាភិបាលដើម្បីប្រជាពលរដ្ឋ(G4C) ១៧ប្រព័ន្ធ(៩,៥%)សម្រាប់ផ្តល់សេវាសាធារណៈពីរដ្ឋាភិបាលទៅធុរកិច្ច(G2B) និង១០៩ប្រព័ន្ធ(៥៩,៨%)សម្រាប់ផ្តល់សេវាពីរដ្ឋាភិបាលទៅរដ្ឋាភិបាល(G2G)។ ប្រព័ន្ធព័ត៌មានឌីជីថលទាំងនេះ ភាគច្រើនត្រូវបានបង្កើតឡើងដោយក្រសួងស្ថាប័នរៀងៗខ្លួន ដោយមិនមានការតភ្ជាប់និងដំណើរការជាមួយគ្នា ហើយមួយចំនួនមានមុខងារជាន់គ្នា ដូចជាប្រព័ន្ធគ្រប់គ្រងមូលធនមនុស្ស ប្រព័ន្ធគ្រប់គ្រងឯកសារជាដើម។

**រូបភាពទី៣ : ស្ថានភាពបច្ចុប្បន្ននៃរដ្ឋាភិបាលឌីជីថលកម្ពុជា**




*ប្រភព : ការស្ទង់មតិដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឆ្នាំ២០២០*

កំណែទម្រង់សេវាសាធារណៈជាច្រើន ត្រូវបានអនុវត្តក្រោមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ដែលបានអនុម័តដោយគណៈរដ្ឋមន្ត្រីកាលពីឆ្នាំ២០០៦។ ចំពោះការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិបានអនុវត្តសាកល្បងតាមការិយាល័យច្រកចេញចូលតែមួយជាលើកដំបូង នៅស្រុកសៀមរាបនិងស្រុកបាត់ដំបងនាដើមឆ្នាំ២០០៣។ ផ្អែកតាមលទ្ធផលនៃការអនុវត្តគម្រោងសាកល្បងការិយាល័យច្រកចេញចូលតែមួយទាំងនេះ រាជរដ្ឋាភិបាល

បានសម្រេចបង្កើតយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត តាមរយៈអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ដើម្បីប្រមូលផ្តុំការផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយ តាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព។ គិតមកដល់ឆ្នាំ២០២១នេះ យន្តការច្រកចេញចូលតែមួយត្រូវបានពង្រីកជាបន្តបន្ទាប់រហូតទៅដល់១១៤ទីតាំងនៅទូទាំងប្រទេស។ គោលបំណងនៃការបង្កើត យន្តការច្រកចេញចូលតែមួយ គឺដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ កែលម្អសេវាសាធារណៈ លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងបង្វិតសេវាសាធារណៈឱ្យកាន់តែជិតនិងកាន់តែងាយស្រួលជូនដល់ប្រជាពលរដ្ឋ និងអាជីវកម្មខ្នាតតូចឱ្យបានឆាប់រហ័សនិងប្រកបដោយតម្លាភាព ដែលជាផ្នែកមួយនៃកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ជាក់ស្តែង អង្គភាពច្រកចេញចូលតែមួយរាជធានីខេត្តបាននិងកំពុងផ្តល់ជូនប្រជាពលរដ្ឋនិងវិស័យឯកជននូវសេវាសំខាន់ៗ ដែលបានផ្ទេរមកពីក្រសួងស្ថាប័នចំនួន១៣ មានសេវារដ្ឋបាលសរុបចំនួនជាង៦០០សេវា ដែលក្នុងនោះសេវាដែលផ្តល់ច្រើនជាងគេមានជាអាទិ៍ ការផ្ទេរកម្មសិទ្ធិនិងសិទ្ធិកាន់កាប់ដីធ្លី ការផ្តល់ប័ណ្ណការងារនិងសៀវភៅការងារ និងសេវាត្រួតពិនិត្យអនាម័យសត្វ។ ទន្ទឹមនេះ ការិយាល័យច្រកចេញចូលតែមួយ បាននិងកំពុងផ្តល់ជូនប្រជាពលរដ្ឋនិងវិស័យឯកជននូវសេវាសំខាន់ៗពីក្រសួងស្ថាប័ន ចំនួន១៦ មានសេវារដ្ឋបាលសរុបចំនួនជាង៣០០សេវា ហើយក្នុងនោះសេវាដែលបានប្រើប្រាស់ច្រើនជាងគេ មានដូចជា ការបញ្ជាក់ភាពត្រឹមត្រូវលើឯកសារថតចម្លង(នីត្យានុកូលកម្ម) ការចុះបញ្ជីដីធ្លី និងការស្នើសុំចុះបញ្ជីទោចក្រយានយន្ត។ ជាការកត់សម្គាល់ រាល់សេវារដ្ឋបាលទាំងអស់ដែលផ្តល់ដោយយន្តការច្រកចេញចូលតែមួយមិនមានសេវាណាមួយជាប្រភេទសេវាអនឡាញនោះទេ។

នៅឆ្នាំ២០២១ រាជរដ្ឋាភិបាលបានប្រែក្លាយវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ទៅជាបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងការដឹកនាំ គ្រប់គ្រង អភិវឌ្ឍការសិក្សាស្រាវជ្រាវ អប់រំ និងនវានុវត្តន៍លើបច្ចេកវិទ្យាឌីជីថល ព្រមទាំងចូលរួមលើកកម្ពស់ប្រព័ន្ធនវានុវត្តន៍ជាតិ។

ទោះបីមានកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍកន្លងមកក៏ដោយ ដំណើរការនៃរដ្ឋាភិបាលឌីជីថលកម្ពុជាស្ថិតនៅកម្រិតទី១នៅឡើយ(រដ្ឋាភិបាលអេឡិចត្រូនិកទៅតាមការបែងចែករបស់ក្រុមហ៊ុនហ្គាតណឺ) ដោយហេតុថា នាពេលបច្ចុប្បន្ន ឌីជីថលនីយកម្មតាមក្រសួងស្ថាប័ន មិនទាន់បានធ្វើសមាហរណកម្មបញ្ចូលគ្នា ដោយភាគច្រើនផ្តោតសំខាន់លើការអភិវឌ្ឍកម្មវិធីសម្រាប់សម្រួលការងារនិងផ្តល់សេវាសាធារណៈតិចតួច និងពុំមានយុទ្ធសាស្ត្ររួមសម្រាប់ធ្វើបរិវត្តកម្មឌីជីថល ឬគិតគូរជាសំខាន់ដល់ប្រសិទ្ធភាពនិងប្រសិទ្ធផល ដែលអាចកើតចេញពីទិន្នន័យប្រមូលផ្តុំបាន។ ការអភិវឌ្ឍទៀតសោត នៅមានបញ្ហាប្រឈម និងគម្លាតច្រើនដែលត្រូវដោះស្រាយ សម្រាប់ត្រៀមខ្លួនក្នុងការចូលរួមអភិវឌ្ឍរដ្ឋាភិបាលឌីជីថលឱ្យបានពេញលេញ ទាំងនៅក្នុងការអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថល ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល អង្គភាពទទួលបន្ទុកបច្ចេកវិទ្យាឌីជីថលតាមក្រសួងស្ថាប័ន មូលធនមនុស្ស និងការកំណត់អាទិភាពសេវាសាធារណៈសម្រាប់ឌីជីថលនីយកម្ម។

## ៣.២- កត្តាអំណោយផលនិងប្រឈម

កម្រិតសន្ទស្សន៍រដ្ឋាភិបាលឌីជីថល(EGDI)ក្នុងរយៈពេលពីរទសវត្សកន្លងមក ដែលវាស់វែងដោយនាយកដ្ឋានសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ(UN-DESA) បានបង្ហាញសញ្ញាណវិជ្ជមានឆ្ពោះទៅរកការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្រិតខ្ពស់។ សន្ទស្សន៍រដ្ឋាភិបាលឌីជីថល ត្រូវបានវាស់វែងតាមរយៈលក្ខណៈវិនិច្ឆ័យចំនួន៣ រួមមាន *សេវាអនឡាញ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍* និង *មូលធនមនុស្ស*។ យោងតាមសន្ទស្សន៍រដ្ឋាភិបាលឌីជីថលចុងក្រោយបង្អស់នាឆ្នាំ ២០២០(ដូចមានក្នុងរូបភាពទី២)បានបង្ហាញថា៦៥%នៃរដ្ឋជាសមាជិកចំនួន១៩៣របស់អង្គការសហប្រជាជាតិ មានការរីកចម្រើនលើការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ ប្រទេសឈានមុខផ្នែករដ្ឋាភិបាលឌីជីថលភាគច្រើនស្ថិតនៅតំបន់

អឺរ៉ុប ដូចជា ដាណឺម៉ាក អេស្តូនី អង់គ្លេស ខ្លះទៀតស្ថិតនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដូចជា សាធារណរដ្ឋកូរ៉េ សិង្ហបុរី ជប៉ុន អូស្ត្រាលី និងសហរដ្ឋអាមេរិក។ ដោយឡែកនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ សិង្ហបុរី និងម៉ាឡេស៊ី ឈរនៅជួរមុខ បន្ទាប់មក ថៃ ប្រ៊ុយណេ ហ្វីលីពីន វៀតណាម និងឥណ្ឌូណេស៊ី ហើយកម្ពុជា មីយ៉ាន់ម៉ា និងឡាវ មានការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលតិចតួច បើប្រៀបធៀបទៅនឹងប្រទេសជាសមាជិកអាស៊ានដទៃទៀត។

នៅឆ្នាំ២០២០ កម្ពុជាបានទទួលចំណាត់ថ្នាក់ទី១២៤ ក្នុងចំណោម១៩៣ប្រទេស កើនឡើងចំនួន២១ថ្នាក់ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨។ ភាពប្រសើរឡើងនូវចំណាត់ថ្នាក់ខាងលើនេះ គឺអាស្រ័យដោយសារមានការពង្រីកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងអត្រានៃអ្នកប្រើប្រាស់ទូរសព្ទចល័តដែលមានការកើនឡើងរហូតដល់ប្រមាណ១២០%។ ទោះបីចំណាត់ថ្នាក់កម្ពុជាមានភាពប្រសើរឡើងក៏ដោយ ក៏ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍នៅមិនទាន់មានវិសាលភាពគ្របដណ្តប់ពេញផ្ទៃប្រទេស រីឯគុណភាពសេវានៅមានកម្រិត ដែលទាមទារឱ្យមានការពង្រីកវិសាលភាពគ្របដណ្តប់ និងពង្រឹងគុណភាពសេវាអនឡាញបន្ថែមទៀត។ ក្នុងចំណោមសន្ទស្សន៍ទាំង៣ សន្ទស្សន៍សេវាអនឡាញមានពិន្ទុតិចជាងគេ ដែលតម្រូវឱ្យមានការកែលម្អបន្ថែម ដូចជាការរៀបចំវិបផតថលថ្នាក់ជាតិ និងនៅតាមក្រសួងស្ថាប័នសម្រាប់ផ្តល់សេវាអនឡាញជូនប្រជាពលរដ្ឋ និងធុរកិច្ច។ ចំណែកសន្ទស្សន៍មូលធនមនុស្សក៏ត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការធានាឱ្យបាននូវការកសាងអក្ខរកម្មឌីជីថលដល់ប្រជាពលរដ្ឋ ព្រមទាំងបណ្តុះបណ្តាលនូវជំនាញទន់ចាំបាច់រួមទាំងភាពជាអ្នកដឹកនាំបែបឌីជីថល ដើម្បីជំរុញឱ្យការធ្វើអន្តរកម្មរបស់ប្រជាពលរដ្ឋក្នុងប្រព័ន្ធអេកូឡូស៊ីរដ្ឋាភិបាលឌីជីថលកាន់តែមានប្រសិទ្ធភាព។

**រូបភាពទី៤ : សន្ទស្សន៍អភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជា**
**ធៀបនឹងប្រទេសក្នុងតំបន់និងពិភពលោកឆ្នាំ២០២០**




| សន្ទស្សន៍អភិវឌ្ឍរដ្ឋាភិបាលឌីជីថល | 2020 | 2018 | 2016 | 2014 | 2012 | 2010 | 2008 | 2005 | 2004 | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| សន្ទស្សន៍ | 124 | 145 | 158 | 139 | 155 | 140 | 139 | 128 | 129 | 134 |
| តម្លៃ | 0.51130 | 0.37530 | 0.25927 | 0.29986 | 0.29021 | 0.28784 | 0.29890 | 0.29891 | 0.28590 | 0.26369 |

*ប្រភព : នាយកដ្ឋានសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ(UN-DESA)២០២០*

រូបភាពខាងលើបញ្ជាក់ថា ថ្វីត្បិតតែមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក៏ដោយ ក៏រដ្ឋាភិបាលឌីជីថលកម្ពុជាស្ថិតនៅកម្រិតទាបក្រោមកម្រិតមធ្យម ទាំងក្នុងអនុតំបន់(អាស៊ាន) ក្នុងតំបន់(អាស៊ីប៉ាស៊ីហ្វិក) និងក្នុងពិភពលោក។ គម្លាតនៃការអភិវឌ្ឍនេះនឹងបន្តរីកទៅទៀត ប្រសិនបើរដ្ឋាភិបាលឌីជីថលកម្ពុជាមានការអភិវឌ្ឍ ដោយគ្មានសង្គតិភាពទៅនឹងនិន្នាការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលក្នុងពិភពលោក។ ដោយភាពចាំបាច់នៃការអភិវឌ្ឍតាមរយៈពិពិធកម្មសេដ្ឋកិច្ច

កម្ពុជាត្រូវតែចាត់វិធានការគោលនយោបាយគ្រប់បែបយ៉ាង ដើម្បីឱ្យល្បឿននៃបរិវត្តកម្មឌីជីថលសម្រេចបានលើកម្រិតមធ្យមនិងឈានដល់ក្នុងចំណោមប្រទេសនាំមុខ។

ក្នុងបរិបទនេះ កម្ពុជាត្រូវចាត់ចែងការត្រៀមខ្លួនឱ្យបានរួចជាស្រេចសម្រាប់ធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថលឱ្យទាន់ពេលវេលា ដោយសារនិន្នាការពិភពលោកនៅតែបន្តល្បឿនទៅមុខយ៉ាងឆាប់រហ័ស ជាពិសេស ការរីកចម្រើននិងនវានុវត្តន៍នៃបច្ចេកវិទ្យាឌីជីថល និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ និងដោយសារការប្រើប្រាស់ និងការទាញយកប្រយោជន៍ឱ្យអស់លទ្ធភាពពីបច្ចេកវិទ្យាឌីជីថល។ ក្នុងដំណាក់កាលនេះ កម្ពុជាមានកត្តាអំណោយផលជាច្រើនដែលសម្រួលដល់ការចាប់ផ្តើមបរិវត្តកម្មរដ្ឋាភិបាលឌីជីថលជាប្រព័ន្ធបានឆាប់ ហើយក៏មានកត្តាប្រឈមមួយចំនួនដែលអាចធ្វើឱ្យមានការលំបាកក្នុងដំណើរការបរិវត្តកម្មរដ្ឋាភិបាលឌីជីថល។

**<u>កត្តាអំណោយផល :</u>**

រាជរដ្ឋាភិបាលកម្ពុជាមាន*ឆន្ទៈនយោបាយនិងការគាំទ្រខ្ពស់* ដល់ការជំរុញការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល ស្របតាមការវិវឌ្ឍយ៉ាងឆាប់រហ័សក្នុងតំបន់និងសកលលោក។ ការគាំទ្ររបស់ថ្នាក់ដឹកនាំកំពូល នឹងជំរុញឱ្យមានការសម្របសម្រួលរវាងស្ថាប័នរដ្ឋ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ វិស័យឯកជន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីធានាបាននូវធនធានថវិកាសមស្រប និងការអនុវត្តគោលនយោបាយដោយរលូន។ ជាក់ស្តែង *ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ២០២១-២០៣៥* ក៏បានចង្អុលបង្ហាញយ៉ាងច្បាស់ពីសារៈសំខាន់នៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលជាចម្បង ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។

កម្ពុជាមានភាពអំណោយផលផ្នែកប្រជាសាស្ត្រ និងធនធានមនុស្សក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ កម្ពុជាមានយុវជន(ពីអាយុ១៥ ដល់អាយុ៣៥ឆ្នាំ)ប្រមាណ៣៧%នៃចំនួនប្រជាជនសរុប ដែលមានសក្តានុពលក្នុងការអភិវឌ្ឍខ្លួនទៅជាពលរដ្ឋនិងធុរជនឌីជីថល នាពេលអនាគត។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានមន្ត្រីជំនាញដែលមានកម្រិតយល់ដឹងនិងសមត្ថភាពក្នុងការរៀបចំនិងអនុវត្តការងាររដ្ឋាភិបាលឌីជីថល និងសន្តិសុខឌីជីថល។ មន្ត្រីជំនាញមួយចំនួនធ្លាប់មានបទពិសោធរៀបចំគម្រោងប្រព័ន្ធព័ត៌មានឌីជីថលរដ្ឋាភិបាលទ្រង់ទ្រាយធំ ដូចជាប្រព័ន្ធព័ត៌មានរដ្ឋបាលរដ្ឋាភិបាល(Government Administrative Information System - GAIS) និងប្រព័ន្ធព័ត៌មានរដ្ឋបាលខេត្ត (Provincial Administrative Information System - PAIS) ដែលជាមូលធនមនុស្សដ៏សំខាន់ក្នុងការចូលរួមរៀបចំ អភិវឌ្ឍ និងប្រតិបត្តិការប្រព័ន្ធរដ្ឋាភិបាលឌីជីថល។ ម្យ៉ាងទៀតនាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើតបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ដែលជាសេនាធិការឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងការអភិវឌ្ឍមូលធនមនុស្សប្រកបដោយគុណភាពនិងសមត្ថភាពលើផ្នែកបច្ចេកវិទ្យាឌីជីថល ការស្រាវជ្រាវនិងការអភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យាឌីជីថល ជាពិសេស វគ្គបណ្តុះបណ្តាលមន្ត្រីរាជការលើជំនាញឌីជីថល ដែលនឹងធានាកម្ពុជានូវប្រភពមូលធនមនុស្សក្នុងជំនាញឌីជីថលទាំងគុណភាព និងបរិមាណប្រកបដោយចីរភាព ដើម្បីជំរុញល្បឿនអភិវឌ្ឍរដ្ឋាភិបាលឌីជីថលស្របតាមនិន្នាការពិភពលោក។

កត្តាអំណោយផលមួយទៀត គឺកម្ពុជាមានការកើនឡើងយ៉ាងឆាប់រហ័សនៃ*ការប្រើប្រាស់ទូរសព្ទចល័តអ៊ីនធឺណិតនិងបច្ចេកវិទ្យាឌីជីថល*ដែលផ្តល់ភាពងាយស្រួលដល់ការពង្រីកសេវាតាមអនឡាញ។ ជាក់ស្តែង ក្នុងឆ្នាំ២០២០ អ្នកចុះឈ្មោះប្រើប្រាស់សេវាទូរសព្ទចល័តមានចំនួន២០,៨២លានលេខ ស្មើនឹង១២៦,១៩% នៃចំនួនប្រជាជនសរុប និងការតភ្ជាប់អ៊ីនធឺណិតតាមឧបករណ៍ចល័តមានចំនួន១៦,៣៣លាន ស្មើនឹង៩៨,៩៥%។ ជាមួយគ្នានេះ *អាជីវកម្មប្រើប្រាស់បច្ចេកវិទ្យាឌីជីថល* ក៏មានការកើនឡើងគួរឱ្យកត់សំគាល់ ស្របគ្នានឹងវត្តមាន*ក្រុមហ៊ុនធុរកិច្ចឌីជីថល* ដែលជាកម្លាំងចលករយ៉ាងសំខាន់ជំរុញដល់ការធ្វើបរិវត្តកម្មឌីជីថល។

កម្ពុជាជាទីផ្សារទាក់ទាញមួយសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលនៅក្នុងពិភពលោក។ តាមទិន្នន័យរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចំណូលបានពីមកពីវិស័យទូរគមនាគមន៍មានប្រមាណ១ ១០០(មួយពាន់មួយរយ) លានដុល្លារអាមេរិកក្នុងឆ្នាំ២០២០ ស្មើប្រមាណ៤,២%នៃផលិតផលក្នុងស្រុកសរុប។ បើប្រៀបធៀបទៅនឹងប្រទេសកំពុងអភិវឌ្ឍតិចតួច តួលេខនេះគឺស្ថិតនៅលើកម្រិតខ្ពស់នៃចំណូលពីវិស័យទូរគមនាគមន៍។ នាពេលបច្ចុប្បន្ន វិស័យទូរគមនាគមន៍ដើរតួនាទីយ៉ាងសំខាន់មួយក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់បណ្តាញទូរគមនាគមន៍និងអ៊ីនធឺណិតល្បឿនលឿនកំពុងតែទាក់ទាញការវិនិយោគ និងអនុញ្ញាតឱ្យវិស័យឯកជនពង្រីកខ្លួនចេញពីរាជធានីទៅតាមបណ្តាខេត្តនានាទូទាំងប្រទេស។ វិស័យនេះបាននិងកំពុងរួមចំណែកយ៉ាងសកម្ម និងដើរតួនាទីស្នូលក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចសំខាន់ៗដទៃទៀតមានដូចជា វិស័យកាត់ដេរដែលជាឧស្សាហកម្មចម្បង និងវិស័យទេសចរណ៍ដែលជាឧស្សាហកម្មទី២នាំឱ្យមានស្ថិរភាពកំណើនសេដ្ឋកិច្ចជាង៧% ជាបន្តបន្ទាប់ក្នុងរយៈពេលជាង២ទសវត្សកន្លងមកនេះ។

ការរីករាលដាលជំងឺកូវីដ-១៩ ដែលបង្កឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចនិងសង្គមយ៉ាងធ្ងន់ធ្ងរបានជំរុញឱ្យប្រទេសនិងដែនដីនៅលើពិភពលោកងាកទៅប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងកិច្ចការរដ្ឋបាល ធុរកិច្ច និងទំនាក់ទំនងសង្គម ដែលកត្តានេះជាកម្លាំងចលករយ៉ាងខ្លាំងក្លាជួយនឹងបង្កើនល្បឿននៃការធ្វើបរិវត្តកម្មឌីជីថលឱ្យកាន់តែលឿន និងមានប្រសិទ្ធភាពទាំងក្នុងក្របខណ្ឌជាតិនិងអន្តរជាតិថែមទៀតផង។ ការប្រឹងប្រែងក្តាប់យកនូវបរិវត្តកម្មឌីជីថល នឹងអាចជួយស្តារនិងកសាងឡើងវិញសេដ្ឋកិច្ចពិភពលោកបន្ទាប់ពីវិបត្តិជំងឺកូវីដ-១៩ នេះ បានកាន់តែឆាប់រហ័សកាន់តែប្រសើរក្នុងជីវភាពសង្គមសេដ្ឋកិច្ចបែបគន្លងប្រក្រតីថ្មី។

ជាមួយគ្នានេះ ការវិវត្តឆ្ពោះទៅរកការធ្វើទំនើបកម្មសេវាប្រៃសណីយ៍ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរួមជាមួយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងបណ្តាញប្រៃសណីយ៍ ឱ្យមានវិសាលភាពទូលំទូលាយ បង្កើតឱ្យមានកាលានុវត្តភាពដ៏សំខាន់មួយក្នុងការចូលរួមអភិវឌ្ឍរដ្ឋាភិបាលឌីជីថល សំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

<u>**កត្តាប្រឈម :**</u>

មកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាមិនទាន់មាន *ស្ថាប័នជាតិ* សម្រាប់សម្របសម្រួល ដឹកនាំ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងផែនការមេ ទាក់ទងនឹងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ដើម្បីធានាប្រសិទ្ធភាពនិងសង្គតិភាពនៃការអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថលសម្រាប់ក្រសួងស្ថាប័ននៅឡើយ។ ដោយសារកង្វះខាតនូវ*គោលនយោបាយ ឬយន្តការ*ថ្នាក់ជាតិដើម្បីអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ការរៀបចំ ផែនការសកម្មភាព និងថវិកាសម្រាប់គាំទ្រគម្រោងឌីជីថលនីយកម្ម(Digitalization) ផ្ទៃក្នុងរដ្ឋាភិបាលនៅពុំទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ ដែលបណ្តាលឱ្យការវិនិយោគគ្មានប្រសិទ្ធភាព ហើយបង្កើតជាបន្ទុកចំណាយខ្ជះខ្ជាយលើបណ្តាញហេដ្ឋារចនាសម្ព័ន្ធឌីជីថល មូលធនមនុស្ស ការថែទាំ និងអាជ្ញាបណ្ណប្រើប្រាស់សុសវែរ។ ដោយសារថវិកាជាតិមានកម្រិត ទន្ទឹមនឹងផែនការចំណាយដាច់ដោយឡែកពីគ្នានិងមិនមានសង្គតិភាពផងនោះ ហេដ្ឋារចនាសម្ព័ន្ធឌីជីថលចាំបាច់មួយចំនួនដែលអាចរៀបចំបាន ប្រែទៅជាមិនមានលទ្ធភាពក្នុងការវិនិយោគឱ្យបានចំគោលដៅអភិវឌ្ឍន៍។

ទន្ទឹមនេះ ដោយសារក្រសួងស្ថាប័ននីមួយៗ បង្កើត*ប្រព័ន្ធព័ត៌មានឌីជីថល* ទៅតាមតម្រូវការរៀងៗខ្លួន ប្រព័ន្ធរដ្ឋាភិបាលឌីជីថលកម្ពុជានាពេលបច្ចុប្បន្នមានសភាពដាច់ដោយឡែកៗពីគ្នានិងច្រំដែល(Silo and Redundancy) មិនមានសង្គតិភាពរវាងគ្នា និងគ្មានថ្នាលជាតិរួមមួយដែលមានការចូលរួមពីគ្រប់ក្រសួងស្ថាប័នសម្រាប់ផ្លាស់ប្តូរ និងចែករំលែកទិន្នន័យក្នុងក្របខណ្ឌអន្តរស្ថាប័ននៅឡើយ។ ប្រការដែលមិនបានគិតគូរពី យន្តការផ្លាស់ប្តូរទិន្នន័យនិងអវត្តមានប្រព័ន្ធផ្លាស់ប្តូរទិន្នន័យដោយសុវត្ថិភាព នាំឱ្យការផ្តល់សេវារដ្ឋាភិបាលឌីជីថលមិនទាន់មានលក្ខណៈពេញលេញ និងធ្វើឱ្យប្រសិទ្ធភាពនិងនវានុវត្តន៍នៃការផ្តល់សេវានៅមានកម្រិត។ លើសពីនេះ អ្នកប្រើប្រាស់សេវាទាំងប្រជាពលរដ្ឋ

ទាំងធុរជន ទាំងមន្ត្រីរាជការតម្រូវឱ្យផ្ដល់ឬបញ្ចូលព័ត៌មានដដែលៗ ដែលធ្វើឱ្យខាតពេលវេលានិងថវិកា បាត់បង់សង្គតិភាពទិន្នន័យ និងបង្កការលំបាកក្នុងការធ្វើអភិបាលកិច្ចទិន្នន័យក្នុងក្របខណ្ឌរដ្ឋាភិបាល។

តាមការធ្វើស្ទង់មតិដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៅដើមឆ្នាំ២០២០ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថលមានចំនួន៥២ ដែលក្នុងនោះប្រព័ន្ធប្រមាណ៣២% ប៉ុណ្ណោះដែលត្រូវបានអភិវឌ្ឍដោយអ្នកជំនាញក្រសួងស្ថាប័នសាមី ចំណែកឯប្រព័ន្ធផ្សេងទៀតត្រូវបានអភិវឌ្ឍដោយប្រើប្រាស់សេវាខាងក្រៅ ដែលភាគច្រើនជាជំនួយបរទេស និងអភិវឌ្ឍដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ជាមួយគ្នានេះ បញ្ហាភាពជាម្ចាស់លើភាសាកូដកម្មវិធីដែលបានកំពុងប្រើប្រាស់ក្នុងចំណោមប្រព័ន្ធព័ត៌មានឌីជីថលដែលបានអភិវឌ្ឍរួចហើយ មានកម្មវិធីប្រមាណ២៤% ដែលក្រសួងស្ថាប័នសាមីពុំមានលទ្ធភាពកែសម្រួលកូដដោយខ្លួនឯង ក្នុងភាពជាម្ចាស់កម្មសិទ្ធិពេញលេញ។ កង្វះភាពជាម្ចាស់លើកូដកម្មវិធីនេះ បានបង្កជាផលវិបាកក្នុងការថែទាំ កែសម្រួលមុខងារប្រព័ន្ធ ឬភ្ជាប់ទំនាក់ទំនងប្រព័ន្ធទាំងនោះជាមួយនឹងប្រព័ន្ធដទៃទៀត។ ទន្ទឹមនេះ ការអភិវឌ្ឍប្រព័ន្ធទាំងនេះប្រើប្រាស់ភាសាសរសេរកម្មវិធីមានចំនួនសរុប១៧ភាសា ដែលនាំឱ្យមានការលំបាកក្នុងការថែទាំនិងគ្រប់គ្រង ហើយត្រូវការមូលធនមនុស្សដែលមានជំនាញច្រើនទៀតផង ។ ម្យ៉ាងទៀត កង្វះភាពជាម្ចាស់លើប្រព័ន្ធទិន្នន័យ និងការគិតគូរពីទិន្នន័យដែលខ្លួនមាន គឺមានប្រព័ន្ធព័ត៌មានឌីជីថលប្រមាណជាង៣០% ដែលក្រសួងស្ថាប័នគ្មានសិទ្ធិពេញលេញលើការគ្រប់គ្រងប្រព័ន្ធទិន្នន័យទាំងនោះ ព្រោះ ត្រូវបានគ្រប់គ្រងដោយសេវាខាងក្រៅឬដោយដៃគូអភិវឌ្ឍ។ កម្មវិធីប្រមាណជាង១៨% បានផ្ទុកទិន្នន័យនៅលើប្រព័ន្ធក្លោដនៅក្រៅប្រទេស ដែលប្រឈមហានិភ័យខ្ពស់ក្នុងការលេចធ្លាយព័ត៌មាននិងទិន្នន័យរបស់ខ្លួន។

កត្តាប្រឈមមួយទៀត គឺកង្វះសង្គតិភាពរវាង ***ចំណាយវិនិយោគ*** លើប្រព័ន្ធព័ត៌មានឌីជីថល ទៅនឹងការកើនឡើងនៃសេវាសាធារណៈផ្ដល់ដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាក់ស្ដែង រាល់សេវាសាធារណៈនិងសេវារដ្ឋបាលទាំងអស់ដែលផ្ដល់ដោយយន្តការច្រកចេញចូលតែមួយមិនមានសេវាណាមួយ អនឡាញនោះទេ។ ប្រជាពលរដ្ឋត្រូវមក អង្គភាពឬការិយាល័យច្រកចេញចូលតែមួយ ដើម្បីបំពេញពាក្យស្នើសុំទទួលសេវាដែលមានទម្រង់ជាក្រដាសនៅផ្នែកជួរមុខ ដែលពាក្យស្នើសុំទាំងនោះត្រូវបានបញ្ជូនទៅផ្នែកជួរក្រោយ ដើម្បីដំណើរការទៅតាមនីតិវិធីបែបប្រពៃណីនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលករណីនេះ ប្រជាពលរដ្ឋត្រូវចំណាយសោហ៊ុយធ្វើដំណើរ និងពេលវេលាច្រើនក្នុងការមកដាក់ពាក្យស្នើសុំនិងមកទទួលសេវា(យ៉ាងតិច២ដង) ហើយដំណើរការផ្ដល់សេវាមានរយៈពេលវែងរវាងផ្នែកជួរមុខជាមួយក្រសួង ស្ថាប័ន និងមន្ទីរអង្គភាពជំនាញ ជាពិសេស ពិបាកក្នុងការគ្រប់គ្រងនូវឯកសារពាក្យស្នើសុំសេវាជាក្រដាសទាំងនោះទៀតផង។

ក្នុងបរិបទនេះ ដរាបណាការចំណាយវិនិយោគលើប្រព័ន្ធព័ត៌មានឌីជីថលមិនសមាមាត្រទៅនឹងការកើនឡើងនៃតម្រូវការសេវាសាធារណៈនិងសេវារដ្ឋបាលនោះទេ ការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថលនឹងមិនបានរួមចំណែកធ្វើឱ្យប្រសើរឡើងនិងបង្កើនប្រសិទ្ធភាពក្នុងការផ្ដល់សេវាសាធារណៈនិងសេវារដ្ឋបាលជូនប្រជាពលរដ្ឋនិងវិស័យធុរកិច្ចនោះឡើយ។

កន្លងមក *វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន* មិនទាន់ត្រូវបានចាត់ទុកជាវិស័យអាទិភាព ទើបនាំឱ្យ *ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍* ដែលជាក្រសួងទទួលបន្ទុកការរៀបចំនិងអភិវឌ្ឍរដ្ឋាភិបាលឌីជីថលជួបការលំបាកក្នុងការពង្រីកវិសាលភាពនិងសមត្ថភាពគ្រប់គ្រាន់សម្រាប់ទ្រទ្រង់រដ្ឋាភិបាលឌីជីថលទាំងមូលលើហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិសម្រាប់តភ្ជាប់ក្រសួងស្ថាប័ន មជ្ឈមណ្ឌលទិន្នន័យជាតិសម្រាប់ដំណើរការប្រព័ន្ធអ៊ីមែល ប្រព័ន្ធគ្រប់គ្រងគេហទំព័ររបស់ក្រសួងស្ថាប័ន និងធនធានគណនាសម្រាប់ប្រព័ន្ធព័ត៌មានឌីជីថលរបស់រដ្ឋាភិបាលដោយសារធនធានហិរញ្ញវត្ថុនៅមានកម្រិត។ ទន្ទឹមនេះ ក្រសួងស្ថាប័នមួយចំនួនបាននិងកំពុងវិនិយោគលើមជ្ឈមណ្ឌលទិន្នន័យរបស់ខ្លួន ដើម្បីដំណើរការប្រព័ន្ធព័ត៌មានឌីជីថលនិងសេវាឌីជីថល។ ដូច្នេះ ដើម្បីអភិវឌ្ឍរដ្ឋាភិបាលឌីជីថល

ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវដើរតួនាទីស្នូលក្នុងការដឹកនាំ អភិវឌ្ឍ និង ប្រតិបត្តិរដ្ឋាភិបាលឌីជីថល ជាពិសេស ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល។

*ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់និងសេវាអ៊ីនធឺណិត*ជាធាតុសំខាន់មិនអាចខ្វះបានសម្រាប់ទ្រទ្រង់ដល់បរិវត្តកម្មឌីជីថល។ បច្ចុប្បន្នគ្រប់ក្រសួងស្ថាប័នមានសេវាអ៊ីនធឺណិតសម្រាប់ប្រើប្រាស់តាមរយៈការតភ្ជាប់បណ្តាញផ្តល់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងការជាវបន្ថែមពីក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិតឯកជន។ ក្រសួងស្ថាប័នប្រមាណ៤៦% មិនមាន បណ្តាញផ្ទៃក្នុងសម្រាប់រៀបចំ និងបែងចែកការផ្តល់សេវាអ៊ីនធឺណិតបន្ត ជាហេតុធ្វើឱ្យការប្រើប្រាស់អ៊ីនធឺណិតមិនអស់ លទ្ធភាព។ បន្ថែមលើបញ្ហាកង្វះបណ្តាញផ្ទៃក្នុង ការតភ្ជាប់ក្រសួងស្ថាប័ននៅរាជធានីភ្នំពេញ នៅមិនទាន់ពេញលេញ នៅឡើយ ដោយសារការតភ្ជាប់នោះត្រឹមតែទីស្តីការក្រសួងស្ថាប័ន មិនបានទៅដល់គ្រប់ទីតាំងទាំងអស់នៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនោះទេ ហើយបណ្តាញតភ្ជាប់នេះបានភ្ជាប់ដោយផ្ទាល់ទៅអ៊ីនធឺណិត ដោយមិនបានបែង ចែកដាច់ដោយឡែកពីបណ្តាញអ៊ីនធឺណិតដែលប្រើប្រាស់ទូទៅនោះឡើយ។

លើសពីនេះ *កង្វះមជ្ឈមណ្ឌលទិន្នន័យជាតិ* ដែលមានម៉ាស៊ីនមេសម្រាប់ផ្តល់ធនធានគណនាប្រព័ន្ធព័ត៌មាន ឌីជីថលនិងកន្លែងផ្ទុកទិន្នន័យរួម ជាបញ្ហាចម្បងមួយសម្រាប់ក្រសួងស្ថាប័ន។ ក្នុងចំណោមក្រសួងស្ថាប័នទាំងអស់ មាន ក្រសួងស្ថាប័នប្រមាណ៣០% ដែលមានមជ្ឈមណ្ឌលទិន្នន័យផ្ទាល់ខ្លួន តែនិន្នាការនៃការបង្កើតមជ្ឈមណ្ឌលទិន្នន័យ ដោយឡែកសម្រាប់ក្រសួងស្ថាប័នរៀងខ្លួននេះកំពុងកើតមានឡើង។

ទន្ទឹមនឹងនេះ ទោះបីជារាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល និងមាន ប្រព័ន្ធ ទិន្នន័យអត្តសញ្ញាណបណ្ណរួចហើយក៏ដោយ ក៏នៅពុំទាន់មាន*ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល* ទទួលស្គាល់ រួមមួយក្នុងការកំណត់អត្តសញ្ញាណអ្នកធ្វើប្រតិបត្តិការអនឡាញ ជាពិសេស ជាមួយនឹងសេវា រដ្ឋាភិបាលឌីជីថល នានា។ ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថលនេះ គឺជាឃ្នាស់ដ៏សំខាន់មួយសម្រាប់ផ្តល់ទំនុកចិត្ត ប្រតិបត្តិការអនឡាញ ដែលជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលឱ្យបានទូលំទូលាយក្នុងវិស័យធនាគារ ធានារ៉ាប់រង ទូរសព្ទចល័ត និងសេវា គាំពារសង្គមជាដើម។ ដើម្បីដំណើរការហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល ត្រូវមានវិញ្ញាតធរហត្ថលេខាឌីជីថលមេ(Root Certificate Authority – Root CA) និងវិញ្ញាតធរហត្ថលេខាឌីជីថល(Certificate Authority - CA) ដែលទទួលស្គាល់ ដោយរាជរដ្ឋាភិបាល និងអាចបំពេញប្រតិបត្តិការរួមគ្នា ជាមួយនឹងប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្ម។

*សន្តិសុខឌីជីថល* ជាកត្តាប្រឈមមួយទៀត ដែលជាទូទៅនៅតាមក្រសួងស្ថាប័ននៅមានកម្រិតទាប នៅឡើយ ជាពិសេស លើកម្រិតអ្នកប្រើប្រាស់តែម្តង។ ជាក់ស្តែង មានក្រសួងស្ថាប័នប្រមាណ៦៣% កំពុងប្រើប្រាស់សុសវែរគ្មាន អាជ្ញាបណ្ណ រីឯ៣៧%ទៀត មានលទ្ធភាពជាវអាជ្ញាបណ្ណសុសវែរសម្រាប់ប្រព័ន្ធទិន្នន័យ និងប្រព័ន្ធដំណើរការសំខាន់ៗ តែប៉ុណ្ណោះ ក្រៅពីនេះសុសវែរសម្រាប់ប្រើប្រាស់ទូទៅស្ទើរតែ១០០% មិនមានអាជ្ញាបណ្ណត្រឹមត្រូវ។ តាមក្រសួងស្ថាប័ន ប្រមាណជាង៧០% អ្នកប្រើប្រាស់មិនបានដំឡើងកម្មវិធីកម្ចាត់មេរោគ មិនបានធ្វើបច្ចុប្បន្នកម្ម និងមិនបានស្កេន ជាទៀងទាត់ ដែលជាហេតុនាំឱ្យមានភាពងាយរងគ្រោះដោយសារមេរោគ។ ម្យ៉ាងទៀត មានតែក្រសួងស្ថាប័នប្រមាណ ២២%ប៉ុណ្ណោះ ដែលមានមន្ត្រីទទួលបន្ទុកសន្តិសុខឌីជីថល។

ក្រៅពីបញ្ហាសន្តិសុខឌីជីថល អវត្តមាននៃ *ប្រកទ្វារទូទាត់សងប្រាក់ថ្នាក់ជាតិ* សម្រាប់សេវាសាធារណៈ ដែលជា ថ្នាលសម្រាប់ក្រសួងស្ថាប័នធ្វើការទូទាត់ជាមួយអ្នកពាក់ព័ន្ធជាបញ្ហាប្រឈមក្នុងការជំរុញដល់ការធ្វើអន្តរប្រតិបត្តិការ ទូទាត់លើសេវាអនឡាញរបស់ក្រសួងស្ថាប័ន។

កត្តាប្រឈមចុងក្រោយ គឺយន្តការ *ភាពជាដៃគូរវាងរដ្ឋនិងឯកជន* លើការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលមិនមាន ភាពច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ។ ការចូលរួមវិនិយោគពីវិស័យឯកជនមិនត្រឹមតែនាំមកនូវប្រភពទុនហិរញ្ញប្បទាន បន្ថែមប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធ ប្រកបដោយនវានុវត្តន៍ និងកាន់តែមាន ប្រសិទ្ធភាពខ្ពស់ជាងមុនទៀតផង។ លើសពីនេះ ការចូលរួមពីវិស័យឯកជន ក៏ជាកត្តាជំរុញ និងជួយគាំទ្រដល់ការ

រីកលូតលាស់នៃឧស្សាហកម្មបច្ចេកវិទ្យាឌីជីថលក្នុងស្រុក ជាពិសេស ក្រុមហ៊ុនចាប់ផ្តើមធុរកិច្ចបច្ចេកវិទ្យាឌីជីថលដែលរួមមាន សេវាសន្តិសុខឌីជីថល និងការជួលសេវានិងដំណោះស្រាយដូចជាអភិវឌ្ឍ ប្រតិបត្តិ និងថែទាំប្រព័ន្ធថ្នាលបច្ចេកវិទ្យាឌីជីថលសម្រាប់រដ្ឋាភិបាលឌីជីថល ដោយប្រើប្រាស់ស្តង់ដាបើកចំហ ថ្នាលបើកចំហ និងកូដបើកចំហ។ ជាមួយគ្នានេះ ប្រព័ន្ធអេកូឡូស៊ីសម្រាប់គាំទ្រភាពជាដៃគូរវាងរដ្ឋនិងឯកជន ជាកត្តាមិនអាចខ្វះបានដើម្បីបង្កើតជាកម្លាំងចលករ បង្កើនល្បឿនអភិវឌ្ឍន៍និងជំរុញនវានុវត្តន៍ ដែលជាក្បាលម៉ាស៊ីនដ៏សំខាន់ក្នុងរដ្ឋាភិបាលឌីជីថល។

## ៤- ចក្ខុវិស័យ

ចក្ខុវិស័យនៃគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥ គឺ "**កសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ**"។

## ៥- គោលបំណង

គោលបំណងនៃគោលនយោបាយនេះ គឺ *កសាងរដ្ឋាភិបាលឆ្លាត ដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបច្ចេកវិទ្យាឌីជីថលជាប្រព័ន្ធអេកូឡូស៊ី សម្រាប់ការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចនិងការកែទម្រង់វិស័យផ្សេងៗប្រកបដោយតម្លាភាព ទំនុកចិត្ត និងការជឿជាក់ ព្រមទាំងការបង្កើតបរិយាកាសអំណោយផលក្នុងការជំរុញសេដ្ឋកិច្ចនិងសង្គមឌីជីថលប្រកបដោយបរិយាបន្ន*។

## ៦- គោលដៅនិងយុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងគោលបំណងខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវគោលដៅចំនួន៤ និងយុទ្ធសាស្ត្រចំនួន១០ ដូចខាងក្រោម៖

*១)-* **លើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល** ដែលមានយុទ្ធសាស្ត្រចំនួន៤៖

- ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល
- ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ
- ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល និង
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មានភស្តុភារកម្មប្រៃសណីយ៍។

*២)-* **កសាងអភិបាលកិច្ចនិងសេវាសាធារណៈឌីជីថល** ដែលមានយុទ្ធសាស្ត្រចំនួន២៖

- ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល ដូចជា ការរៀបចំនិងកែលម្អគោលនយោបាយ ការរៀបចំនិងកែលម្អក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការរៀបចំស្តង់ដានិងនិម្មាបនកម្មរដ្ឋាភិបាលឌីជីថល និង
- ការធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាលនិងសេវាសាធារណៈ ដូចជា ការធ្វើឱ្យប្រសើរឡើងនូវសេវាពីរដ្ឋាភិបាលទៅរដ្ឋាភិបាល(G2G) ការធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈពីរដ្ឋាភិបាលដើម្បីប្រជាពលរដ្ឋ (G4C) និងការធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈពីរដ្ឋាភិបាលទៅធុរកិច្ច(G2B)។

*៣)-* **កសាងសមត្ថភាពនិងនវានុវត្តន៍ឌីជីថល** ដែលមានយុទ្ធសាស្ត្រចំនួន២៖

- ការកសាងមូលធនមនុស្សឌីជីថល និង
- ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល។

*៤)-* **លើកកម្ពស់កិច្ចសហការនិងភាពជាដៃគូរវាងរដ្ឋនិងឯកជន៖** ដែលមានយុទ្ធសាស្ត្រចំនួន២៖

- ការរៀបចំកិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល និង
- ការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល។

*រូបភាពទី៥ : ចក្ខុវិស័យ គោលបំណង គោលដៅនិងយុទ្ធសាស្ត្រ*

**ចក្ខុវិស័យ**

កសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ

**គោលបំណង**

កសាងរដ្ឋាភិបាលឆ្លាត ដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបច្ចេកវិទ្យាឌីជីថលជាប្រព័ន្ធអេកូឡូស៊ី សម្រាប់ការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចនិងការកែទម្រង់វិស័យផ្សេងៗប្រកបដោយតម្លាភាព ទំនុកចិត្តនិងការជឿជាក់ ព្រមទាំងការបង្កើតបរិយាកាសអំណោយផល ក្នុងការជំរុញសេដ្ឋកិច្ចនិងសង្គមឌីជីថលប្រកបដោយបរិយាបន្ន

**គោលដៅ**

- លើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថល
- កសាងអភិបាលកិច្ចនិងសេវាសាធារណៈឌីជីថល
- កសាងសមត្ថភាពនិងនវានុវត្តន៍ឌីជីថល
- លើកកម្ពស់កិច្ចសហការនិងភាពជាដៃគូរវាងរដ្ឋនិងឯកជន

**យុទ្ធសាស្ត្រ**

- ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល
- ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ
- ហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល
- ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានភស្តុភារកម្មប្រៃសណីយ៍
- អភិបាលកិច្ចរដ្ឋាភិបាលឌីជីថល
- បរិវត្តកម្មឌីជីថលរដ្ឋាភិបាលនិងសេវាសាធារណៈ
- មូលធនមនុស្សឌីជីថល
- ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល
- កិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល
- ធុរកិច្ចថ្មីឌីជីថល

## ៧- សកម្មភាពអាទិភាព

យោងតាមផែនការសកម្មភាពដែលបានអនុម័តនៅក្នុង**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** មានវិធានការគោលនយោបាយគន្លឹះសរុបចំនួន១៣៩ សម្រាប់អនុវត្តក្នុងអំឡុងពេលពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣៥។ វិធានការគោលនយោបាយគន្លឹះទាំងនោះត្រូវបានរៀបចំឡើង ទៅតាមចង្កោមយុទ្ធសាស្ត្រផ្សេងៗគ្នា ដែលយុទ្ធសាស្ត្រតម្រង់ទៅគោលដៅទាំង៥ គឺ *១). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ២). ការកសាងទំនុកចិត្តនិងភាពជឿជាក់លើប្រព័ន្ធឌីជីថល ៣). ការកសាងពលរដ្ឋឌីជីថល ៤). ការកសាងរដ្ឋាភិបាលឌីជីថល និង ៥). ការជំរុញធុរកិច្ចឌីជីថល*។

ការទទួលបន្ទុកនៃការអនុវត្តវិធានការគោលនយោបាយគន្លឹះទាំងនេះ ត្រូវបានបែងចែកទៅគណៈកម្មាធិការទាំង៣ នៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល គឺគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល និងគណៈកម្មាធិការសន្តិសុខឌីជីថល។ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលទទួលបន្ទុកលើការកសាងរដ្ឋាភិបាលឌីជីថល គួបផ្សំជាមួយនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធគ្រឹះ ព្រមទាំងសហការជាមួយគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ក្នុងការកសាងពលរដ្ឋឌីជីថល និងធុរកិច្ចឌីជីថល។ ពាក់ព័ន្ធនឹងការកសាងទំនុកចិត្តនិងភាពជឿជាក់លើប្រព័ន្ធឌីជីថល គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល នឹងសហការជាមួយគណៈកម្មាធិការសន្តិសុខឌីជីថលក្នុងការអនុវត្តសកម្មភាពអាទិភាពមួយចំនួន។

តាមរយៈនៃការបែងចែកខាងលើ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលទទួលបន្ទុកអនុវត្តវិធានការគោលនយោបាយគន្លឹះចំនួន៦០ក្រោមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។ ឈរលើមូលដ្ឋាននេះ ឯកសារគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥ កំណត់នូវ *សកម្មភាពអាទិភាពចំនួន៨៦* ទៅតាមយុទ្ធសាស្ត្រនីមួយៗ។

### ៧.១- យុទ្ធសាស្ត្រ៖ ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល

ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល ធ្វើឡើងក្នុងគោលបំណងធានាបាននូវគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពនៃការតភ្ជាប់បណ្តាញ ការរក្សាទុក ដំណើរការនិងការចែករំលែកទិន្នន័យ ដែលជាមូលដ្ឋានសម្រាប់គាំទ្រដល់ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថល។ សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះមានដូចខាងក្រោម៖

- ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធទូរសព្ទចល័តនិងអ៊ីនធឺណិតល្បឿនលឿន តាមរយៈ ១- ការពង្រឹងគុណភាពនិងពង្រីកវិសាលភាពនៃសេវាទូរសព្ទចល័តជំនាន់ទី៤(4G) ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតល្បឿនលឿនពាក់ព័ន្ធឱ្យបានដល់គ្រប់ស្រុកឃុំ ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល និងតំបន់ដែលមិនទាន់មានសេវាគ្របដណ្តប់ ក្នុងភាពជាដៃគូជាមួយវិស័យឯកជននិងការប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកល ២- ការកសាងហេដ្ឋារចនាសម្ព័ន្ធនិងផ្តល់សេវាបច្ចេកវិទ្យាទូរសព្ទចល័តជំនាន់ទី៥(5G) និងប្រមើលមើលបច្ចេកវិទ្យាទូរគមនាគមន៍បច្ចេកវិទ្យាជំនាន់ថ្មីៗទៀត ស្របតាមនិន្នាការបរិវត្តកម្ម នៃបច្ចេកវិទ្យា ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ក្នុងដំណើរឆ្ពោះទៅកឧស្សាហកម្មជំនាន់ទី៤ និងជួយទ្រទ្រង់ដល់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ៣- ការកសាងបណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រ និង ៤- ការរៀបចំហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍រួមសម្រាប់គ្រប់ប្រតិបត្តិករទូរគមនាគមន៍ ដើម្បីកាត់បន្ថយចំណាយលើការវិនិយោគនិងតម្លៃប្រើប្រាស់របស់ប្រជាពលរដ្ឋ និងបង្កើនប្រសិទ្ធភាពនៃសេវាទូរគមនាគមន៍។

- បង្កើតមជ្ឈមណ្ឌលទិន្នន័យជាតិ ដែលមានទាំងមជ្ឈមណ្ឌលប្រតិបត្តិការនិងមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ ដោយប្រើប្រាស់ បច្ចេកវិទ្យាក្លោដសម្រាប់ផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធ ថ្នាល សុសវែរ និងសេវាទិន្នន័យ ដែលបញ្ចូលទាំងសេវាវិភាគទិន្នន័យ និងទិន្នន័យធំ(Big Data) សម្រាប់គាំទ្រដល់អភិបាលកិច្ច ការសម្រេចចិត្ត និងការបង្កើតចំណេះដឹងផ្សេងៗ របស់ក្រសួងស្ថាប័ន សំដៅកាត់បន្ថយចំណាយ បង្កើនប្រសិទ្ធភាព សុវត្ថិភាព និងផលិតភាពការងាររបស់រាជរដ្ឋាភិបាល។ ការកសាងមជ្ឈមណ្ឌលទិន្នន័យនេះនឹង តភ្ជាប់ទៅគ្រប់ មជ្ឈមណ្ឌលទិន្នន័យរបស់ក្រសួងស្ថាប័នដែលមានស្រាប់ និងជានានូវការថែរក្សា ការការពារ និងការចែករំលែក ទិន្នន័យប្រកបដោយប្រសិទ្ធភាពនិងការទទួលខុសត្រូវ។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធបណ្តាញរដ្ឋាភិបាលឌីជីថល តភ្ជាប់នៅគ្រប់ក្រសួងស្ថាប័ន និងស្ថានតំណាងកម្ពុជានៅបរទេសទាំងអស់លើបណ្តាញឯកជន(Private Network) ដាច់ដោយឡែកពីបណ្តាញប្រើប្រាស់ទូទៅ ដោយកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់ និងវិនិយោគបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធបណ្តាញថ្មីៗទៀត ដើម្បីឱ្យមានសមត្ថភាពពេញលេញក្នុងការគាំទ្រដល់ប្រតិបត្តិការរដ្ឋាភិបាលឌីជីថល តាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជននិង/ឬអង្គភាពក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
- ជំរុញការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីផ្គាយរណបតាមរយៈ ១- រៀបចំមូលដ្ឋានគ្រឹះសំខាន់ៗ ដើម្បីពង្រឹងនិងជំរុញការប្រើប្រាស់អេកូឡូស៊ីនៃប្រព័ន្ធផ្កាយរណប ២- រៀបចំថ្នាលនៃការប្រើប្រាស់ទិន្នន័យពីប្រព័ន្ធផ្កាយរណបសម្រាប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធដោយផ្តោតទៅលើនិរន្តរភាព និងប្រសិទ្ធិភាពនៃការអនុវត្តគម្រោង ៣- ពង្រឹងធនធានមនុស្សសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យានិងប្រើប្រាស់ប្រព័ន្ធផ្កាយរណប ។
- ពង្រឹងនិងពង្រីកថ្នាលផ្លាស់ប្តូរទិន្នន័យ(CamDX) ដើម្បីឱ្យមានសមត្ថភាពក្នុងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធព័ត៌មាននៅគ្រប់ក្រសួងស្ថាប័ន និងមានលទ្ធភាពក្នុងការតភ្ជាប់ជាមួយប្រព័ន្ធព័ត៌មានរបស់វិស័យឯកជនដើម្បីសម្រួលនិងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។
- ជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅថ្នាក់ក្រោមជាតិចាប់ពីកម្រិតរាជធានីខេត្ត ដល់ឃុំសង្កាត់ ដូចជារដ្ឋបាលឃុំសង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ សាលារៀន និងមណ្ឌលសុខភាព ដើម្បីគាំទ្រការផ្តល់សេវាសាធារណៈឌីជីថល ការបណ្តុះបណ្តាលពីចម្ងាយ ការប្រឹក្សានិងធ្វើរោគវិនិច្ឆ័យពីចម្ងាយ ការចាប់យកបច្ចេកវិទ្យាឌីជីថលរបស់ប្រជាពលរដ្ឋ និងព័ត៌មានអំពីទីផ្សារនិងផលិតផលកសិកម្ម។

### ៧.២- យុទ្ធសាស្ត្រ៖ ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ

សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះ គឺការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ តាមរយៈការតភ្ជាប់និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារទូទាត់សងប្រាក់ថ្នាក់ជាតិ ក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាព សុវត្ថិភាព ភាពងាយស្រួល និងភាពជឿទុកចិត្តខ្ពស់នៃការទូទាត់សងប្រាក់សម្រាប់សេវាសាធារណៈនិងសេវាផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលប្រកបដោយបរិយាបន្ន។

## ៧.៣- យុទ្ធសាស្ត្រ៖ ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល

ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល ធ្វើឡើងក្នុងគោលបំណងការពារហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថលឱ្យបានគ្រប់ជ្រុងជ្រោយ និងការធានាបាននូវសុវត្ថិភាពនិងសន្តិសុខខ្ពស់សម្រាប់ការគ្រប់គ្រងប្រតិបត្តិការ និងការប្រើប្រាស់ប្រព័ន្ធ ឬបច្ចេកវិទ្យាឌីជីថល ដែលជាមូលដ្ឋានគ្រឹះនៃការកសាងទំនុកចិត្ត និងភាពជឿជាក់លើការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថល។ សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះមានដូចខាងក្រោម៖

- ពង្រឹងប្រព័ន្ធគ្រប់គ្រងនិងការពារសន្តិសុខឌីជីថលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ តាមរយៈការកំណត់នីតិវិធីសុវត្ថិភាព និងការបំពាក់សម្ភារៈបរិក្ខារបច្ចេកទេសសម្រាប់តាមដាន ត្រួតពិនិត្យ និងទប់ស្កាត់ការវាយប្រហារនានាតាមប្រព័ន្ធឌីជីថលស្របតាមស្តង់ដា សន្តិសុខព័ត៌មាន។
- រៀបចំនិងពង្រឹងសន្តិសុខច្រកទ្វារអ៊ីនធឺណិតជាតិ ដើម្បីបង្កើនសមត្ថភាពក្នុងការការពារសន្តិសុខជាតិ និងការថែរក្សារបៀបរៀបរយសណ្តាប់ធ្នាប់សង្គម សីលធម៌ វប្បធម៌ និងប្រពៃណីជាតិ តាមរយៈការជំរុញការបង្កើតហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារអ៊ីនធឺណិតជាតិ និងបំពាក់នូវឧបករណ៍បរិក្ខារបច្ចេកទេសសម្រាប់តាមដាន ត្រួតពិនិត្យ និងទប់ស្កាត់ការវាយប្រហារផ្សេងៗតាមប្រព័ន្ធអ៊ីនធឺណិត។
- រៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថលដើម្បីគាំទ្រដល់ការគ្រប់គ្រង ការប្រើប្រាស់ និងការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់រូបវន្តបុគ្គលនិងនីតិបុគ្គលក្នុងទម្រង់ឌីជីថល សម្រាប់ធ្វើប្រតិបត្តិការលើថ្នាលឌីជីថលទាំងក្នុងក្របខណ្ឌរដ្ឋាភិបាលឌីជីថលនិងវិស័យឯកជន តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ(Public Key Infrastructure - PKI )និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឈានមុខ។ រាជរដ្ឋាភិបាលបានចាប់ផ្តើមពីការរៀបចំអត្តសញ្ញាណឌីជីថលរបស់ប្រជាពលរដ្ឋដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ និងអ្នកប្រើប្រាស់កម្មវិធីកូដQR បង្កើតជាវិញ្ញាបនបត្រចាក់វ៉ាក់សាំងឌីជីថល ដែលបានប្រែក្លាយទៅជាវិញ្ញាបនបត្រសុខភាពឌីជីថលសម្រាប់ប្រជាពលរដ្ឋ ប្រើប្រាស់ក្នុងការធ្វើដំណើរក្នុងនិងក្រៅប្រទេស។ ឈរលើមូលដ្ឋាននៃវិញ្ញាបនបត្រសុខភាពឌីជីថលនេះ រាជរដ្ឋាភិបាលនឹងពង្រីកការរៀបចំអត្តសញ្ញាណឌីជីថលទៅលើអ្នកជំងឺ ប្រជាពលរដ្ឋ មន្ត្រីរាជការ សិស្ស និស្សិត ក្រសួង ស្ថាប័ន និងក្រុមហ៊ុនទូទាំងប្រទេស។ យន្តការនៃការផ្តល់ ការត្រួតពិនិត្យ ការផ្ទៀងផ្ទាត់ និងការប្រើប្រាស់អត្តសញ្ញាណឌីជីថល ត្រូវរៀបចំស្របតាមតម្រូវការជាក់ស្តែងរបស់ជាតិនិងឧត្តមានុវត្តន៍តំបន់និងសកល។ ដូចមានចែងក្នុងយន្តការអនុវត្ត ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងទទួលបន្ទុកអភិវឌ្ឍនិងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រអត្តសញ្ញាណឌីជីថល ដូចជា មជ្ឈមណ្ឌលទិន្នន័យក្លោដនិងហេដ្ឋារចនាសម្ព័ន្ធការពារសន្តិសុខឌីជីថល ហើយក្រសួងស្ថាប័នសាមីជាម្ចាស់គ្រប់គ្រងទិន្នន័យអត្តសញ្ញាណឌីជីថល។

## ៧.៤- យុទ្ធសាស្ត្រ៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មានភស្តុភារកម្មប្រៃសណីយ៍

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មានភស្តុភារកម្មប្រៃសណីយ៍ ធ្វើឡើងដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងកែលម្អប្រព័ន្ធបណ្តាញនិងថ្នាលឌីជីថលប្រៃសណីយ៍ជាតិ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងនិងពង្រីកការផ្តល់សេវាប្រៃសណីយ៍ប្រកបដោយប្រសិទ្ធភាព។

## ៧.៥- យុទ្ធសាស្ត្រ៖ ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល

ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល ចាប់ផ្តើមពីការរៀបចំនិងការអនុម័តគោលនយោបាយចាំបាច់ ការរៀបចំនិងកែលម្អក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការរៀបចំស្តង់ដានិងនិម្មាបនកម្មរដ្ឋាភិបាលឌីជីថលស្របតាមគោលការណ៍ និយាម ម៉ូដែល ការវិវត្តនៃបច្ចេកវិទ្យា និងឧត្តមានុវត្តន៍ជាតិនិងអន្តរជាតិ ដែលជាមូលដ្ឋាន

សម្រាប់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសុវត្ថិភាព ក្នុងគោលដៅរួមចំណែកគាំទ្រដល់ការកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថលឱ្យបានរឹងមាំនិងរស់រវើក។ សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះ មានដូចខាងក្រោម៖

- រៀបចំគោលនយោបាយអភិបាលកិច្ចទិន្នន័យ ដើម្បីកំណត់អំពីគោលការណ៍ ស្តង់ដា និម្មាបនកម្មទិន្នន័យ យន្តការ និងក្របខណ្ឌនៃការគ្រប់គ្រង ការផ្លាស់ប្តូរ មូលដ្ឋាននីយកម្ម ការចែកចំណាត់ថ្នាក់ ការចែករំលែក និងការការពារទិន្នន័យ ព្រមទាំងលំហូរទិន្នន័យឆ្លងកាត់ព្រំដែន ក្នុងគោលដៅជានាឱ្យមានទិន្នន័យគ្រប់គ្រាន់ប្រកបដោយគុណភាពនិងសុវត្ថិភាពស្របទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ដោយគ្មានការរើសអើង។
- រៀបចំគោលនយោបាយទិន្នន័យបើកចំហ ដើម្បីកំណត់អំពីគោលការណ៍ ស្តង់ដា អាជ្ញាបណ្ណ និងយន្តការនៃការបើកចំហ ការរក្សាទុក និងការចែករំលែកទិន្នន័យរបស់រាជរដ្ឋាភិបាលជូនស្ថាប័នសាធារណៈ វិស័យធុរកិច្ច និងប្រជាពលរដ្ឋ ដើម្បីយកទៅប្រើប្រាស់ជាប្រយោជន៍ផ្សេងៗ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ការបើកចំហទិន្នន័យនេះមានគោលដៅបង្កើនតម្លាភាព សមភាព និងគណនេយ្យភាព និងលើកកម្ពស់គុណភាពសេវាសំដៅបង្កើនទំនុកចិត្តរបស់សាធារណជនមកលើរាជរដ្ឋាភិបាល ព្រមទាំងលើកកម្ពស់ការស្រាវជ្រាវនិងនវានុវត្តន៍ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមប្រកបដោយចីរភាពនិងបរិយាបន្ន។
- រៀបចំគោលនយោបាយជំរុញការអភិវឌ្ឍ និងការប្រើប្រាស់សុសវែរ ដើម្បីកំណត់អំពីគោលការណ៍ ស្តង់ដាគុណភាព និងយន្តការនៃការគ្រប់គ្រងនិងការលើកទឹកចិត្ត ដើម្បីពង្រីកទីផ្សារ ជំរុញការវិនិយោគ កសាងមូលធនមនុស្សជំនាញទាំងស្ត្រីនិងបុរស និងផ្តល់ការអប់រំទៅលើរបៀបប្រើប្រាស់សុសវែរថ្មីៗតាមគ្រប់រូបភាព សម្រាប់គាំទ្រដល់ការអភិវឌ្ឍនិងការប្រើប្រាស់សុសវែរ។ គោលនយោបាយនេះនឹងបង្កើនការប្រើប្រាស់និងការផ្គត់ផ្គង់សុសវែរក្នុងស្រុក កាត់បន្ថយការចំណាយលើការនាំចូលសុសវែរ លើកកម្ពស់សមត្ថភាពប្រកួតប្រជែង និងបង្កើនផលិតភាពសេដ្ឋកិច្ចជាតិ។
- រៀបចំគោលនយោបាយអ៊ីនធឺណិតល្បឿនលឿន ដើម្បីកំណត់អំពីគោលការណ៍ ក្របខណ្ឌនិងយន្តការនៃការគ្រប់គ្រង ការធ្វើនិយ័តកម្ម ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងស្តង់ដាគុណភាព ដើម្បីជំរុញការផ្តល់សេវាអ៊ីនធឺណិតល្បឿនលឿនឱ្យមានវិសាលភាពគ្របដណ្តប់គ្រប់ទីកន្លែងទូទាំងប្រទេស ងាយស្រួលប្រើប្រាស់ តម្លៃសមរម្យ និងប្រកបដោយគុណភាព ឆ្លើយតបនឹងតម្រូវការនិងលទ្ធភាពចំណូលរបស់ប្រជាពលរដ្ឋ ជាពិសេសនៅតំបន់ដាច់ស្រយាល។ ការជំរុញការអភិវឌ្ឍអ៊ីនធឺណិតល្បឿនលឿនជាកត្តាចាំបាច់សម្រាប់គាំទ្រ និងលើកកម្ពស់ការប្រើប្រាស់សេវារដ្ឋាភិបាលឌីជីថល និងសេវាផ្សេងៗទៀត ដែលត្រូវផ្តល់តាមរយៈប្រព័ន្ធអ៊ីនធឺណិត។
- រៀបចំគោលនយោបាយឌីជីថលសម្រាប់ទីក្រុងឆ្លាត ដើម្បីកំណត់អំពីគោលការណ៍ ស្តង់ដា ក្របខណ្ឌ និងយន្តការសម្រាប់ការរៀបចំអភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ថ្នាល ទិន្នន័យ សេវា និងសន្តិសុខឌីជីថល សំដៅជំរុញដល់ការអភិវឌ្ឍទីក្រុងឆ្លាត ជាពិសេស ធ្វើឱ្យប្រសើរ ឡើងនូវប្រសិទ្ធភាពនៃអភិបាលកិច្ចទីក្រុង តាមរយៈការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវបច្ចេកវិទ្យាឌីជីថលនិងទិន្នន័យ ដើម្បីបង្កើន គុណភាពជីវិតប្រជាពលរដ្ឋនិងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន។
- រៀបចំគោលនយោបាយជំរុញការអភិវឌ្ឍវិស័យប្រៃសណីយ៍ ដើម្បីជាប្រទីបនាំផ្លូវឆ្ពោះទៅរកការដោះស្រាយបញ្ហាប្រឈមនានា ក្នុងទិសដៅទាញយកផលប្រយោជន៍ឱ្យបានពេញលេញពីកាលានុវត្តភាពដែលបាននិងកំពុងលេចឡើង និងជួយជំរុញការអភិវឌ្ឍក្របខណ្ឌគតិយុត្ត យន្តការ ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ប្រៃសណីយ៍ ព្រមទាំងពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មផ្តល់សេវាបញ្ញើរបស់ផ្នែកឯកជន ជាមួយនឹងការដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តជាក់ស្តែង ដែលមានលក្ខណៈប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមក រវាងប្រតិបត្តិករ និងប្រតិបត្តិករ នៃវិស័យប្រៃសណីយ៍ដែលអាចផ្តល់សេវាប្រកបដោយ និរន្តរភាព ទូលំទូលាយ អាច

ជឿទុកចិត្តបាន ស្របតាមនិយាមអន្តរជាតិ បំពេញបានតាមតម្រូវការរបស់អ្នកប្រើប្រាស់ និងជួយសម្រួលដល់ការតភ្ជាប់ចុងម្ខាងនៃផលិតកម្មទៅចុងម្ខាងនៃការប្រើប្រាស់។

- រៀបចំគោលនយោបាយជំរុញការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលសំខាន់ៗ ដើម្បីកំណត់អំពីគោលការណ៍ ស្តង់ដា ក្របខណ្ឌ និងយន្តការនៃការជំរុញការអភិវឌ្ឍ និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ជាពិសេស បច្ចេកវិទ្យាថ្មីៗ ជាអាទិ៍ បច្ចេកវិទ្យាក្លោដ បញ្ញាសិប្បនិម្មិត ទិន្នន័យធំ អ៊ីនធឺណិតនៃវត្ថុ និងប្លុកឆេន ក្នុងគោលដៅលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ក៏ដូចជាការពង្រឹងប្រសិទ្ធភាព ប្រសិទ្ធផល និងសុវត្ថិភាព រដ្ឋាភិបាលឌីជីថល។
- រៀបចំច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថល ដើម្បីកំណត់អំពីគោលការណ៍ នីតិវិធី ថវិកា និងវិធីសាស្ត្រសម្រាប់អភិវឌ្ឍ គ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថល និងបទប្បញ្ញត្តិស្តីពីការប្រើប្រាស់និងចែករំលែកទិន្នន័យរបស់រាជរដ្ឋាភិបាល ទៅតាមក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនេះ មន្ត្រីសាធារណៈអាចប្រើប្រាស់ទិន្នន័យនិងព័ត៌មានទាំងនោះនៅក្នុងកិច្ចការងារប្រចាំថ្ងៃ ដើម្បីផ្តល់សេវាសាធារណៈបម្រើ និងធ្វើប្រតិបត្តិការជាមួយប្រជាពលរដ្ឋនិងធុរកិច្ច។ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលបានបង្កើតដោយច្បាប់នេះនឹងអនុញ្ញាតឱ្យមន្ត្រីសាធារណៈបម្រើសាធារណជន និងកំណត់គោលនយោបាយដោយផ្អែកលើទិន្នន័យព័ត៌មាន និងភស្តុតាង។ ច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថលក៏នឹងបង្កើតផងដែរនូវវិធាន គោលការណ៍ ស្តង់ដា យន្តការ និងបទដ្ឋានគតិយុត្តទាក់ទងទៅនឹងការប្រើប្រាស់និងការគ្រប់គ្រងអត្តសញ្ញាណឌីជីថល។ ការកំណត់អត្តសញ្ញាណឌីជីថល គឺមានសារៈសំខាន់សម្រាប់ដំណើរការនៃរដ្ឋាភិបាលឌីជីថល និងជាសមាសភាពសំខាន់ចំពោះប្រតិបត្តិការនៃប្រព័ន្ធព័ត៌មានឌីជីថលក្នុងយុគសម័យឌីជីថល។ ព្រមជាមួយគ្នានេះ ការកំណត់អត្តសញ្ញាណឌីជីថលនឹងអនុញ្ញាតឱ្យប្រជាពលរដ្ឋប្រើប្រាស់នូវសេវា រដ្ឋាភិបាលឌីជីថលយ៉ាងពេញលេញ និងទទួលបាននូវផលប្រយោជន៍ដែលបានមកពីសង្គម និងសេដ្ឋកិច្ចឌីជីថលប្រកបដោយសមធម៌និងបរិយាបន្ន។
- រៀបចំច្បាប់ស្តីពីបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដើម្បីកំណត់អំពីមុខងាររបស់ស្ថាប័នមានសមត្ថកិច្ច ក្របខណ្ឌអាជ្ញាបណ្ណ ស្តង់ដាសេវា ការប្រកួតប្រជែង សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវានិងអ្នកប្រើប្រាស់ ក្នុងគោលដៅពង្រឹងនិងពង្រីកការគ្រប់គ្រងនិងការ អភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឱ្យបានរីកចម្រើនប្រកបដោយសក្តានុពលខ្លាំងក្លា សម្រាប់គាំទ្រដល់ការកសាងនិងការអភិវឌ្ឍរដ្ឋាភិបាល សេដ្ឋកិច្ចនិងសង្គមឌីជីថល។
- រៀបចំច្បាប់ស្តីពីការការពារទិន្នន័យបុគ្គល ដើម្បីកំណត់អំពីគោលការណ៍ យន្តការ និងនីតិវិធីនៃការការពារទិន្នន័យឯកជនរបស់បុគ្គល ក្នុងគោលដៅការពារសិទ្ធិ សេរីភាព សេចក្តីថ្លៃថ្នូរ និងគុណតម្លៃរបស់បុគ្គល។ ច្បាប់នេះជាឧបករណ៍ចាំបាច់សម្រាប់បង្កើនភាពជឿជាក់ និងទំនុកចិត្តរបស់ប្រជាពលរដ្ឋលើការប្រើប្រាស់សេវារដ្ឋាភិបាលឌីជីថល និងសេវាឌីជីថលផ្សេងៗទៀត។ រូបវន្តបុគ្គលនិងនីតិបុគ្គល ត្រូវតែតម្រូវឱ្យអនុវត្តវិធានការដែលសមស្រប និងចាំបាច់ ដើម្បីធានាថាសិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានគោរព ហើយទិន្នន័យរបស់ពួកគាត់ ក៏ត្រូវបានការពារផងដែរ។
- រៀបចំនិងធ្វើវិសោធនកម្មច្បាប់ស្តីពីទូរគមនាគមន៍និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់ស្តីពីទូរគមនាគមន៍ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិង ការអភិវឌ្ឍវិស័យទូរគមនាគមន៍ ក្នុងការគាំទ្រដល់ការកសាងនិងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចនិងសង្គមឌីជីថល។
- រៀបចំនិងធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់វិទ្យុ ដើម្បីកំណត់អំពីគោលការណ៍ យន្តការ និងនីតិវិធីនៃ ការគ្រប់គ្រង ការបែងចែង និងការប្រើប្រាស់ ក្របខណ្ឌអាជ្ញាបណ្ណ

ការប្រកួតប្រជែង សិទ្ធិនិងការទទួលខុសត្រូវ និងយន្តការ នៃការដោះស្រាយវិវាទ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ធនធានវិសាលគមន៍វិទ្យុឆ្លើយតបទៅនឹងការវិវត្តសេដ្ឋកិច្ចនិងសង្គម។

- រៀបចំបទដ្ឋាននិងសេចក្តីណែនាំស្តីពីហត្ថលេខាឌីជីថល ដើម្បីកំណត់អំពីយន្តការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ ការពិនិត្យអត្តសញ្ញាណឌីជីថល ការបញ្ជាក់អំពីអ្នកផ្ញើនិងអ្នកទទួលឯកសារអេឡិចត្រូនិក ក្នុងគោលដៅពង្រឹងសន្តិសុខនិងសុវត្ថិភាពនៃទំនាក់ទំនងលើប្រព័ន្ធអនឡាញធានាឱ្យបាននូវសុវត្ថិភាព និងភាពទុកចិត្តបាននៃឯកសារអេឡិចត្រូនិក។
- រៀបចំច្បាប់ស្តីពីសេវាប្រៃសណីយ៍ ដើម្បីកំណត់អំពីមុខងាររបស់ស្ថាប័នមានសមត្ថកិច្ច ក្របខណ្ឌអាជ្ញាបណ្ណស្តង់ដាសេវា ការប្រកួតប្រជែង សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវានិង អ្នកប្រើប្រាស់ ក្នុងគោលដៅពង្រឹងនិងពង្រីក ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍និង ជាពិសេសការចែកបញ្ញើគោលដៅចុងក្រោយឱ្យបានរីកចម្រើនប្រកបដោយសក្តានុពលខ្លាំងក្លា សម្រាប់គាំទ្រដល់ការកសាងនិងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចនិងសង្គមឌីជីថល។
- ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលកំណត់អំពីយន្តការនិងនីតិវិធីក្នុងការជំរុញឱ្យស្ថាប័នសាធារណៈបំពេញកាតព្វកិច្ចផ្តល់និងផ្សព្វផ្សាយព័ត៌មានឱ្យបានជាអតិបរមាជូនសាធារណជន ក្នុងគោលដៅធានាឱ្យសាធារណជនគ្រប់រូបអាចទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ និងលើកទឹកចិត្តឱ្យពួកគាត់ចូលរួមក្នុងជីវភាពនយោបាយសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។
- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការត្រួតពិនិត្យលើការបង្ហោះ និងបង្កើតនូវខ្លឹមសារដែលកំណត់អំពីយន្តការពាក់ព័ន្ធនឹងការគ្រប់គ្រងការបង្កើតខ្លឹមសារអនឡាញ សិទ្ធិនិងការទទួលខុសត្រូវ ក្នុងគោលដៅចូលរួមចំណែកក្នុងការរក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ប្រពៃណី និងវប្បធម៌ជាតិដែលធានាបាននូវការការពារសិទ្ធិ និងអត្ថប្រយោជន៍សាធារណៈ។
- រៀបចំស្តង់ដាការងាររដ្ឋបាល ដើម្បីកំណត់អំពីគោលការណ៍ និយាម និងនីតិវិធីសម្រាប់ដំណើរការការងាររដ្ឋបាលរួមរបស់រាជរដ្ឋាភិបាលឱ្យមាន សង្គតិភាព ប្រសិទ្ធភាព និងប្រសិទ្ធផល។ ការរៀបចំស្តង់ដានេះទាមទារឱ្យមានការសិក្សា វិភាគ និងរៀបចំដំណើរការការងារឡើងវិញ(Business Process Re-engineering) ស្របតាមនិន្នាការនិងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល។
- រៀបចំស្តង់ដាបច្ចេកសព្ទឌីជីថលរដ្ឋបាល ដើម្បីកំណត់អំពីទម្រង់នៃការរៀបចំពាក្យ និងអត្ថន័យនៃពាក្យសម្រាប់ប្រើប្រាស់នៅក្នុងការងាររដ្ឋបាល និងស្តង់ដាទិន្នន័យ(ទម្រង់និងអត្ថន័យទិន្នន័យ) សម្រាប់ប្រើប្រាស់នៅពេលអភិវឌ្ឍប្រព័ន្ធព័ត៌មាន។
- រៀបចំស្តង់ដាសេវារដ្ឋាភិបាលឌីជីថល ដើម្បីកំណត់នូវបែបបទនិងទម្រង់រួមមួយដែលមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់មានសុវត្ថិភាព និងផ្តល់ព័ត៌មានគ្រប់គ្រាន់និងពេញលេញសម្រាប់អ្នកប្រើប្រាស់ទូទៅ ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាព គុណភាព និងចីរភាពនៃការអភិវឌ្ឍនិងការប្រើប្រាស់សេវារដ្ឋាភិបាលឌីជីថល។
- រៀបចំស្តង់ដាស្តីពីការគ្រប់គ្រងសេវាឌីជីថល ដើម្បីកំណត់អំពីតម្រូវការ ម៉ូដែល យន្តការ និងនីតិវិធីសម្រាប់ការដឹកនាំនិងគ្រប់គ្រងសេវាឌីជីថល ដើម្បីធានាបាននូវគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាឌីជីថល។
- រៀបចំស្តង់ដាវិស្វកម្មសុសវែរនិងប្រព័ន្ធព័ត៌មាន ដើម្បីកំណត់អំពីបច្ចេកសព្ទ វិធីសាស្ត្រ ឧបករណ៍ និងបច្ចេកទេសសម្រាប់ការរៀបចំផែនការ ការវិភាគ ការតាក់តែង ការអភិវឌ្ឍ ការធ្វើតេស្ត ការដាក់ឱ្យដំណើរការ និងការថែទាំសុសវែរនិងប្រព័ន្ធព័ត៌មានឱ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់។ ស្តង់ដានេះគាំទ្រដល់ការអភិវឌ្ឍ

សុសវែរនិងប្រព័ន្ធព័ត៌មានរបស់រដ្ឋាភិបាល រួមចំណែកក្នុងការជំរុញនិងលើកកម្ពស់ឧស្សាហកម្មសុសវែររបស់ជាតិ។

- ស្តង់ដាសន្តិសុខព័ត៌មានដែលកំណត់អំពីបច្ចេកសព្ទ យន្តការក្របខណ្ឌបច្ចេកទេស ប្រតិបត្តិការ ប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន និងក្រុមអនុវត្តសម្រាប់ការត្រួតពិនិត្យសន្តិសុខព័ត៌មាន ដើម្បីធានាបាននូវសន្តិសុខនិងសុវត្ថិភាពនៃប្រព័ន្ធព័ត៌មាន។
- រៀបចំស្តង់ដាឌីជីថលសម្រាប់ទីក្រុងឆ្លាត ដើម្បីកំណត់អំពីគោលការណ៍ បច្ចេកសព្ទ ក្របខណ្ឌបច្ចេកទេស និងយន្តការសម្រាប់ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងទិន្នន័យ ថ្នាលបច្ចេកវិទ្យា សន្តិសុខ និងសេវាឌីជីថលសម្រាប់ទីក្រុងឆ្លាតដែលមានដូចជាសេវាអភិបាលកិច្ចឆ្លាត សេដ្ឋកិច្ចឆ្លាត ចល័តភាពឆ្លាត បរិស្ថានឆ្លាត ប្រជាជនឆ្លាត និងការរស់នៅឆ្លាត។ ស្តង់ដានេះជួយគាំទ្រដល់ការ អភិវឌ្ឍទីក្រុងឆ្លាតនិងការកសាងរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាពខ្ពស់។
- រៀបចំស្តង់ដាមជ្ឈមណ្ឌលទិន្នន័យ ដើម្បីកំណត់អំពីក្របខណ្ឌបច្ចេកទេស និងយន្តការនៃការរៀបចំនិងស្ថាបនាមជ្ឈមណ្ឌលទិន្នន័យប្រកបដោយ គុណភាព និរន្តរភាព និងសុវត្ថិភាពខ្ពស់។ ក្របខណ្ឌនិងយន្តការទាំងនេះផ្តោតលើការរៀបចំទីតាំង អគារ បន្ទប់ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធម៉ាស៊ីនត្រជាក់ ប្រព័ន្ធសន្តិសុខ និងសម្ភារបរិក្ខារបច្ចេកទេស សម្រាប់មជ្ឈមណ្ឌលទិន្នន័យ ទាំងមជ្ឈមណ្ឌលទិន្នន័យរដ្ឋាភិបាល និងមជ្ឈមណ្ឌលទិន្នន័យវិស័យឯកជន។
- រៀបចំស្តង់ដាបច្ចេកវិទ្យាឌីជីថលសំខាន់ៗ ដើម្បីកំណត់អំពីគោលការណ៍ សេចក្តីណែនាំ បទដ្ឋានបច្ចេកទេស និងយន្តការសម្រាប់ការ អភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ជាពិសេស បច្ចេកវិទ្យាថ្មីៗ ជាអាទិ៍ បច្ចេកវិទ្យាក្លោដ បញ្ញាសិប្បនិម្មិត ទិន្នន័យធំ អ៊ីនធឺណិតនៃវត្ថុ និងប្លុកឆេន ស្របតាមឧត្តមានុវត្តន៍ជាតិនិងអន្តរជាតិ។ ស្តង់ដានេះជាមូលដ្ឋានសម្រាប់ជំរុញការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍ បច្ចេកវិទ្យា ឌីជីថលនិងរដ្ឋាភិបាលឌីជីថល។
- រៀបចំនិម្មាបនកម្មរដ្ឋាភិបាលឌីជីថលរួមមាននិម្មាបនកម្មធុរកិច្ច ទិន្នន័យ សុសវែរ និងបច្ចេកវិទ្យា ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់។

## ៧.៦- យុទ្ធសាស្ត្រ៖ ការធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាលនិងសេវាសាធារណៈ

ការធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាលនិងសេវាសាធារណៈ ចាប់ផ្តើមពីការរៀបចំនិងធ្វើឱ្យប្រសើរឡើងនូវសេវាពីរដ្ឋាភិបាលទៅរដ្ឋាភិបាល(G2G) ឱ្យមានភាពសាមញ្ញ ងាយស្រួល និងបង្កើនប្រសិទ្ធភាពការងាររដ្ឋបាលរបស់រាជរដ្ឋាភិបាល តាមរយៈការលើកកម្ពស់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្លាស់ប្តូររបៀបរបបការងារលើឯកសារក្រដាសទៅជាការងារលើឯកសារអេឡិចត្រូនិក និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសការងាររបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ បន្ថែមលើនេះ ការធ្វើបរិវត្តកម្មឌីជីថល គឺត្រូវរៀបចំនិងធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈពីរដ្ឋាភិបាលដើម្បីប្រជាពលរដ្ឋ (G4C) ដែលតភ្ជាប់ប្រព័ន្ធព័ត៌មានឌីជីថលក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព សមភាព គុណភាព និងតម្លាភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងកាត់បន្ថយការចំណាយថវិកានិងពេលវេលា។ ចុងក្រោយ ការធ្វើបរិវត្តកម្មឌីជីថលត្រូវរៀបចំនិងធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈពីរដ្ឋាភិបាលទៅធុរកិច្ច(G2B) សំដៅកាត់បន្ថយការចំណាយ ជំរុញការចូលរួម លើកកម្ពស់តម្លាភាព ផ្តល់ភាពងាយស្រួល និងបង្កើនប្រសិទ្ធភាពសេវាសាធារណៈជូនវិស័យឯកជន។ សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះមានដូចខាងក្រោម៖

- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវថ្នាលសហការកិច្ចការរដ្ឋបាលដើម្បីសម្រួលដល់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការការងារ តាមរយៈការប្រើប្រាស់ប្រព័ន្ធគមនាគមន៍ប្រមូលផ្តុំ(អ៊ីមែល ឈែត វីដេអូសន្និសីទ) ប្រព័ន្ធគ្រប់គ្រងក្រុមការងារ គម្រោង និងលំហូរការងារ ព្រមទាំងប្រព័ន្ធចែករំលែកឯកសារ ព័ត៌មាន និងចំណេះដឹង។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងរួមរបស់រដ្ឋាភិបាលដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងឯកសារអេឡិចត្រូនិក និងប្រព័ន្ធផ្តល់សច្ចានុម័តអេឡិចត្រូនិក សំដៅបង្កើនប្រសិទ្ធភាព និងតម្លាភាពការងាររដ្ឋបាលរបស់រាជរដ្ឋាភិបាល កាត់បន្ថយការចំណាយ និងលុបបំបាត់នូវការបង្កើតប្រព័ន្ធព័ត៌មានដដែលៗច្រើនដងដែលមានមុខងារជាន់គ្នា។
- រៀបចំនិងបំពាក់ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ឌីជីថល សុសវែរ និងប្រព័ន្ធព័ត៌មានចាំបាច់នានាដើម្បីជួយសម្រួល និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- រៀបចំថ្នាលទិន្នន័យរូបភាពពីផ្កាយរណប ដ្រូន(Drone) និងឧបករណ៍ផ្សេងៗ ដើម្បីចែករំលែកទិន្នន័យជូនក្រសួងស្ថាប័ន សម្រាប់ទាញយក វិភាគ និងធ្វើចំណាត់ថ្នាក់ទិន្នន័យ លើវិស័យសំខាន់ៗ ជាអាទិ៍ កសិកម្ម ធនធានទឹក បរិស្ថាន ការប្រើប្រាស់ដីធ្លី សំណង់ នគរូបនីយកម្ម និងទូរគមនាគមន៍ សំដៅបង្កលក្ខណៈងាយស្រួលក្នុងការរៀបចំគោលនយោបាយ និងអនុវត្តសកម្មភាពការងារ។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងប្រព័ន្ធគ្រប់គ្រងព័ត៌មានភូមិសាស្ត្រជាតិ (National Geographic Information System) ដើម្បីពង្រឹងប្រសិទ្ធភាពនៃការប្រមូល ការរក្សាទុក ការប្រើប្រាស់ ការចែករំលែក និងការគ្រប់គ្រងទិន្នន័យភូមិសាស្ត្រ សម្រាប់សម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមនៅកម្ពុជា។
- រៀបចំមូលដ្ឋានទិន្នន័យហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ(National Infrastructure Management Information System) ដើម្បីគ្រប់គ្រង តាមដាន និងវាយតម្លៃលើប្រសិទ្ធភាព និងតម្រូវការនៃហេដ្ឋារចនាសម្ព័ន្ធជាតិ ជាអាទិ៍បណ្តាញផ្លូវថ្នល់ ផ្លូវទឹក អគ្គិសនី ទឹកស្អាត ទូរគមនាគមន៍ ធារាសាស្ត្រ ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធជនបទ និងបណ្តាញហេដ្ឋារចនាសម្ព័ន្ធជាតិផ្សេងៗ។ល។
- រៀបចំប្រព័ន្ធគ្រប់គ្រងចំណេះដឹង(Knowledge Management System) ដើម្បីបង្កើត រក្សាទុក ផ្ទេរឬចែករំលែកចំណេះដឹងដល់ក្រសួងស្ថាប័ន គ្រឹះស្ថានសាធារណៈ វិស័យឯកជន និងប្រជាពលរដ្ឋ។
- រៀបចំថ្នាលសេវាច្រកចេញចូលតែមួយ ដើម្បីផ្តល់សេវាសាធារណៈរបស់គ្រប់ក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាង១ ៥០០សេវា ព្រមទាំងការប្រមូលមតិយោបល់ និងទំនាក់ទំនងជាមួយប្រជាពលរដ្ឋតាមប្រព័ន្ធឌីជីថលនិងសេវាទូរសព្ទ។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្រានុកូលដ្ឋាន ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការធ្វើសមកាលកម្ម សម្រាប់ការចុះបញ្ជីសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្តសញ្ញាណកម្ម ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងអត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ លិខិតឆ្លងដែន និងប័ណ្ណព្រំដែន។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានជនអន្តោប្រវេសន៍ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានទិដ្ឋាការ ដើម្បីពង្រឹងប្រសិទ្ធភាពនៃ លំហូរចេញចូលជនអន្តោប្រវេសន៍ និងគ្រប់គ្រងការងារផ្តល់ទិដ្ឋាការជូនជនបរទេស។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានស្នាក់នៅនិងគ្រួសារ ដើម្បីធានាប្រសិទ្ធភាពដល់ការងារចុះបញ្ជី ការរក្សាទុក និងស្វែងរកទិន្នន័យ និងការផ្តល់សៀវភៅស្នាក់នៅនិងគ្រួសារជូនប្រជាពលរដ្ឋ។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអចលនវត្ថុ ដើម្បីគ្រប់គ្រងនិងធ្វើបច្ចុប្បន្នកម្មព័ត៌មាន និងកំណត់ទិសដៅកែលម្អ សេវាគ្រប់គ្រងកម្មសិទ្ធិដីធ្លីនិងអចលនវត្ថុជូនប្រជាពលរដ្ឋ។

- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានយានយន្ត ដើម្បីជានាប្រសិទ្ធភាពនៃការចុះបញ្ជីយានយន្ត ការរក្សាទុកនិង ស្វែងរក ទិន្នន័យ និងការផ្តល់បណ្ណសម្គាល់យានយន្ត។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូរសព្ទសេវាបន្ទាន់ជូនប្រជាពលរដ្ឋ ដូចជាសន្តិសុខ ចរាចរណ៍ អគ្គិភ័យ និង សង្គ្រោះបន្ទាន់ជាដើម។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ដើម្បីគ្រប់គ្រង ធ្វើបច្ចុប្បន្នកម្ម និងផ្តល់ព័ត៌មានស្តីពីការអប់រំជូនប្រជាពលរដ្ឋ និងកំណត់ទិសដៅសម្រាប់កែលម្អគុណភាពសេវាអប់រំ។
- រៀបចំនិងកែលម្អឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានទីផ្សារការងារនិងសេវាជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋ ដើម្បីផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារនៅមួយកន្លែងងាយស្រួល និងប្រកបដោយគុណភាព និង ប្រសិទ្ធភាពខ្ពស់ដល់អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នករៀបចំគោលនយោបាយ និងផែនការ និងសាធារណជនទូទៅ។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលរួមនិងគ្រប់គ្រងសេវា តាមរយៈការបង្កើតថ្នាលសុខាភិបាលឌីជីថលនិងរៀបចំអត្តសញ្ញាណនិងកំណត់ត្រាអ្នកជំងឺឌីជីថល សំដៅពង្រឹងប្រសិទ្ធភាពនិងសុវត្ថិភាពនៃការប្រមូល ការរក្សាទុក ការប្រើប្រាស់ និងការគ្រប់គ្រងទិន្នន័យសុខាភិបាល សម្រាប់គាំទ្រដល់ការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ការសម្រេចចិត្តក្នុងវិស័យសុខាភិបាលនិងសុខភាពសាធារណៈ ការគ្រប់គ្រងអ្នកជំងឺនិងបរិក្ខារសុខាភិបាល ការស្រាវជ្រាវនិងការរៀបចំផែនការសុខាភិបាល។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានទេសចរណ៍រួម ដើម្បីប្រមូល រក្សាទុក គ្រប់គ្រងនិងផ្តល់ព័ត៌មានពាក់ព័ន្ធនឹង វិស័យទេសចរណ៍ជូនប្រជាពលរដ្ឋនិងភ្ញៀវទេសចរអន្តរជាតិ ដែលមានជាអាទិ៍តំបន់និងគោលដៅទេសចរណ៍ ផែនទីទេសចរណ៍ឌីជីថល ផលិតផលនិងសេវាទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ វប្បធម៌ អាកាសធាតុ និងស្ថិតិទេសចរណ៍។
- រៀបចំនិងកែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មានកសិកម្ម ដូចជាវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម បច្ចេកទេសផលិតកម្មកសិកម្ម ស្ថានភាពដំណាំ អាកាសធាតុ ទីផ្សារ និងព័ត៌មានចាំបាច់ផ្សេងទៀត សំដៅរួមចំណែកជួយបង្កើនទិន្នផលកសិកម្មប្រកបដោយគុណភាពនិងសុវត្ថិភាព ក៏ដូចជាជួយសម្រួលដល់ការវិនិយោគ ការស្វែងរកទីផ្សារ និង ការនាំចេញផលិតផលកសិកម្ម។
- រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រោះមហន្តរាយ និងប្រព័ន្ធផ្តល់ដំណឹងជាមុន ជូនប្រជាពលរដ្ឋ ពាក់ព័ន្ធនឹង គ្រោះមហន្តរាយ គ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ដើម្បីបង្កើតប្រសិទ្ធភាពនៃការគ្រប់គ្រង និងការឆ្លើយតបនឹងគ្រោះមហន្តរាយ។
- ជំរុញនិងរៀបចំប្រព័ន្ធអេកូឡូស៊ីប្រៃសណីយ៍ឌីជីថល តាមរយៈការបង្កើតនិងការប្រើប្រាស់ថ្នាលប្រៃសណីយ៍ឌីជីថល និងច្រកទ្វារ ប្រៃសណីយ៍ជាតិរួមដើម្បីគាំទ្រដល់ការផ្តល់សេវាប្រៃសណីយ៍ជូនប្រជាពលរដ្ឋ ព្រមទាំងការគ្រប់គ្រង ការប្រើប្រាស់ ការចែករំលែក និងការតាមដានទិន្នន័យវិស័យប្រៃសណីយ៍ ប្រកបដោយសុវត្ថិភាព តម្លាភាព និងប្រសិទ្ធភាព។
- ធ្វើទំនើបកម្មការគ្រប់គ្រងសេវាប្រៃសណីយ៍ ដោយរៀបចំនិងកែលម្អសេវាប្រៃសណីយ៍មួយចំនួនដែលមានស្រាប់ឱ្យទៅជាសេវា ប្រៃសណីយ៍ឌីជីថល និងពង្រឹងការគ្រប់គ្រងការចែកបញ្ញើគោលដៅចុងក្រោយ ដោយរួមបញ្ចូលនូវការអភិវឌ្ឍប្រព័ន្ធអាសយដ្ឋាន ប្រៃសណីយ៍ឌីជីថលជាតិ (National Digital Postal Addressing System) និងលេខកូដប្រៃសណីយ៍ឌីជីថលជាតិសម្រាប់តំបន់ចែកចាយ ឬលេខកូដផែនទីឌីជីថលជាតិ (National Digital Postal Code or National Digital Map Code)។

- រៀបចំនិងកែលម្អថ្នាលចុះបញ្ជីអាជីវកម្មរួម ដើម្បីផ្ដល់សេវាច្រកចេញចូលតែមួយដល់ធុរកិច្ចលើការងារចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីគម្រោង វិនិយោគនិងទិន្នន័យសម្រាប់អ្នកវិនិយោគ ចុះបញ្ជីពន្ធដារ ចុះបញ្ជិកាកម្មករនិយោជិត ស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតពាក់ព័ន្ធ សំដៅសម្រួលដល់ការបង្កើតនិងការធ្វើធុរកិច្ច។
- រៀបចំប្រព័ន្ធគ្រប់គ្រងលទ្ធកម្មអេឡិចត្រូនិក(e-Procurement) ដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព ភាពជឿជាក់ និងការប្រកួតប្រជែង ដោយកាត់បន្ថយដំណើរការ និងពេលវេលានៃកិច្ចលទ្ធកម្ម បង្កើតយន្តការនៃការត្រួតពិនិត្យ សវនកម្ម និងការប្ដឹងតវ៉ា សំដៅជំរុញ និងផ្ដល់ឱកាសសម្រាប់ធុរកិច្ចចូលរួមក្នុងគម្រោងរបស់រាជរដ្ឋាភិបាល។
- រៀបចំនិងកែលម្អប្រព័ន្ធសេវាពន្ធដារឌីជីថល ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងមានភាពងាយស្រួល សំដៅសម្រួលដល់ការប្រកាសពន្ធ ទូទាត់ បង្វិលសង ទទួលនិងដោះស្រាយបណ្ដឹងនិងការតវ៉ា ព្រមទាំងអាចកាត់បន្ថយបន្ទុកចំណាយរបស់ធុរកិច្ចក្នុងការបំពេញអនុលោមភាព និងសម្រួលដល់ការបំពេញអនុលោមភាពរបស់អ្នកជាប់អាករលើតម្លៃបន្ថែមនិងពន្ធផ្សេងៗទៀត ដែលជាក្រុមហ៊ុនបរទេសដែលរកចំណូលបានពីអ្នកប្រើប្រាស់នៅកម្ពុជា។
- រៀបចំនិងកែលម្អប្រព័ន្ធបញ្ជរតែមួយជាតិ(National Single Window) សំដៅបង្កើនតម្លាភាព ប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងកិច្ចសម្រួលពាណិជ្ជកម្ម និងជំរុញការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងសកលលោក។

## ៧.៧- យុទ្ធសាស្ត្រ៖ ការកសាងមូលធនមនុស្សឌីជីថល

ការកសាងមូលធនមនុស្សឌីជីថល ចាប់ផ្ដើមពីការកសាងសមត្ថភាពដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ក្រសួងស្ថាប័ន ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលសម្រាប់បម្រើឱ្យការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព គុណភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ បន្ថែមលើនេះ ត្រូវកសាងធនធានមនុស្សជំនាញបច្ចេកវិទ្យាឌីជីថល សំដៅជំរុញការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព គុណភាព សុវត្ថិភាព និងបរិយាបន្ន។ លើសពីនេះការលើកកម្ពស់អក្ខរកម្មឌីជីថលសម្រាប់សិស្ស និស្សិត និងប្រជាពលរដ្ឋ ទាំងបុរសនិងស្ត្រី ប្រកបដោយបរិយាបន្ន គឺជាភាពចាំបាច់សំដៅជំរុញការទទួលយក និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល កាត់បន្ថយគម្លាតឌីជីថល បង្កើនភាពប្រកួតប្រជែង និងជំរុញការប្រើប្រាស់សេវារដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព។ សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះមានដូចខាងក្រោម៖

- រៀបចំយន្តការនៃការវាស់វែងកម្រិតសមត្ថភាព ការទទួលស្គាល់ជំនាញបច្ចេកទេស និងយន្តការ គ្រប់គ្រង កៀរគរ និងរក្សាទុកមូលធនមនុស្សជំនាញឌីជីថល ក្នុងវិស័យសាធារណៈ ដើម្បីបម្រើឱ្យបរិវត្តកម្មឌីជីថលនិងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។
- ជំរុញការបណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំឌីជីថល ដល់ថ្នាក់ដឹកនាំទាំងបុរសនិងស្ត្រីនៅតាម ក្រសួងស្ថាប័ននានារបស់រដ្ឋ ដើម្បីលើកកម្ពស់សមត្ថភាពអភិបាលកិច្ចឌីជីថលសម្រាប់គាំទ្រដល់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។
- ជំរុញការបណ្ដុះបណ្ដាលអក្ខរកម្មឌីជីថល និងជំនាញឌីជីថលចាំបាច់នានាដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការនិងបុគ្គលិកក្រសួងស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ជាពិសេស មន្ត្រីបង្គោលបច្ចេកវិទ្យា ដើម្បីលើកកម្ពស់សមត្ថភាពឌីជីថល សម្រាប់បម្រើដល់ការអភិវឌ្ឍ ការគ្រប់គ្រង ការប្រើប្រាស់ និងការផ្ដល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងប្រសិទ្ធផល។
- ជំរុញការរៀបចំនិងកែលម្អកម្មវិធីសិក្សា ដើម្បីលើកកម្ពស់អក្ខរកម្មឌីជីថលសម្រាប់សិស្សនិស្សិត គ្រប់កម្រិតសិក្សា និងបណ្ដុះបណ្ដាល ពីកម្រិតចំណេះដឹងទូទៅ ជំនាញវិជ្ជាជីវៈ និងឧត្តមសិក្សា។

- លើកកម្ពស់អត្ថរកម្មនិងវិធីសាស្ត្របង្រៀនឌីជីថលសម្រាប់គ្រូបង្រៀនគ្រប់កម្រិតសិក្សានិងបណ្ដុះបណ្ដាល។
- ជំរុញការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអប់រំចាំបាច់ ដើម្បីគាំទ្រដល់ការអប់រំនិងការបណ្ដុះបណ្ដាលអត្ថរកម្មឌីជីថលដល់ស្ថាប័នអប់រំគ្រប់កម្រិតនិងបណ្ដុះបណ្ដាល។
- រៀបចំកម្មវិធីបណ្ដុះបណ្ដាល កម្មវិធីបញ្ជ្រាបការយល់ដឹង និងការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយនានា អំពីចំណេះដឹងមូលដ្ឋានបច្ចេកវិទ្យាឌីជីថល និងការប្រើប្រាស់សេវាសាធារណៈរបស់រដ្ឋាភិបាលឌីជីថល ដោយសហការជាមួយតួអង្គពាក់ព័ន្ធ ពិសេស ស្ថាប័នផ្សព្វផ្សាយនិងអាជ្ញាធរមូលដ្ឋាន។
- ជំរុញរៀបចំថ្នាលអប់រំនិងបណ្ដុះបណ្ដាលជាតិរួម ដើម្បីផ្ដល់មាតិកាអប់រំសម្រាប់កាត់បន្ថយគម្លាតឌីជីថលក្នុងចំណោមប្រជាពលរដ្ឋ ជាពិសេស តាមតំបន់ជនបទដាច់ស្រយាល តាមរយៈប្រព័ន្ធអនឡាញនិងជំរុញការសិក្សាពេញមួយជីវិត។
- រៀបចំក្របខណ្ឌសមត្ថភាពឌីជីថលជាតិ ដែលកំណត់ស្តង់ដាគុណវុឌ្ឍិ សមត្ថភាពនិងជំនាញបច្ចេកវិទ្យាឌីជីថលសំខាន់ៗ ដើម្បីឆ្លើយតបនឹងតម្រូវការការងារទាំងក្របខណ្ឌនៃរដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចនិងសង្គមឌីជីថល និងឧស្សាហកម្ម៤.០។
- ពង្រឹងនិងពង្រីកស្ថាប័នបណ្ដុះបណ្ដាលជំនាញបច្ចេកវិទ្យាឌីជីថល តាមរយៈការរៀបចំកម្មវិធីសិក្សា ការរៀបចំមន្ទីរពិសោធន៍ និងការបណ្ដុះបណ្ដាលគ្រូបង្គោល ដែលរួមមាន ការពង្រឹងសមត្ថភាពជំនាញនិងវិធីសាស្ត្របង្រៀនបែបឌីជីថល។
- រៀបចំកម្មវិធីតម្រង់ទិស ផ្សព្វផ្សាយ និងលើកទឹកចិត្ត ដើម្បីជំរុញឱ្យយុវជន យុវនារី និងស្ត្រី ជ្រើសរើសជំនាញបច្ចេកវិទ្យាឌីជីថល។
- ជំរុញការបណ្ដុះបណ្ដាលធនធានជំនាញឌីជីថលសំខាន់ៗ ជាអាទិ៍ ការអភិវឌ្ឍសុសវែរ ឯកទេសទូរគមនាគមន៍ និងបណ្ដាញ បញ្ញាសិប្បនិម្មិត វិទ្យាសាស្ត្រទិន្នន័យ និម្មាបនកម្មប្រព័ន្ធព័ត៌មាន និងជាពិសេស សន្តិសុខឌីជីថលស្របតាមក្របខណ្ឌសមត្ថភាពឌីជីថលជាតិនិងអន្តរជាតិ។

## ៧.៨- យុទ្ធសាស្ត្រ៖ ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល

ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល គឺដើម្បីបង្កើនសមត្ថភាព ប្រសិទ្ធភាព និងប្រសិទ្ធផលនៃបរិវត្តកម្មឌីជីថល និងជានាការប្រកួតប្រជែងឌីជីថលក្នុងតំបន់។ សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះមានដូចខាងក្រោម៖

- ជំរុញសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល តាមរយៈការរៀបចំផែនការមេនិងយន្តការនៃការលើកទឹកចិត្តនិងទាក់ទាញអ្នកស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលទាំងក្នុងនិងក្រៅប្រទេសសំដៅជំរុញសកម្មភាពនិងភាពជាដៃគូក្នុងការស្រាវជ្រាវ ការអភិវឌ្ឍ និងការផ្លាស់ប្ដូរព័ត៌មាននិងចំណេះដឹង នៅតាមគ្រឹះស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ និងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល។
- ជំរុញការផ្ទេរបច្ចេកវិទ្យាឌីជីថល ដែលបានពីការស្រាវជ្រាវដល់វិស័យសាធារណៈនិងឯកជន។
- ជំរុញសហគ្រិននិងនវានុវត្តន៍ឌីជីថល និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន ដើម្បីលើកកម្ពស់នវានុវត្តន៍ជាតិ។

## ៧.៩- យុទ្ធសាស្ត្រ៖ ការរៀបចំកិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល

ការរៀបចំកិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល គឺដើម្បីជំរុញការរៀបចំយន្តការសហការនិងសម្របសម្រួលរវាងរដ្ឋាភិបាល និងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល សំដៅលើកកម្ពស់ការចូលរួមពីវិស័យឯកជនលើការកសាង

និងអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងភាពជឿទុកចិត្ត។ សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះមានដូចខាងក្រោម៖

- រៀបចំវេទិកាវាងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលនិងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល សំដៅជំរុញភាពជាដៃគូរវាងរដ្ឋនិងឯកជនលើការងារវិនិយោគ ការផ្តល់សេវា និងដំណោះស្រាយបច្ចេកទេសសម្រាប់រដ្ឋាភិបាលឌីជីថល។
- ជំរុញការផ្សព្វផ្សាយ សម្របសម្រួល និងលើកទឹកចិត្តក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ក្នុងការចូលរួមអភិវឌ្ឍ និងផ្គត់ផ្គង់ការរៀបចំប្រព័ន្ធ និងសេវាបច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញបរិវត្តកម្មឌីជីថល និងការអភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាលឌីជីថល។
- ជំរុញកិច្ចសហការជាមួយប្រតិបត្តិករវិស័យប្រៃសណីយ៍និងវិស័យផ្សេងទៀត ក្នុងគោលដៅលើកកម្ពស់ការចូលរួមរបស់វិស័យឯកជនក្នុង ដំណើរការផ្តល់សេវារដ្ឋាភិបាលឌីជីថល ជាអាទិ៍ ការផ្តល់ជំនួយក្នុងការបំពេញពាក្យស្នើសុំសេវា ការបង់កម្រៃសេវា ការដឹកជញ្ជូន និងការសម្របសម្រួលជាមួយក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ។

## ៧.១០- យុទ្ធសាស្ត្រ៖ ការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល

ការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល គឺការរៀបចំនិងពង្រឹងការអនុវត្តយន្តការលើកទឹកចិត្ត និងពង្រីកឱកាសទីផ្សារសម្រាប់ធុរកិច្ចថ្មីឌីជីថលជាកិច្ចការចាំបាច់ សំដៅចូលរួមបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពបច្ចេកវិទ្យា នវានុវត្តន៍ និងធុរកិច្ចថ្មីឌីជីថល ប្រកបដោយសក្តានុពលនិងអំណោយផលដល់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ សកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនេះមានដូចខាងក្រោម៖

- បង្កើតនិងពង្រឹងសេវាគាំទ្រនិងលើកទឹកចិត្តការបង្កើតធុរកិច្ចថ្មីឌីជីថល ទាំងផ្នែកបច្ចេកទេស និងទាំងផ្នែកហិរញ្ញវត្ថុ ពិសេស លើការបណ្តុះបណ្តាល ការការពារកម្មសិទ្ធិបញ្ញា ការបង្កើតទំនាក់ទំនងជាមួយបណ្តាញអ្នកវិនិយោគនិងការគាំទ្របច្ចេកទេសនានា។
- ពង្រីកឱកាសទីផ្សារសម្រាប់ធុរកិច្ចថ្មីឌីជីថល តាមរយៈការជំរុញភាពជាដៃគូរវាងធុរកិច្ចថ្មីឌីជីថលនិងសហគ្រាសគ្រប់ទំហំនិងគ្រប់វិស័យ ដើម្បីសហការអភិវឌ្ឍផលិតផលឬសេវាឌីជីថលប្រកបដោយនវានុវត្តន៍ខ្ពស់ ដែលធ្វើឱ្យប្រសើរឡើងនូវដំណើរការអាជីវកម្មនិងផលិតកម្មប្រកបដោយបរិយាបន្ន។

*រូបភាពទី៦ : រូបភាពរួមនៃការរៀបចំគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥*



# ៨- យន្តការដឹកនាំ សម្របសម្រួល អនុវត្ត តាមដាននិងវាយតម្លៃ

## ៨.១- យន្តការដឹកនាំ សម្របសម្រួល និងអនុវត្ត

គោលនយោបាយរដ្ឋាភិបាលឌីជីថល ជាឧបករណ៍សម្រាប់ជំរុញបរិវត្តកម្មឌីជីថលក្នុងរដ្ឋាភិបាល។ ការអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យស្របតាមចក្ខុវិស័យ គោលបំណង និងគោលដៅ ទាមទារឱ្យមានការតាំងចិត្តខ្ពស់និងមានការចូលរួមពីសំណាក់ក្រសួងស្ថាប័ន អង្គភាពគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធទាំងអស់។ រាជរដ្ឋាភិបាលបានពិនិត្យឃើញនូវភាពចាំបាច់នៃការរៀបចំស្ថាប័នដឹកនាំ សម្របសម្រួល និងអនុវត្តគោលនយោបាយ ដែលរួមមាន *១*- បង្កើតគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលសម្រាប់ដឹកនាំ សម្របសម្រួល អនុវត្ត តាមដាន និងវាយតម្លៃក្នុង គោលនយោបាយនេះ *២*- កំណត់តួនាទីច្បាស់លាស់របស់ក្រសួងជំនាញ ដើម្បីទទួលបន្ទុកគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថលរួម ដែលអាចបម្រើសេវានិងទ្រទ្រង់ដល់ការអភិវឌ្ឍប្រព័ន្ធឌីជីថលនៅតាមក្រសួងស្ថាប័នដទៃទៀតក្នុងរដ្ឋាភិបាលទាំងមូល និង *៣*- បង្កើតអង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថលក្រោមក្រសួងស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសម្រាប់ជំរុញបរិវត្តកម្មឌីជីថលរបស់ខ្លួន។ តួអង្គទាំងបីនេះបំពេញកិច្ចការប្រទាក់ក្រឡាគ្នានិងមានអន្តរទំនាក់ទំនងក្នុងការជំរុញការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។

<u>**គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល**</u>

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ជាសេនាធិការនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល ទទួលបន្ទុកការងារជំរុញបរិវត្តកម្មឌីជីថលរបស់រាជរដ្ឋាភិបាលលើទិដ្ឋភាពបច្ចេកទេសនិងគោលនយោបាយ។ គណៈកម្មាធិការនេះដឹកនាំដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងមានសមាសភាពចូលរួមជាតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ។ គណៈកម្មាធិការនេះមានតួនាទីដឹកនាំ សម្របសម្រួល ជំរុញ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ វិធានការ ស្តង់ដាបច្ចេកទេស និងផែនការសកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ ក្រៅពីនេះ គណៈកម្មាធិការនេះក៏មានតួនាទីចម្បងក្នុងការសម្របសម្រួល ធានាការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធឌីជីថល និងជំរុញការប្រើប្រាស់ប្រព័ន្ធរួមរបស់រាជរដ្ឋាភិបាល។ គណៈកម្មាធិការមានភារកិច្ចជំរុញការរៀបចំផែនការបរិវត្តកម្មឌីជីថលរយៈពេល៣ឆ្នាំតាមក្រសួងស្ថាប័ននីមួយៗ ហើយជារៀងរាល់ឆ្នាំ គណៈកម្មាធិការទទួលគម្រោងដែលស្នើដោយក្រសួងស្ថាប័ន ដើម្បីត្រួតពិនិត្យនិងវាយតម្លៃលើលក្ខណៈបច្ចេកទេសនិងហិរញ្ញវត្ថុ និងស្នើសុំការឯកភាពពីក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល។

ដើម្បីធានាបាននូវការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលឱ្យបានជោគជ័យ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល និងគណៈកម្មាធិការសន្តិសុខឌីជីថល ត្រូវមានអន្តរទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធ និងបំពេញគ្នាទៅវិញទៅមកលើគ្រប់វិស័យ។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលត្រូវអនុវត្តយន្តការពិគ្រោះយោបល់ជាមួយតួអង្គពាក់ព័ន្ធ លើផែនការនិងគម្រោងពាក់ព័ន្ធនឹងរដ្ឋាភិបាលឌីជីថល។ រាជរដ្ឋាភិបាលនឹងធ្វើវិភាជន៍កញ្ចប់ថវិកាជាតិ និងកៀរគរថវិកាពីប្រភពផ្សេងទៀត សម្រាប់អនុវត្តគម្រោងអាទិភាព ដែលគណៈកម្មាធិការរដ្ឋាភិបាលឌីជីថលបានសិក្សានិងវាយតម្លៃលក្ខណៈបច្ចេកទេសនិងហិរញ្ញវត្ថុ និងទទួលការឯកភាពគម្រោងពីក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថលរួចរាល់។

ក្រុមការងារបច្ចេកទេសអន្តរក្រសួងត្រូវដឹកនាំដោយតំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងមានសមាសភាពចូលរួមដោយមន្ត្រីជាន់ខ្ពស់ និងមន្ត្រីបច្ចេកទេសនៃអង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថលតាមក្រសួងស្ថាប័ន ដោយគិតគូរអំពីសមាសភាពចូលរួមរបស់ស្ត្រីផងដែរ។ ក្រុមការងារបច្ចេកទេសអន្តរក្រសួង មានតួនាទីសម្របសម្រួលការងារបច្ចេកទេសនិងហិរញ្ញវត្ថុ ការអនុវត្តនិងវាយតម្លៃគម្រោង និងការងារសន្តិសុខព័ត៌មាននៅក្នុងក្រសួងស្ថាប័ន។

ក្នុងករណីចាំបាច់ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលអាចបង្កើតក្រុមការងារបច្ចេកទេសផ្សេងៗ និងមានសិទ្ធិជ្រើសរើសនិងតែងតាំងទីប្រឹក្សាសម្រាប់ផ្តល់ប្រឹក្សានិងជួយការងារបច្ចេកទេសពាក់ព័ន្ធនឹងគម្រោងរដ្ឋាភិបាលឌីជីថល។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល មានលេខាធិការដ្ឋានមួយជាជំនួយការលើការងាររដ្ឋបាល នីតិកម្ម ផែនការ ការបណ្តុះបណ្តាល កិច្ចសហប្រតិបត្តិការ ការតាមដាននិងវាយតម្លៃ និងការពិនិត្យលើលក្ខណៈបច្ចេកទេសនៃគម្រោងរដ្ឋាភិបាលឌីជីថលដែលអនុវត្តដោយក្រសួងស្ថាប័ន និងការងារពាក់ព័ន្ធដទៃទៀត។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលនឹងរៀបចំសេចក្តីណែនាំស្តីពីការបង្កើតអង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថលនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) សហការធ្វើសុខដុមនីយកម្មបរិវត្តកម្មឌីជីថលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីពង្រីកនិងពង្រឹងការផ្តល់សេវាសាធារណៈឌីជីថល ឱ្យមានភាពប្រទាក់ក្រឡា ដំណើរការរលូន និងប្រសិទ្ធភាពខ្ពស់។

**<u>តួនាទីក្រសួងជំនាញ</u>**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាក្រសួងជំនាញ ទទួលបន្ទុកអភិវឌ្ឍនិងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន រួមមានហេដ្ឋារចនាសម្ព័ន្ធទូរសព្ទចល័តនិងអចល័ត ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិត ហេដ្ឋារចនាសម្ព័ន្ធបណ្តាញរដ្ឋាភិបាលឌីជីថល មជ្ឈមណ្ឌលទិន្នន័យនិងប្រព័ន្ធក្លោដ ហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល និងមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខជាតិ និងផ្តល់សេវាប្រព័ន្ធព័ត៌មានឌីជីថលរួមទៅកាន់ក្រសួងស្ថាប័ននានា មានជាអាទិ៍ ប្រព័ន្ធអ៊ីមែលរួម វិបផតថលជាតិ ប្រព័ន្ធសហការរួម ប្រព័ន្ធផ្ញើសារ ប្រព័ន្ធឯកសារអេឡិចត្រូនិកនិងប្រព័ន្ធផ្តល់សច្ចានុម័តអេឡិចត្រូនិក។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធនិងសេវាខាងលើ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានតួនាទីក្នុងការរៀបចំស្តង់ដា ការធានានិរន្តរភាព ការផ្តល់ការប្រឹក្សាយោបល់និងគាំទ្រដល់ក្រសួងស្ថាប័ន និងការបណ្តុះបណ្តាលជំនាញឌីជីថលសម្រាប់មន្ត្រីរាជការ ជាពិសេស មន្ត្រីជាន់ខ្ពស់និងមន្ត្រីបង្គោលបច្ចេកទេសក្រសួងស្ថាប័នក្នុងគោលដៅជំរុញបរិវត្តកម្មឌីជីថល។

**<u>អង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថល</u>**

ក្រសួងស្ថាប័ននីមួយៗ ត្រូវបង្កើតអង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថល ដែលមានតួនាទីនិងរចនាសម្ព័ន្ធច្បាស់លាស់ក្នុងការជំរុញបរិវត្តកម្មឌីជីថលនៅតាមក្រសួងស្ថាប័នរបស់ខ្លួន ដើម្បីរួមចំណែកដល់ការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល។ នៅថ្នាក់ក្រោមជាតិ ត្រូវមានអង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថលរាជធានីខេត្ត ដែលមានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍រាជធានីខេត្ត ជាសេនាធិការបច្ចេកទេសឱ្យគណៈអភិបាលរាជធានីខេត្ត ក្នុងការសម្របសម្រួលការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល។

**<u>អភិក្រម</u>**

ការអនុវត្តគម្រោងរដ្ឋាភិបាលឌីជីថលអាចមានលក្ខណៈបែបវិមជ្ឈការ ប៉ុន្តែត្រូវគោរពតាមគោលការណ៍ ពិធីសារស្តង់ដារួម និងលក្ខណៈបច្ចេកទេស ដែលកំណត់ដោយគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ដើម្បីឱ្យការអនុវត្តគម្រោងទាំងអស់ ដើម្បីឆ្លើយតបទៅនឹងគោលដៅរួមរបស់រដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព។ ក្នុងន័យនេះ តួអង្គនៃរដ្ឋាភិបាលឌីជីថលនីមួយៗអាចចូលរួមរៀបចំ បង្កើត គ្រប់គ្រង និងអនុវត្តគម្រោងរដ្ឋាភិបាលឌីជីថលដំណាលគ្នា និងដាច់ដោយឡែកពីគ្នា ស្របតាមផែនការនិងទិសដៅនៃរដ្ឋាភិបាលឌីជីថល។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលត្រូវគិតគូរពីការកសាងហេដ្ឋារចនាសម្ព័ន្ធក្លោដក្នុងក្របខណ្ឌរដ្ឋាភិបាលឌីជីថល ក្នុងទម្រង់ពាក់កណ្តាលវិមជ្ឈការ (Hybrid) ដែលការកសាងនេះត្រូវគិតគូរលើប្រសិទ្ធភាពនៃការគ្រប់គ្រង, ការប្រើប្រាស់ធនធាន, ការវិនិយោគ, សន្តិសុខឌីជីថល, និងធនធាន

មនុស្សសម្រាប់គ្រប់គ្រង ព្រមទាំងអនុលោមភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ក្រសួងស្ថាប័នដែលមានហេដ្ឋារចនាសម្ព័ន្ធក្លោដដោយខ្លួនឯងរួចស្រេចនឹងបន្តប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ ហើយធ្វើការតភ្ជាប់មកហេដ្ឋារចនាសម្ព័ន្ធក្លោដជាតិសម្រាប់រក្សាទិន្នន័យបម្រុងទុករបស់ខ្លួន។ ដោយឡែក ក្រសួងស្ថាប័នដែលមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធក្លោដ ត្រូវប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធក្លោដជាតិ ដែលបានកសាងក្នុងក្របខណ្ឌរដ្ឋាភិបាលឌីជីថល។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្លោដបែបពាក់កណ្តាលវិមជ្ឈការនេះ នឹងធានាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា និងធ្វើឱ្យការចែករំលែកធនធានគណនាលើហេដ្ឋារចនាសម្ព័ន្ធរួមបានល្អប្រសើរ ព្រមទាំងកាត់បន្ថយហានិភ័យនៃដំណើរការមិនប្រក្រតីនូវសេវារដ្ឋាភិបាលឌីជីថលទាំងមូល ដែលអាចកើតពីបញ្ហាបច្ចេកទេស និងការវាយប្រហារតាមប្រព័ន្ធអេឡិចត្រូនិក(Single Point of Failure)។

**<u>ដំណាក់កាល</u>**

ដើម្បីសម្រេចបាននូវការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥ រាជរដ្ឋាភិបាលកំណត់ក្របខណ្ឌពេលវេលាជា៣ដំណាក់កាល ដែលរួមមាន ការកសាងមូលដ្ឋានគ្រឹះរដ្ឋាភិបាលឌីជីថល ការចាប់យកបច្ចេកវិទ្យាឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាល។ តាមរយៈក្របខណ្ឌពេលវេលាដែលបានកំណត់១៥ឆ្នាំ បណ្តាសកម្មភាពនឹងត្រូវបែងចែកនិងអនុវត្តទៅតាមដំណាក់កាល និងលំដាប់លំដោយទៅតាមអាទិភាពនិងកាលានុវត្តភាពជាក់ស្តែង ដែលមានភាពប្រទាក់ក្រឡាគ្នានិងឆ្លើយតបគ្នាទៅវិញទៅមក។

(១) **ការកសាងមូលដ្ឋានគ្រឹះរដ្ឋាភិបាលឌីជីថល ២០២១-២០២៥** សំដៅរៀបចំស្ថាប័នសម្របសម្រួល អង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថល កសាងគោលនយោបាយនិងក្របខណ្ឌគតិយុត្តរដ្ឋាភិបាលឌីជីថលចាំបាច់នានា ដូចជា គោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងស្តង់ដា រៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធរដ្ឋាភិបាលឌីជីថលទាំងគុណភាពនិងវិសាលភាព ដូចជា ហេដ្ឋារចនាសម្ព័ន្ធបណ្តាញរដ្ឋាភិបាលឌីជីថលនិងហេដ្ឋារចនាសម្ព័ន្ធក្លោដ ពង្រឹងនិងពង្រីកសេវាឌីជីថលឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ប្រកបដោយសមធម៌និងបរិយាបន្ន ជាពិសេស សេវាពីរដ្ឋាភិបាលទៅរដ្ឋាភិបាល(G2G) សេវាសាធារណៈពីរដ្ឋាភិបាលដើម្បីប្រជាពលរដ្ឋ(G4C) និងសេវាសាធារណៈពីរដ្ឋាភិបាលទៅធុរកិច្ច(G2B) ពង្រឹងនិងពង្រីកសមត្ថភាពក្នុងការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថល ដូចជាការកសាងសមត្ថភាពឌីជីថលសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ ហើយទិន្នន័យបើកចំហរបស់រដ្ឋាភិបាលត្រូវបានចែករំលែកដល់សាធារណជន ដើម្បីធានាតម្លាភាព និងគណនេយ្យភាព។ ភាពជោគជ័យនៃការអនុវត្តសកម្មភាពនៅក្នុងដំណាក់កាលនេះ នឹងជំរុញកម្រិតនៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជា បច្ចុប្បន្នពីកម្រិតទី១ទៅកម្រិតទី៣ ទៅតាមការកំណត់របស់ក្រុមហ៊ុនស្រាវជ្រាវហ្គាតណឺ (Gartner)។

(២) **ការចាប់យកបច្ចេកវិទ្យាឌីជីថល ២០២៦-២០៣០** សំដៅកសាង រៀបចំ និងពង្រឹងសមត្ថភាពរដ្ឋាភិបាលឌីជីថល ជាពិសេស សេវាសាធារណៈពីរដ្ឋាភិបាលដើម្បីប្រជាពលរដ្ឋ(G4C) និងសេវារដ្ឋាភិបាលទៅធុរកិច្ច (G2B) ឱ្យកាន់តែប្រសើរឡើង ជាពិសេស ការផ្តោតលើអភិបាលកិច្ចទិន្នន័យ ទិន្នន័យបើកចំហ និងការផ្លាស់ប្តូរទិន្នន័យដើម្បីអភិវឌ្ឍប្រព័ន្ធឌីជីថលដែលមានលក្ខណៈនវានុវត្តន៍ ការគ្រប់គ្រងនិងការផ្តល់សេវានានាឱ្យបានប្រសើរជាងមុនដោយទាញយកនិងផ្អែកលើទិន្នន័យប្រមូលផ្តុំ។ ក្នុងដំណាក់កាលនេះ កម្រិតអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជា នឹងកើនឡើងពីកម្រិតទី៣ទៅកាន់កម្រិតទី៤។

(៣) **ការធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាល ២០៣១-២០៣៥** សំដៅកសាងរដ្ឋាភិបាលឆ្លាត ដោយឈរលើការកសាងមូលដ្ឋានគ្រឹះរដ្ឋាភិបាលឌីជីថល ការចាប់យកបច្ចេកវិទ្យាឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាល។ ក្នុងដំណាក់

កាលនេះ ដំណើរការនៃការប្រមូលនិងវិភាគទិន្នន័យ ត្រូវបានធ្វើឡើងដោយស្វ័យប្រវត្តិ និងមាននវានុវត្តន៍ដោយប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ជាអាទិ៍ បញ្ញាសិប្បនិម្មិត អ៊ីនធឺណិតនៃវត្ថុ សម្រាប់ជំនួយដល់ការសម្រេចចិត្តនិងការឆ្លើយតបចំពោះបញ្ហា។ កម្រិតអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជានឹងកើនឡើងពី កម្រិតទី៤ ដែលជាដំណាក់កាលរដ្ឋាភិបាលបរិវត្តកម្មពេញលេញ ទៅកម្រិតទី៥ ដែលជាដំណាក់កាលរដ្ឋាភិបាលឆ្លាត។

**<u>មូលធនមនុស្សនិងធនធានហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍរដ្ឋាភិបាលឌីជីថល</u>**

ដើម្បីអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលទទួលបានជោគជ័យ រាជរដ្ឋាភិបាលកម្ពុជាកំណត់អាទិភាពចំបងលើការកែទម្រង់ធនធានមនុស្សក្នុងក្របខណ្ឌមន្ត្រីរាជការដោយបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាឌីជីថលដល់មន្ត្រីដែលមានស្រាប់និងការជ្រើសរើសមន្ត្រីជំនាញបច្ចេកវិទ្យាឌីជីថលបន្ថែមក្នុងបរិមាណសមរម្យសម្រាប់បំពេញការងារ។ កិច្ចការនេះនឹងធ្វើឡើងតាមរយៈការកំណត់កូតាជ្រើសរើសមន្ត្រីជំនាញបច្ចេកវិទ្យាឌីជីថលប្រចាំឆ្នាំ ស្របទៅនឹងសមាមាត្រនៃចំនួនមន្ត្រីរាជការសរុប។

រាជរដ្ឋាភិបាលនឹងរៀបចំកញ្ចប់ថវិកាអាទិភាព ដែលមានប្រភពពីថវិកាជាតិ ពីដៃគូអភិវឌ្ឍន៍ ពីវិស័យឯកជន និងប្រភពស្របច្បាប់ដទៃទៀត សម្រាប់ការអភិវឌ្ឍនិងបន្តនិរន្តរភាពនៃប្រព័ន្ធរដ្ឋាភិបាលឌីជីថល។

គម្រោងរដ្ឋាភិបាលឌីជីថល ត្រូវពិនិត្យនិងផ្តល់យោបល់ ដោយគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល មុននឹងអនុវត្តនីតិវិធីផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តគម្រោងស្របទៅតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

*រូបភាពទី៧ : គំនូសបំព្រួញនៃយន្តការដឹកនាំ សម្របសម្រួល និងអនុវត្ត*




**<u>កិច្ចសហប្រតិបត្តិការអន្តរជាតិ</u>**

កិច្ចសហប្រតិបត្តិការអន្តរជាតិ នឹងដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងពង្រីកទំនាក់ទំនងទ្វេភាគី និងពហុភាគី ផ្សព្វផ្សាយពីគោលនយោបាយ កៀរគរធនធានទាំងផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍ បន្ថែមលើធនធានរបស់រាជរដ្ឋាភិបាលកម្ពុជា និងផ្តល់ការសម្របសម្រួល ពិគ្រោះយោបល់ និងគាំទ្រដល់ការអនុវត្តគម្រោងរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងនិរន្តរភាព។

ការពង្រឹងកិច្ចសហប្រតិបត្តិការធ្វើឡើងក្នុងទម្រង់ផ្សេងៗជាមួយដៃគូអភិវឌ្ឍ រួមមានកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ក្នុងក្របខណ្ឌអនុតំបន់ តំបន់ និងពិភពលោក សំដៅជានាបានផលប្រយោជន៍ទៅវិញទៅមក ជំរុញការតភ្ជាប់សុខដុមនីយកម្ម និងប្រសិទ្ធផល ក្នុងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលនិងរដ្ឋាភិបាលឌីជីថល តាមរយៈការចែករំលែកបទពិសោធនិងចំណេះដឹងរវាងគ្នា ការវិនិយោគដែលមានលក្ខណៈសមាហរណកម្ម និងការសម្របសម្រួលយុទ្ធសាស្ត្រឌីជីថលដែលជានាអន្តរប្រតិបត្តិការរវាងគ្នា។

ការផ្សព្វផ្សាយបញ្ជ្រាបគោលនយោបាយនិងផែនការមេរដ្ឋាភិបាលឌីជីថលទៅកាន់ប្រទេសជាដៃគូ និងអង្គការក្នុងតំបន់និងអន្តរជាតិ ត្រូវធ្វើឱ្យបានទូលំទូលាយ ដើម្បីទាក់ទាញការចូលរួមចំណែក និងកិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍគម្រោងរដ្ឋាភិបាលឌីជីថល។

## ៨.២- យន្តការតាមដាននិងវាយតម្លៃ

ដើម្បីជានាបាននូវវឌ្ឍនភាព ប្រសិទ្ធភាព សង្គតិភាព និងដំណោះស្រាយលើបញ្ហាប្រឈមបានទាន់ពេលវេលា ក្នុងការអនុវត្តគោលនយោបាយនេះ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលដែលជាស្ថាប័នទទួលបន្ទុកតាមដាន និងវាយតម្លៃការអនុវត្តត្រូវ៖

- បង្កើតប្រព័ន្ធតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ ដោយកំណត់សូចនាករជាក់លាក់ដែលអាចវាស់វែងបាន ក៏ដូចជាប្រភពទិន្នន័យ ឬវិធីសាស្ត្រស្វែងរកទិន្នន័យ ដោយមានការចូលរួម និងផ្តល់យោបល់ពីភាគីពាក់ព័ន្ធ។
- រៀបចំផែនការសម្រាប់តាមដាននិងវាយតម្លៃការអនុវត្ត និងការផ្តល់របាយការណ៍។
- បង្កើតប្រព័ន្ធរាយការណ៍ និងគំរូរបាយការណ៍ សម្រាប់សម្រួលដល់ការរាយការណ៍របស់អ្នកពាក់ព័ន្ធ។
- សម្របសម្រួលដំណើរការតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយនេះ។
- ដំណើរការតាមដាននិងវាយតម្លៃត្រូវប្រើប្រាស់ធនធានលេខាធិការដ្ឋាននៃគណៈកម្មាធិការឬប្រើប្រាស់សេវាកម្មខាងក្រៅតាមការចាំបាច់។

*រូបភាពទី៨ : យន្តការតាមដាននិងវាយតម្លៃ*




**ការតាមដាន**

ការតាមដានការអនុវត្តគោលនយោបាយ គឺជាការពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តសកម្មភាព ការប្រើប្រាស់ធនធាន ធាតុចេញ ដែលកើតចេញពីការអនុវត្តសកម្មភាពទាំងនោះនិងបញ្ហាប្រឈមនានាដែលរាំងស្ទះដល់ដំណើរការអនុវត្ត។ ដើម្បីអាចសម្រួលដល់ការតាមដាន គណៈកម្មាធិការអាចដាក់ចេញផែនការតាមដានការអនុវត្តគោលនយោបាយ

ច្បាស់លាស់ តាមរយៈការបង្កើតប្រព័ន្ធរាយការណ៍ របៀបរបបទំនាក់ទំនង និងកាលវិភាគនៃការរាយការណ៍ដែលត្រូវធ្វើរៀងរាល់ធមាសនិងរៀងរាល់ឆ្នាំ។ គំរូរបាយការណ៍ក៏នឹងត្រូវបង្កើតឡើងសម្រាប់សម្រួលដល់យន្តការរាយការណ៍របស់អ្នកអនុវត្តគោលនយោបាយ។ គណៈកម្មាធិការត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យលើរបាយការណ៍បូកសរុប លើវឌ្ឍនភាពនៃការអនុវត្តនិងដោះស្រាយបញ្ហាប្រឈម ព្រមទាំងសំណូមពរនានាសម្រាប់ធានាដំណើរការនៃការអនុវត្តសកម្មភាពបានរលូននិងមានប្រសិទ្ធភាព។

**<u>ការវាយតម្លៃ</u>**

យន្តការវាយតម្លៃមានសារៈសំខាន់ក្នុងការពិនិត្យប្រសិទ្ធភាពនៃសកម្មភាពអាទិភាព ដែលបានដាក់ចេញ និងកាន់តែមានសារៈសំខាន់ខ្លាំងឡើងក្នុងយុគសម័យដែលបច្ចេកវិទ្យាមានការផ្លាស់ប្តូរឆាប់រហ័ស ហើយប្រព័ន្ធការងារឬប្រព័ន្ធឌីជីថលមួយចំនួនងាយនឹងហួសសម័យ មិនអាចឆ្លើយតបទៅនឹងបរិបទបរិវត្តកម្មឌីជីថលបានបន្តទៀត។ ក្នុងន័យនេះ ការវាយតម្លៃគោលនយោបាយបានទៀងទាត់ អាចផ្តល់ឱកាសឱ្យគណៈកម្មាធិការពិនិត្យឡើងវិញ កែប្រែវិធានការមិនមានប្រសិទ្ធភាពមួយចំនួន ដាក់ចេញវិធានការថ្មីឬផ្លាស់ប្តូរបច្ចេកវិទ្យាថ្មីៗទាន់សភាពការណ៍។ ការវាយតម្លៃលើលទ្ធផលនិងបច្ច័យនៃការអនុវត្តគោលនយោបាយនេះ អាចត្រូវធ្វើឡើងក្នុងរយៈពេលជាក់លាក់ណាមួយកំណត់ដោយគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល។ ការវាយតម្លៃនេះត្រូវធ្វើឡើងដោយមានការកំណត់សូចនាករសម្រាប់ការវាស់វែងនិងប្រភពទិន្នន័យច្បាស់លាស់ មានផែនការវាយតម្លៃនិងវិធីសាស្ត្រក្នុងការសិក្សាស្វែងរកទិន្នន័យ។ បន្ទាប់ពីមានការវាយតម្លៃរួច គណៈកម្មាធិការអាចពិនិត្យ សម្រេច កែប្រែសកម្មភាពអាទិភាព ឬដាក់ចេញផែនការថ្មីណាមួយបន្ថែមទៀត។

# ៩- ការបញ្ចៀស កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់ និងការគ្រប់គ្រងហានិភ័យ

## ៩.១- ការបញ្ចៀស កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់ពាក់ព័ន្ធនឹងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម

តាមការចង្អុលបង្ហាញក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ២០២១-២០៣៥ដើម្បីចូលរួមបញ្ចៀស កាត់បន្ថយ និងដោះស្រាយនូវហានិភ័យពាក់ព័ន្ធនឹងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម ដូចជា វប្បធម៌ និងប្រពៃណី ដែលកើតមានឡើងតាមរយៈនៃការធ្វើបរិវត្តកម្មឌីជីថល គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ត្រូវរៀបចំនិងធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើការបង្ហោះ និង ការបង្កើតនូវខ្លឹមសារ (Content Creation) ផ្សេងៗ ក្នុងការការពារឱ្យបាននូវវប្បធម៌ និងប្រពៃណីប្រកបដោយភាពទន់ភ្លន់ ប៉ុន្តែក្នុងន័យទុកលំហសម្រាប់ការច្នៃប្រតិដ្ឋក្នុងកម្រិតសមរម្យមួយ។ ទន្ទឹមនឹងនេះ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល អនុវត្តគម្រោង និង/ឬ កម្មវិធីជំរុញការយល់ដឹងពីវប្បធម៌, សិល្បៈ និង អរិយធម៌ តាមប្រព័ន្ធអេឡិចត្រូនិក ជាពិសេស រៀបចំក្របខណ្ឌនៃការផ្សព្វផ្សាយ និងសារគមនាគមន៍ជាសាធារណៈសម្រាប់តម្រង់ឥរិយាបថ, ពន្យល់អំពីការសម្រេចចិត្ត, និងបញ្ញាបទិសដៅអភិវឌ្ឍន៍ក្នុងពេលអនាគត ទាក់ទងនឹងបច្ចេកវិទ្យាឌីជីថលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និង អភិបាលកិច្ច នៅក្នុងវិស័យសាធារណៈ។ បន្ថែមលើនេះ ការរៀបចំនិងអនុវត្តក្របខណ្ឌកម្មវិធីផ្សព្វផ្សាយថ្នាក់ជាតិ ដែលនឹងជំរុញការអភិវឌ្ឍចំណេះដឹង និងជំនាញឌីជីថល និង ការផ្តល់ប្រឹក្សាស្តីពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលមានសុវត្ថិភាព និង មានកិច្ចជានា ដល់កុមារ, យុវជន, លោកគ្រូ អ្នកគ្រូ និងអាណាព្យាបាល ព្រមទាំងសាធារណជនទូទៅ។

## ៩.២- ហានិភ័យពាក់ព័ន្ធនឹងការសម្របសម្រួលស្ថាប័ន

ដើម្បីអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យខ្ពស់ ចាំបាច់ទាមទារឱ្យមានការចូលរួមអនុវត្តយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។ ក្នុងន័យនេះ គ្រប់ក្រសួងស្ថាប័នរដ្ឋ ទាំងកម្រិតនយោបាយ និងកម្រិតបច្ចេកទេស ត្រូវមានមុខងារទទួលខុសត្រូវជាក់លាក់និងច្បាស់លាស់ចំពោះការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ប្រកបដោយចីរភាព ស្របតាមគោលនយោបាយនេះ។ ការងារទាំងនេះគួរត្រូវទទួលបន្ទុកគ្រប់គ្រងដោយបុគ្គលដែលមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការកំណត់ការបែងចែកធនធាន និងអាទិភាពរបស់អង្គភាព ព្រមទាំងមានសមត្ថភាពអាចដឹកនាំ គ្រប់គ្រង និងអនុវត្តកិច្ចការដ៏មានសារៈសំខាន់នេះឱ្យទទួលបានជោគជ័យ។ ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវលើកកម្ពស់ទំនាក់ទំនងល្អក្នុងស្ថាប័ននិងអន្តរស្ថាប័ន និងទំនាក់ទំនងជាមួយបុគ្គលពាក់ព័ន្ធទាំងអស់ ជំរុញនិងលើកកម្ពស់ការចែករំលែកព័ត៌មាន និងបទពិសោធ និងពង្រឹងតម្លាភាពនិងសុចរិតភាពក្នុងការងារ ដើម្បីធានាបាននូវការជឿទុកចិត្តគ្នាទៅវិញទៅមកនិងការអនុវត្តការងាររួមគ្នាបានដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

## ៩.៣- ហានិភ័យពាក់ព័ន្ធនឹងការផ្លាស់ប្តូររបៀបរបបការងារ

ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលនឹងជំរុញឱ្យមានការផ្លាស់ប្តូររបៀបរបប និងឥរិយាបថការងារនៅក្នុងក្រសួងស្ថាប័នរដ្ឋ ដែលមានជាអាទិ៍ ការផ្លាស់ប្តូរពីដំណើរការការងារដែលធ្វើដោយដៃ ដោយប្រើក្រដាសច្រើន និងមិនសូវមានការចែករំលែកព័ត៌មានទូលំទូលាយ មកជាការធ្វើការងារតាមប្រព័ន្ធព័ត៌មានឌីជីថលដែលមានលក្ខណៈស្វ័យប្រវត្តិ មានតម្លាភាព ពុំមានប្រើក្រដាស និងងាយស្រួលក្នុងការចែករំលែកទិន្នន័យនិងព័ត៌មាន ដោយប្រើប្រាស់ពេលវេលាតិចនិងឆាប់រហ័ស។ ហានិភ័យធំទីមួយ គឺការរារាំងដោយថាហេតុរបស់មន្ត្រីមួយចំនួននៅតាមក្រសួងស្ថាប័នរដ្ឋមិនឱ្យអភិវឌ្ឍ និងប្រើប្រាស់រដ្ឋាភិបាលឌីជីថល ដោយរលូនឬមិនអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យអស់លទ្ធភាពសម្រាប់

ដំណើរការនៃការធ្វើស្វ័យប្រវត្តិកម្មការងារ ដោយហេតុថា ការប្រើប្រាស់បច្ចេកវិទ្យាថ្មី អាចនឹងប៉ះពាល់ដល់ផលប្រយោជន៍បុគ្គល។ ហានិភ័យធំទីពីរ គឺការបំពេញការងារតាមរយៈការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថលអាចនឹងមិនទទួលបាននូវលទ្ធផលល្អដូចការរំពឹងទុក ដោយសារមន្ត្រីរាជការក្នុងវិស័យសាធារណៈ និងឯកជន ព្រមទាំងប្រជាពលរដ្ឋមួយចំនួនមិនទាន់មានចំណេះដឹងគ្រប់គ្រាន់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីនេះ ជាពិសេសតំបន់ដែលមានការអភិវឌ្ឍតិចតួច (កង្វះខាតឧបករណ៍ និងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិត)។ ដើម្បីទប់ស្កាត់និងបញ្ចៀសនូវហានិភ័យខាងលើនេះ រាជរដ្ឋាភិបាលត្រូវពង្រីកការយល់ដឹងឱ្យបានទូលំទូលាយជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ទាំងក្នុងវិស័យសាធារណៈ និងឯកជន ប្រជាពលរដ្ឋ និងបុគ្គលពាក់ព័ន្ធទាំងអស់ នូវចំណេះដឹងអំពីការប្រើប្រាស់ ផលប្រយោជន៍ និងសារៈសំខាន់នៃរដ្ឋាភិបាលឌីជីថល រៀបចំផែនការ សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់ ដើម្បីគាំទ្រដល់ការផ្លាស់ប្តូររៀបចំយន្តការសម្របសម្រួល និងដាក់ចេញវិធានការចាំបាច់ជាក់ស្តែង ដើម្បីដោះស្រាយបញ្ហានិងជម្នះឱ្យបាននូវឧបសគ្គនានា។

## ៩.៤- ហានិភ័យពាក់ព័ន្ធនឹងមូលធនមនុស្សនិងហិរញ្ញវត្ថុ

មូលធនមនុស្សនិងហិរញ្ញវត្ថុ គឺជាធនធានដ៏ចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ការអនុវត្ត គោលនយោបាយ ដំណើរការស្ថាប័ន និងការអភិវឌ្ឍវិស័យផ្សេងៗទៀត។ ហានិភ័យពាក់ព័ន្ធនឹងមូលធនមនុស្ស មានដូចជាកង្វះធនធានមនុស្សជំនាញ កង្វះឆន្ទៈនិងសុចរិតភាពក្នុងការអនុវត្តការងារ និងអត្រានៃការចាកចេញឬការផ្លាស់ប្តូរពីការងារមានកម្រិតខ្ពស់។ ចំណែកឯហានិភ័យពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុវិញមានចំណុចធំៗពីរ គឺកង្វះខាតធនធានហិរញ្ញវត្ថុសម្រាប់ការវិនិយោគនិងអនុវត្តការងារ និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុមិនមានប្រសិទ្ធភាពនិងប្រសិទ្ធផល។ រាជរដ្ឋាភិបាលត្រូវផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងធនធានទាំងពីរនេះឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ ហើយត្រូវកាត់បន្ថយឱ្យបានជាអតិបរមានូវហានិភ័យនានាដែលអាចកើតឡើងជាយថាហេតុ។ អភិបាលកិច្ចល្អ ការបើកចំហ ការគោរពយ៉ាងម៉ឺងម៉ាត់នូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងការលើកទឹកចិត្តប្រកបដោយសមធម៌ គឺជាកត្តាគន្លឹះដ៏សំខាន់បំផុតដែលនាំមកនូវជោគជ័យសម្រាប់ការងារនេះ។

## ៩.៥- ហានិភ័យពាក់ព័ន្ធនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា

បច្ចេកវិទ្យាឌីជីថលមានការវិវឌ្ឍយ៉ាងឆាប់រហ័ស ដែលធ្វើឱ្យសុសវែរនិងគ្រឿងសម្ភារៈបរិក្ខារឌីជីថលមួយចំនួនអាចមិនឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ក្នុងរយៈពេលវែង ដោយហេតុថា បច្ចេកវិទ្យាឌីជីថលដែលកំពុងប្រើប្រាស់មួយចំនួនមិនទាន់អាចឆ្លើយតបទៅនឹងបញ្ហាសន្តិសុខ និងការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត ព្រមទាំងបញ្ហាប្រឈមក្នុងការថែទាំនិងធ្វើទំនើបកម្មនៃប្រព័ន្ធព័ត៌មានឌីជីថល។ ដើម្បីកាត់បន្ថយនូវហានិភ័យទាំងនេះ ក្រសួង ស្ថាប័ននិងមន្ត្រីទទួលខុសត្រូវលើការអនុវត្តគោលនយោបាយនេះ ត្រូវរៀបចំឱ្យមានផែនការច្បាស់លាស់ និងវិភាគល្អិតល្អន់ក្នុងការជ្រើសរើសនិងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីធ្វើយ៉ាងណាធានាឱ្យបាននូវប្រសិទ្ធភាព ភាពអាចដំណើរការជាមួយគ្នាបាន និងភាពងាយស្រួលក្នុងការកែលម្អនិងលើកកម្ពស់សមត្ថភាពនៃរដ្ឋាភិបាលឌីជីថល។

## ៩.៦- ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថលនិងការគ្រប់គ្រងក្នុងពេលប្រធានសក្តិ

ដោយសាររដ្ឋាភិបាលឌីជីថលសម្រួលដល់ដំណើរការនៃការអនុវត្តការងាររបស់ប្រទេសទាំងមូល ការធានាឱ្យមានសុវត្ថិភាពខ្ពស់និងនិរន្តរភាពនៃការប្រើប្រាស់សេវារដ្ឋាភិបាលឌីជីថលនេះ គឺពិតជាមានសារៈសំខាន់បំផុត។ ហានិភ័យចម្បងៗមួយចំនួនរួមមាន ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត ការគំរាមកំហែងដល់សន្តិសុខជាតិ ការបាត់បង់និង

លេចធ្លាយនៃព័ត៌មានសម្ងាត់សំខាន់ៗ ករណីប្រធានសក្តិ។ល។ ដូចនេះ រាជរដ្ឋាភិបាលត្រូវជានាឱ្យមានហេដ្ឋារចនាសម្ព័ន្ធប្រកបដោយសុវត្ថិភាព ស្ទួនគ្នា និងគង់វង្ស (High Availability) ព្រមទាំងចម្លងទិន្នន័យបម្រុងទុក សម្រាប់ដំណើរការសេវារដ្ឋាភិបាលឌីជីថល នៅតាមបណ្តាក្រសួងស្ថាប័នរដ្ឋទាំងអស់ តាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទាំងនេះ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធនឹងសន្តិសុខរដ្ឋាភិបាលឌីជីថលនៅកម្ពុជា។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលត្រូវមានគោលនយោបាយពាក់ព័ន្ធនឹងការប្រើប្រាស់កម្មវិធីនានា ប្រព័ន្ធការពារមេរោគតាមប្រព័ន្ធអ៊ីនធឺណិត ការបញ្ជ្រាបការយល់ដឹង និងការអប់រំអំពីការគំរាមកំហែងមកលើរដ្ឋាភិបាលឌីជីថល និងយន្តការគ្រប់គ្រងក្នុងពេលប្រធានសក្តិ ដើម្បីធានាសេវារដ្ឋាភិបាលឌីជីថលដោយនិរន្តរភាព។

## ១០- សេចក្តីសន្និដ្ឋាន

"គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥" ត្រូវបានរៀបចំឡើង ដោយមានខ្លឹមសារ លម្អិតគ្រប់ជ្រុងជ្រោយ និងស្របតាមការចង្អុលបង្ហាញនៅក្នុង "ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ២០២១-២០៣៥"។ គោលនយោបាយនេះបានដាក់ចេញនូវគោលដៅ និងយុទ្ធសាស្ត្រក្នុងការកសាងរដ្ឋាភិបាលឌីជីថលជាចម្បង។ បន្ថែមលើនេះ សកម្មភាពអាទិភាព ត្រូវបានរៀបចំឡើងដោយរាប់បញ្ចូលទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ការលើកកម្ពស់សេវាសាធារណៈឌីជីថល អភិបាលកិច្ចផ្អែកលើទិន្នន័យ ការកសាងមូលធនមនុស្សឌីជីថល កិច្ចសហការនិងភាពជាដៃគូរវាងរដ្ឋនិងឯកជន ការចូលរួមជំរុញការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យធុរកិច្ច និងការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល។ ចំណុចពិសេសមួយទៀត សកម្មភាពអាទិភាពមានលក្ខណៈប្រទាក់ក្រឡាគ្នា ដែលបានផ្តល់នូវការបំពេញឱ្យគ្នាទៅវិញទៅមក ដោយផ្តើមចេញពីចង្កោមយុទ្ធសាស្ត្រនៃចក្ខុវិស័យរួម។ គោលនយោបាយនេះក៏បានផ្តោតការយកចិត្តទុកដាក់លើបញ្ហាប្រឈមទាំងឡាយដែលកំពុងកើតមាននៅក្នុងក្រសួងស្ថាប័នរដ្ឋ ព្រមទាំងបង្ហាញផ្លូវនាំឆ្ពោះទៅរកដំណោះស្រាយ ដើម្បីចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលប្រកបដោយប្រសិទ្ធភាពខ្ពស់។

គោលនយោបាយនេះត្រូវបានតាក់តែងឡើង ដោយមានសកម្មភាពអាទិភាពដែលត្រូវបានកំណត់ក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ហើយមានសមាសភាពចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ និងមានលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសអន្តរក្រសួង និងទីប្រឹក្សា។ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ធ្វើកិច្ចសហការជាមួយគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល គណៈកម្មាធិការសន្តិសុខឌីជីថល និងភាគីពាក់ព័ន្ធដទៃទៀត។

ជាមួយគ្នានេះ មូលធនមនុស្សនិងហិរញ្ញវត្ថុ ត្រូវបានកំណត់តាមតម្រូវការជាក់លាក់ជាមុន ដើម្បីធានាដំណើរការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថលដោយរលូន។ គោលនយោបាយនេះក៏បានដាក់ចេញនូវយន្តការតាមដាននិងវាយតម្លៃ និងគ្រប់គ្រងហានិភ័យ សម្រាប់ធានាភាពជោគជ័យនៃការអនុវត្តតាមគោលដៅនិងយុទ្ធសាស្ត្រ។ គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២១-២០៣៥ រំលេចនូវសកម្មភាពអាទិភាពជាក់លាក់មួយចំនួនដើម្បីជំរុញការប្រើប្រាស់សេវាសាធារណៈឌីជីថល។ ជាអាទិ៍ ការកំណត់ស្តង់ដាច្បាស់លាស់ផ្តល់ភាពងាយស្រួលនិងទំនុកចិត្តក្នុងការរៀបចំនិងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងសេវារដ្ឋាភិបាលឌីជីថល ព្រមទាំងការពង្រឹងសន្តិសុខឌីជីថល។ ដូចគ្នានេះដែរ ការកសាងសមត្ថភាពនិងការបណ្តុះបណ្តាលជាយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងការជំរុញដល់ការអភិវឌ្ឍ ការគ្រប់គ្រង ការចាប់យក និងការផ្តល់សេវារដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសុវត្ថិភាព។

ឯកសារគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងត្រូវរៀបចំឡើង ដើម្បីគាំទ្រដំណើរប្រព្រឹត្តទៅនៃការបម្រើសេវាសាធារណៈនិងបរិវត្តកម្មឌីជីថលរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល សំដៅលើកកម្ពស់កម្រិតជីវភាព សុខុមាលភាព ទំនុកចិត្ត និងភាពជឿជាក់របស់ប្រជាពលរដ្ឋ។

គោលនយោបាយរដ្ឋាភិបាលឌីជីថលនេះគឺជាត្រីវិស័យមួយបន្ថែមទៀត រួមជាមួយគោលនយោបាយពាក់ព័ន្ធនានា ដែលគ្រប់ក្រសួងស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន និងប្រជាពលរដ្ឋ ត្រូវចូលរួមអនុវត្តប្រកបដោយភាពប្រទាក់ក្រឡា ប្រសិទ្ធភាព និងប្រសិទ្ធផល៕

## ឧបសម្ព័ន្ធ១ តារាងសកម្មភាពអាទិភាពនៃក្របខណ្ឌយុទ្ធសាស្ត្រដែលទទួលបន្ទុកដោយគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល

| ល.រ | យុទ្ធសាស្ត្រ | សកម្មភាពអាទិភាព | ក្រសួងស្ថាប័នទទួលបន្ទុក | ដំណាក់កាល |
|---|---|---|---|---|
| ១ | ក. ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល | ជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល តាមរយៈ ១-ការពង្រឹងគុណភាពសេវាទូរគមនាគមន៍បច្ចេកវិទ្យាជំនាន់ទី៤(4G) ២- ការកសាងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍បច្ចេកវិទ្យាជំនាន់ទី៥ (5G) ៣- ការកសាងបណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រ និង/ឬបណ្តាញផ្កាយរណបក្នុងករណីចាំបាច់ និង ៤- ការរៀបចំហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍រួម | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ពេលខ្លី-វែង<br>(២០២១- ២០៣៥) |
| ២ | | បង្កើតមជ្ឈមណ្ឌលទិន្នន័យជាតិ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងផែនការ | ពេលខ្លី-មធ្យម<br>(២០២១- ២០៣០) |
| ៣ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធបណ្តាញរដ្ឋាភិបាលឌីជីថលតភ្ជាប់ក្រសួងស្ថាប័ន | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-មធ្យម<br>(២០២១- ២០៣០) |
| ៤ | | ជំរុញការអភិវឌ្ឍន៍អេកូឡូស៊ីនៃប្រព័ន្ធផ្កាយរណប | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦- ២០៣០) |
| ៥ | | ពង្រឹងនិងពង្រីកថ្នាលផ្លាស់ប្តូរទិន្នន័យ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី |

| | | | | |
|---|---|---|---|---|
| | | (CamDX) | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | (២០២១-២០២៥) |
| ៦ | | ជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនៅថ្នាក់ក្រោមជាតិចាប់ពីកម្រិតរាជធានីខេត្ត ដល់ឃុំសង្កាត់ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |
| ៧ | **ខ. ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ** | រៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារទូទាត់សងប្រាក់ថ្នាក់ជាតិសម្រាប់សេវាសាធារណៈ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងប្រៃណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |
| ៨ | **គ. ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល** | ពង្រឹងប្រព័ន្ធគ្រប់គ្រងនិងការពារសន្តិសុខឌីជីថលសម្រាប់ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិ | ក្រសួងប្រៃណីយ៍និងទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ | ពេលខ្លី-វែង<br>(២០២១-២០៣៥) |
| ៩ | | រៀបចំនិងពង្រឹងសន្តិសុខច្រកទ្វារអ៊ីនធឺណិតជាតិ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-វែង<br>(២០២១-២០៣៥) |
| ១០ | | រៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងពាណិជ្ជកម្ម<br>ធនាគារជាតិនៃកម្ពុជា | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |

| | | | | |
|---|---|---|---|---|
| ១១ | **ឃ. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធព័ត៌មានភស្តុភារកម្មប្រៃសណីយ៍** | រៀបចំនិងកែលម្អប្រព័ន្ធបណ្តាញប្រៃសណីយ៍ជាតិ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសាធារណការនិងដឹកជញ្ជូន<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ពេលខ្លី<br>(២០២១-២០២៥) |
| ១២ | **ង. ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល** | រៀបចំគោលនយោបាយអភិបាលកិច្ចទិន្នន័យ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងមហាផ្ទៃ<br>ក្រសួងផែនការ<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងពាណិជ្ជកម្ម<br>ធនាគារជាតិនៃកម្ពុជា | ពេលខ្លី<br>(២០២១-២០២៥) |
| ១៣ | | រៀបចំគោលនយោបាយទិន្នន័យបើកចំហ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦-២០៣០) |
| ១៤ | | រៀបចំគោលនយោបាយជំរុញការអភិវឌ្ឍនិងការប្រើប្រាស់សុសវែរ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦-២០៣០) |
| ១៥ | | រៀបចំគោលនយោបាយអ៊ីនធឺណិតល្បឿនលឿន | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី<br>(២០២១-២០២៥) |
| ១៦ | | រៀបចំគោលនយោបាយឌីជីថលសម្រាប់ទីក្រុងឆ្លាត | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ | ពេលមធ្យម<br>(២០២៦-២០៣០) |

| | | | | |
|---|---|---|---|---|
| | | | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>ក្រសួងសាធារណការនិងដឹកជញ្ជូន<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | |
| ១៧ | | រៀបចំគោលនយោបាយជំរុញការអភិវឌ្ឍវិស័យប្រៃសណីយ៍ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១- ២០២៥) |
| ១៨ | | រៀបចំគោលនយោបាយជំរុញការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ពេលខ្លី-មធ្យម<br>(២០២១- ២០៣០) |
| ១៩ | | រៀបចំច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១- ២០២៥) |
| ២០ | | រៀបចំច្បាប់ស្តីពីបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១- ២០២៥) |
| ២១ | | រៀបចំច្បាប់ស្តីពីការការពារទិន្នន័យបុគ្គល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងមហាផ្ទៃ<br>ក្រសួងពាណិជ្ជកម្ម | ពេលមធ្យម<br>(២០២៦- ២០៣០) |

| | | | | |
|---|---|---|---|---|
| | | | ធនាគារជាតិនៃកម្ពុជា<br>ក្រសួងយុត្តិធម៌<br>ក្រសួងសុខាភិបាល | |
| ២២ | | រៀបចំនិងវិសោធនកម្មច្បាប់ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងច្បាប់ស្តីពីទូរគមនាគមន៍ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី<br>(២០២១-២០២៥) |
| ២៣ | | រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់គ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់វិទ្យុ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ២៤ | | រៀបចំបទដ្ឋាននិងសេចក្តីណែនាំស្តីពីហត្ថលេខាឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងមហាផ្ទៃ<br>ក្រសួងពាណិជ្ជកម្ម<br>ធនាគារជាតិនៃកម្ពុជា | ពេលខ្លី<br>(២០២១-២០២៥) |
| ២៥ | | រៀបចំច្បាប់ស្តីពីសេវាប្រៃសណីយ៍ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសាធារណការនិងដឹកជញ្ជូន<br>ក្រសួងយុត្តិធម៌<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ២៦ | | រៀបចំច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន | ក្រសួងព័ត៌មាន<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ២៧ | | រៀបចំនិងវិសោធនកម្មច្បាប់ និងបទដ្ឋានគតិយុត្តិ | ក្រសួងព័ត៌មាន | ពេលខ្លី |

| | | | | |
|---|---|---|---|---|
| | | ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការត្រួតពិនិត្យលើការបង្ហោះ និងបង្កើតនូវខ្លឹមសារ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | (២០២១-២០២៥) |
| ២៨ | | រៀបចំស្តង់ដាការងាររដ្ឋបាល | ក្រសួងមុខងារសាធារណៈ<br>ក្រសួងប្រៃសណីយយ៍និងទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ២៩ | | រៀបចំស្តង់ដាបច្ចេកសព្ទឌីជីថលរដ្ឋបាល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ៣០ | | រៀបចំស្តង់ដាសេវារដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយយ៍និងទូរគមនាគមន៍<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ៣១ | | រៀបចំស្តង់ដាស្តីពីការគ្រប់គ្រងសេវាឌីជីថល | ក្រសួងប្រៃសណីយយ៍និងទូរគមនាគមន៍ | ពេលខ្លី |

| | | | | |
|---|---|---|---|---|
| | | | ក្រសួងមុខងារសាធារណៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | (២០២១-២០២៥) |
| ៣២ | | រៀបចំស្តង់ដាវិស្វកម្មសុសវែរនិងប្រព័ន្ធព័ត៌មាន | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ៣៣ | | រៀបចំស្តង់ដាសន្តិសុខព័ត៌មាន | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ពេលខ្លី<br>(២០២១-២០២៥) |
| ៣៤ | | រៀបចំស្តង់ដាឌីជីថលសម្រាប់ទីក្រុងឆ្លាត | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងសាធារណការនិងដឹកជញ្ជូន<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦-២០៣០) |

| | | | | |
|---|---|---|---|---|
| ៣៥ | | រៀបចំស្តង់ដាមជ្ឈមណ្ឌលទិន្នន័យ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ៣៦ | | រៀបចំស្តង់ដាបច្ចេកវិទ្យាឌីជីថលចុងក្រោយ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-វែង<br>(២០២១-២០២៥) |
| ៣៧ | | រៀបចំនិម្មាបនកម្មរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ៣៨ | **ច. ការធ្វើបរិវត្តកម្មឌីជីថលរដ្ឋាភិបាលនិងសេវាសាធារណៈ** | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវថ្នាលសហការកិច្ចការរដ្ឋបាល (Collaboration Platform) | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |
| ៣៩ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការរួម | ក្រសួងមុខងារសាធារណៈ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |
| ៤០ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុរួម | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |

| | | | | |
|---|---|---|---|---|
| ៤១ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងឯកសារអេឡិចត្រូនិករួម និងប្រព័ន្ធផ្តល់សច្ចានុម័តអេឡិចត្រូនិករួម | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦-២០៣០) |
| ៤២ | | រៀបចំនិងបំពាក់ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ឌីជីថល សុសវែរ និងប្រព័ន្ធព័ត៌មានចាំបាច់នានា | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-មធ្យម<br>(២០២១-២០២៥) |
| ៤៣ | | រៀបចំថ្នាលទិន្នន័យរូបភាពពីផ្កាយរណប ដ្រូន (Drone) និងឧបករណ៍ផ្សេងៗ ប្រើប្រាស់បច្ចេកវិទ្យា Remote Sensing | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦-២០៣០) |
| ៤៤ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងប្រព័ន្ធគ្រប់គ្រងព័ត៌មានភូមិសាស្ត្រ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ<br>ក្រសួងបរិស្ថាន<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលមធ្យម<br>(២០២៦-២០៣០) |
| ៤៥ | | រៀបចំមូលដ្ឋានទិន្នន័យហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ (National Infrastructure Management Information System) | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦-២០៣០) |
| ៤៦ | | រៀបចំប្រព័ន្ធគ្រប់គ្រងចំណេះដឹងផ្នែកបច្ចេកវិទ្យាឌីជីថល (Knowledge Management System on | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦-២០៣០) |

| | | | | |
|---|---|---|---|---|
| | | Digital Technology ) | | |
| ៤៧ | | រៀបចំថ្នាលសេវាច្រកចេញចូលតែមួយ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-មធ្យម<br>(២០២១- ២០៣០) |
| ៤៨ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្រានុកូលដ្ឋាន | ក្រសួងមហាផ្ទៃ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-មធ្យម<br>(២០២១- ២០៣០) |
| ៤៩ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្តសញ្ញាណកម្ម | ក្រសួងមហាផ្ទៃ<br>ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-មធ្យម<br>(២០២១- ២០៣០) |
| ៥០ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានជនអន្តោប្រវេសន៍ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានទិដ្ឋាការ | ក្រសួងមហាផ្ទៃ<br>ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលមធ្យម<br>(២០២៦- ២០៣០) |
| ៥១ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានស្នាក់នៅ និងគ្រួសារ | ក្រសួងមហាផ្ទៃ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលមធ្យម<br>(២០២៦- ២០៣០) |
| ៥២ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអចលនវត្ថុ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-មធ្យម<br>(២០២១- ២០៣០) |

| | | | | |
|---|---|---|---|---|
| ៥៣ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានយានយន្តនិងប័ណ្ណបើកបរយានយន្ត | ក្រសួងសាធារណការ និងដឹកនាំជញ្ជូន<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី<br>(២០២១- ២០២៥) |
| ៥៤ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូរសព្ទសេវាបន្ទាន់ជូនប្រជាពលរដ្ឋ | ក្រសួងមហាផ្ទៃ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី<br>(២០២១- ២០២៥) |
| ៥៥ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលមធ្យម<br>(២០២៦- ២០៣០) |
| ៥៦ | | រៀបចំ និងកែលម្អឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានទីផ្សារការងារនិងសេវាជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-វែង<br>(២០២១- ២០៣៥) |
| ៥៧ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលរួមនិងគ្រប់គ្រងសេវា | ក្រសួងសុខាភិបាល<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-មធ្យម<br>(២០២១- ២០៣០) |
| ៥៨ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានទេសចរណ៍រួម | ក្រសួងទេសចរណ៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលមធ្យម<br>(២០២១- ២០២៥) |
| ៥៩ | | រៀបចំនិងកែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មានកសិកម្ម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលមធ្យម<br>(២០២៦- ២០៣០) |

| | | | | |
|---|---|---|---|---|
| ៦០ | | រៀបចំនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រោះមហន្តរាយ និងប្រព័ន្ធផ្តល់ដំណឹងជាមុនជូនប្រជាពលរដ្ឋពាក់ព័ន្ធនឹងគ្រោះមហន្តរាយ គ្រោះធម្មជាតិ និងការប្រែប្រួលអាកាសធាតុ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦-២០៣០) |
| ៦១ | | ជំរុញនិងរៀបចំប្រព័ន្ធអេកូឡូស៊ីប្រៃសណីយ៍ឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |
| ៦២ | | ធ្វើទំនើបកម្មការគ្រប់គ្រងនិងសេវាប្រៃសណីយ៍ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |
| ៦៣ | | រៀបចំនិងកែលម្អថ្នាលចុះបញ្ជីអាជីវកម្មរួម | ក្រសួងពាណិជ្ជកម្ម<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |
| ៦៤ | | រៀបចំប្រព័ន្ធគ្រប់គ្រងលទ្ធកម្មអេឡិចត្រូនិក(e-Procurement) | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី<br>(២០២១-២០២៥) |

| | | | | |
|---|---|---|---|---|
| ៦៥ | | រៀបចំនិងកែលម្អប្រព័ន្ធសេវាពន្ធដារឌីជីថល | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |
| ៦៦ | | រៀបចំនិងកែលម្អប្រព័ន្ធបញ្ជីរតែមួយជាតិ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលមធ្យម<br>(២០២៦-២០៣០) |
| ៦៧ | **ធ. ការកសាងសមត្ថភាពមូលធនមនុស្សឌីជីថល** | រៀបចំយន្តការនៃការវាស់វែងកម្រិតសមត្ថភាព និងយន្តការនៃគ្រប់គ្រងនិងរក្សាទុកមូលធនមនុស្សជំនាញឌីជីថលក្នុងវិស័យសាធារណៈ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ពេលខ្លី<br>(២០២១-២០២៥) |
| ៦៨ | | ជំរុញការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-វែង<br>(២០២១-២០៣៥) |
| ៦៩ | | ជំរុញការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល និងជំនាញឌីជីថលចាំបាច់នានាដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការនិងបុគ្គលិកក្រសួងស្ថាប័នរដ្ឋទាំងថ្នាក់ជាតិនិងក្រោមជាតិ ជាពិសេស មន្ត្រីបង្គោលបច្ចេកវិទ្យា | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-វែង<br>(២០២១-២០៣៥) |
| ៧០ | | ជំរុញការរៀបចំនិងកែលម្អកម្មវិធីសិក្សា ដើម្បីលើកកម្ពស់អក្ខរកម្មឌីជីថលសម្រាប់សិស្សនិស្សិត គ្រប់កម្រិតសិក្សានិងបណ្តុះបណ្តាល | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី<br>(២០២១-២០២៥) |
| ៧១ | | លើកកម្ពស់អក្ខរកម្ម និងវិធីសាស្ត្របង្រៀនឌីជីថលសម្រាប់គ្រូបង្រៀនគ្រប់កម្រិតសិក្សានិងបណ្តុះ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-មធ្យម<br>(២០២១-២០៣០) |

| | | | | |
|---|---|---|---|---|
| | | បណ្តាល | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | |
| ៧២ | | ជំរុញការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធអប់រំចាំបាច់ ដើម្បីគាំទ្រដល់ការអប់រំ និងការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល ដល់ស្ថាប័នអប់រំគ្រប់កម្រិតនិងបណ្តុះបណ្តាល | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-វែង<br>(២០២១-២០៣៥) |
| ៧៣ | | រៀបចំនូវកម្មវិធីបណ្តុះបណ្តាល កម្មវិធីបញ្ជ្រាបការយល់ដឹង និងការអប់រំនិងការបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រព័ន្ធផ្សព្វផ្សាយនានា | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងព័ត៌មាន<br>ក្រសួងមហាផ្ទៃ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ពេលខ្លី-វែង<br>(២០២១-២០៣៥) |
| ៧៤ | | ជំរុញការរៀបចំថ្នាលអប់រំនិងបណ្តុះបណ្តាលជាតិរួម | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងព័ត៌មាន<br>ក្រសួងមុខងារសាធារណៈ | ពេលខ្លី<br>(២០២១-២០២៥) |
| ៧៥ | | រៀបចំក្របខណ្ឌជាតិសមត្ថភាពឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ពេលខ្លី<br>(២០២១-២០២៥) |
| ៧៦ | | ពង្រឹងនិងពង្រីកស្ថាប័នបណ្តុះបណ្តាលជំនាញ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងអប់រំ យុវជន និងកីឡា | ពេលខ្លី-វែង<br>(២០២១-២០៣៥) |

| | | | | |
|---|---|---|---|---|
| | | ឌីជីថល | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | |
| ៧៧ | | រៀបចំកម្មវិធីតម្រង់ទិស ផ្សព្វផ្សាយ និងលើកទឹកចិត្ត ដើម្បីជំរុញឱ្យយុវជន យុវនារី និងស្ត្រីជ្រើសរើសជំនាញបច្ចេកវិទ្យាឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ពេលខ្លី-វែង<br>(២០២១- ២០៣៥) |
| ៧៨ | | ជំរុញការបណ្តុះបណ្តាលអ្នកជំនាញឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ពេលខ្លី-វែង<br>(២០២១- ២០៣៥) |
| ៧៩ | **ជ. ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល** | ជំរុញការស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ពេលខ្លី-វែង<br>(២០២១- ២០៣៥) |
| ៨០ | | ជំរុញការផ្ទេរបច្ចេកវិទ្យាឌីជីថល ដែលបានពីការស្រាវជ្រាវដល់វិស័យសាធារណៈ និងឯកជន | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ពេលខ្លី-វែង<br>(២០២១- ២០៣៥) |
| ៨១ | | ជំរុញសហគ្រិន និងនវានុវត្តន៍ឌីជីថល និងកិច្ច | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-វែង<br>(២០២១- ២០៣៥) |

| | | | | |
|---|---|---|---|---|
| | | សហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន | | |
| ៨២ | **ឈ. ការរៀបចំសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល** | រៀបចំវេទិការវាងគណៈកម្មការរដ្ឋាភិបាលឌីជីថល និងក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល | ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-វែង (២០២១- ២០៣៥) |
| ៨៣ | | ជំរុញការផ្សព្វផ្សាយនិងសម្របសម្រួល សម្របសម្រួល និងលើកទឹកចិត្តក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ក្នុងការចូលរួមអភិវឌ្ឍ និងផ្គត់ផ្គង់ការរៀបចំប្រព័ន្ធ និងសេវាបច្ចេកវិទ្យាឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ពេលខ្លី-វែង (២០២១- ២០៣៥) |
| ៨៤ | | ជំរុញកិច្ចសហការជាមួយប្រតិបត្តិករវិស័យប្រៃសណីយ៍ និងវិស័យផ្សេងទៀតក្នុងការចូលរួមផ្តល់សេវារដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងស្ថាប័នពាក់ព័ន្ធ | ពេលខ្លី-វែង (២០២១- ២០៣៥) |
| ៨៥ | **ញ. ការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល** | បង្កើតនិងពង្រឹងសេវាគាំទ្រនិងលើកទឹកចិត្តការបង្កើតធុរកិច្ចថ្មីឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ពេលខ្លី-វែង (២០២១- ២០៣៥) |
| ៨៦ | | ពង្រឹងឱកាសទីផ្សារសម្រាប់ធុរកិច្ចថ្មីឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ពេលខ្លី-វែង (២០២១- ២០៣៥) |

# សកម្មភាពអាទិភាពក្រោមការទទួលបន្ទុករបស់គណៈកម្មាធិការសន្តិសុខឌីជីថល

| យុទ្ធសាស្ត្រអាទិភាព | | សកម្មភាពអាទិភាព | | ក្រសួងស្ថាប័នទទួលបន្ទុក | ដំណាក់កាល |
|---|---|---|---|---|---|
| ១ | ការរៀបចំក្របខណ្ឌគោលនយោបាយ | ១ | រៀបចំគោលនយោបាយសន្តិសុខឌីជីថល | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ | ពេលខ្លី<br>(២០២១-២០២៥) |
| ២ | ការរៀបចំនិងកែលម្អក្របខណ្ឌច្បាប់និងបទដ្ឋានគតិយុត្ត | ២ | រៀបចំច្បាប់ស្តីពីសន្តិសុខសាយប័រ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងយុត្តិធម៌ | ពេលខ្លី<br>(២០២១-២០២៥) |
| | | ៣ | រៀបចំច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន | ក្រសួងមហាផ្ទៃ<br>ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>ក្រសួងយុត្តិធម៌ | ពេលខ្លី<br>(២០២១-២០២៥) |

**ឧបសម្ព័ន្ធ២**

## ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

# របាយការណ៍សិក្សាអំពី
# ស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា

**លេខាធិការដ្ឋាននៃក្រុមការងារគោលនយោបាយរដ្ឋាភិបាលឌីជីថល**

**ខែតុលា ឆ្នាំ២០២០**

## I) សេចក្តីផ្តើម

ការសិក្សាពីស្ថានភាពរដ្ឋាភិបាលឌីជីថលក្នុងឆ្នាំ២០២០ ត្រូវបានធ្វើឡើងដើម្បីស្វែងយល់ពីបច្ចុប្បន្នភាពនៃរដ្ឋាភិបាលឌីជីថលនៅកម្ពុជា បញ្ហាប្រឈម និងគម្លាតដែលកើតមានឡើង សម្រាប់ផ្តល់អនុសាសន៍មួយចំនួនដែលអាចធ្វើទៅបានសម្រាប់ដាក់ចេញនូវវិធានការគោលនយោបាយចាំបាច់និងមានប្រសិទ្ធភាព ក្នុងគោលបំណងអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយលទ្ធផលខ្ពស់ មានសង្គតិភាព និងនិរន្តរភាពតាមទិសដៅកំណែទម្រង់របស់រាជរដ្ឋាភិបាល។ ការអង្កេតនេះធ្វើឡើងក្នុងដែនកំណត់មួយដោយមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលចំនួន២៨តែប៉ុណ្ណោះ ដោយមិនបានពង្រីកការឈ្វេងយល់បន្ថែមលើអ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធដទៃទៀត ព្រោះតែពេលវេលា និងធនធានមានកម្រិត។ ក្រុមការងារបានប្រើប្រាស់វិធីសិក្សាស្រាវជ្រាវទាំងបែបគុណភាព ទាំងបរិមាណ។ ក្រៅពីនេះ យើងបានប្រើប្រាស់មូលដ្ឋានក្របខណ្ឌកម្រិតរដ្ឋាភិបាលឌីជីថលរបស់ Gartner ដោយបែងចែករដ្ឋាភិបាលឌីជីថលជា៥កម្រិត ដើម្បីយកមកវាស់ស្ទង់ពីការវិវត្តនៃស្ថានភាពរដ្ឋាភិបាលឌីជីថលនៅកម្ពុជា។ ក្នុងគោលបំណងឈ្វេងយល់បានកាន់តែស៊ីជម្រៅពីឫសគល់នៃបញ្ហានិងគម្លាតក្នុងការផ្លាស់ប្តូរឌីជីថលបានច្បាស់លាស់និងជាក់លាក់ ក្រុមការងារបច្ចេកទេសបានសិក្សាបន្ថែមលើស្ថានភាពប្រព័ន្ធកម្មវិធី និងប្រព័ន្ធទិន្នន័យដែលកំពុងប្រើប្រាស់ បញ្ហាសន្តិសុខឌីជីថល ហេដ្ឋារចនាសម្ព័ន្ធ អភិបាលកិច្ចបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងការផ្តល់សេវាសាធារណៈ នៅតាមក្រសួងស្ថាប័នក្នុងរូបភាពរួមនិងកាន់តែស៊ីជម្រៅបន្ថែមទៀត។ ទិន្នន័យដែលទទួលបានពីការសិក្សាស្ថានភាពលើធាតុសំខាន់ៗទាំងនេះ នឹងឆ្លុះបញ្ចាំងពីកម្រិតនិងស្ថានភាពនៃរដ្ឋាភិបាលឌីជីថលនៅកម្ពុជាបានកាន់តែច្បាស់។

ជាការពិតជាក់ស្តែង ការវិវត្តរបស់បច្ចេកវិទ្យាបានធ្វើឱ្យបរិបទនៃការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ បង្កើនប្រសិទ្ធភាពការងារ និងការផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាលមានការផ្លាស់ប្តូរដែរ។ កាលពីមុន ក្នុងន័យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលសម្រាប់ការងាររដ្ឋាភិបាល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ជាពិសេសអ៊ីនធឺណិតត្រូវបានប្រើប្រាស់សម្រាប់អភិបាលកិច្ចល្អ ប៉ុន្តែជាទូទៅការផ្លាស់ប្តូរជំនួសដោយ ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់បំពេញការងារ និងការផ្តល់សេវា មិនបានធ្វើឱ្យមានការផ្លាស់ប្តូរទម្រង់បែបបទ និងរចនាសម្ព័ន្ធការងារនោះទេ។ រដ្ឋាភិបាលអេឡិចត្រូនិកបែបនេះបានជួយសម្រួលដល់ការបំពេញការងារ និងការផ្តល់សេវាសាធារណៈមួយកម្រិត និងប្រសិទ្ធភាពច្រើនជាងមុន តែមិនទាន់បានបង្កើតតម្លៃបន្ថែមចេញពីសមាហរណកម្មនៃប្រព័ន្ធទាំងឡាយ និងទិន្នន័យប្រមូលផ្តុំដែលកើតចេញពីការតភ្ជាប់ទំនាក់ទំនងប្រព័ន្ធបច្ចេកវិទ្យាទាំងអស់ពីគ្រប់អង្គភាព និងក្រសួង ស្ថាប័នរាជរដ្ឋាភិបាលនោះដែរ។ សក្តានុពលកើតចេញពីការវិវត្តជាបន្តបន្ទាប់បែបនេះ បានប្រែក្លាយគោលគំនិតនៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល មិនមែនត្រឹមតែជាការផ្លាស់ប្តូរមកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់បង្កើនប្រសិទ្ធភាពការងារ និងការផ្តល់សេវាសាធារណៈនោះទេ គឺជាការរៀបចំយុទ្ធសាស្ត្រយូរអង្វែងក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ផ្សារភ្ជាប់ជាមួយទិន្នន័យដែលកើតចេញពីប្រព័ន្ធប្រមូលផ្តុំសម្រាប់ជំនួយដល់ការសម្រេចចិត្ត ការផ្លាស់ប្តូរទម្រង់បែបបទការងារ គាំទ្រដល់ទិសដៅអភិវឌ្ឍន៍ និងកំណែទម្រង់ផ្សេងៗទៀត[1]។

តាមការវិវត្តនាពេលកន្លងមក Gartner ដែលជាក្រុមហ៊ុនប្រឹក្សាយោបល់ដ៏ធំមួយបង្កើតក្របខណ្ឌរដ្ឋាភិបាលឌីជីថល និងបានបែងចែកការវិវត្តរដ្ឋាភិបាលឌីជីថលជា៥កម្រិត[2]។ កម្រិតនីមួយៗមានលក្ខណៈផ្សេងៗគ្នា និងសណ្ឋានដូចខាងក្រោម៖

1 Broadband Policies for Lati n America and the Caribbean: A Digital Economy Toolkit © OECD, IDB 2016, p.361

2 https://www.gartner.com/smarterwithgartner/5-levels-of-digital-government-maturity/

- កម្រិតទី១ : រដ្ឋាភិបាលអេឡិចត្រូនិក(e-Government) ជាដំណាក់កាលដំបូងនៃរដ្ឋាភិបាលឌីជីថល។ ក្នុងដំណាក់កាលនេះ ការអភិវឌ្ឍនិងការប្រើប្រាស់ប្រព័ន្ធឌីជីថល ផ្ដោតលើការផ្លាស់ប្ដូរការផ្ដល់សេវាទៅតាមប្រព័ន្ធអនឡាញ ក្នុងន័យផ្ដល់ភាពងាយស្រួលដល់ការប្រើប្រាស់និងសន្សំសំចៃថវិកា។ ប្រព័ន្ធឌីជីថល និងការផ្ទុកទិន្នន័យនៅក្នុងដំណាក់កាលដំបូងមានសភាពដាច់ដោយឡែកពីគ្នា។

- កម្រិតទី២ : រដ្ឋាភិបាលចំហ(Open Government) ដំណាក់កាលបើកចំហ ជាដំណាក់កាលដែលប្រព័ន្ធកម្មវិធីត្រូវបានបង្កើតឡើងដើម្បីទទួលមតិយោបល់ និងមានអន្តរអំពើជាមួយអ្នកទទួលសេវា។ នៅក្នុងកម្រិតទី២ ព័ត៌មានរបស់រដ្ឋាភិបាលត្រូវបានបើកចំហដល់សាធារណជន ដើម្បីធានាតម្លាភាពនិងការទទួលខុសត្រូវ។

- កម្រិតទី៣ : រដ្ឋាភិបាលផ្ដោតលើទិន្នន័យ(Data-centric) ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្រិតនេះ ផ្ដោតសំខាន់លើទិន្នន័យជាទ្រព្យសំខាន់និងចាំបាច់។ ការអភិវឌ្ឍកម្មវិធីលែងជាចំណុចអាទិភាព ផ្ទុយទៅវិញការប្រមូល ការប្រើប្រាស់ និងការវិភាគទិន្នន័យ គឺជាយុទ្ធសាស្ត្រសំខាន់របស់រដ្ឋាភិបាល។ ប្រព័ន្ធដំណើរការរបស់អង្គភាពក្រោមចំណុះរដ្ឋាភិបាលត្រូវបានភ្ជាប់ទំនាក់ទំនងគ្នាជាបណ្ដើរៗ ហើយការអនុវត្តការងារ នឹងដំណើរការលើថ្នាលឌីជីថល (Government as A Platform)។

- កម្រិតទី៤ : រដ្ឋាភិបាលឌីជីថលពេញលេញ(Fully Digital) ជាដំណាក់កាលដែលអង្គភាព ក្រសួងស្ថាប័នក្នុងជួររដ្ឋាភិបាលទាំងអស់ផ្ដោតសារៈសំខាន់លើទិន្នន័យ ដើម្បីអភិវឌ្ឍប្រព័ន្ធឌីជីថលនវានុវត្តន៍សម្រាប់ការងារ ការគ្រប់គ្រង និងការផ្ដល់សេវានានាបានប្រសើរជាងមុន ដោយទាញយកនិងផ្អែកលើទិន្នន័យប្រមូលផ្ដុំ។

- កម្រិតទី៥ : រដ្ឋាភិបាលឆ្លាត(Smart Government) ជាដំណាក់កាលដែលដំណើរការប្រមូលនិងវិភាគទិន្នន័យកើតឡើងដោយស្វ័យប្រវត្តិសម្រាប់ជំនួយដល់ការសម្រេចចិត្ត និងការឆ្លើយតបចំពោះបញ្ហា។ នវានុវត្តន៍នៃសេវាកម្មជាមួយបច្ចេកវិទ្យាថ្មីៗ ដូចជា បញ្ញានិម្មិត និងអ៊ីនធឺណិតវត្ថុអាចប្រតិបត្តិការបានពេញលេញនៅក្នុងដំណាក់កាលនេះ។

តាមការប្រៀបធៀបជាមួយការបែងចែកទាំង៥កម្រិតនេះ រដ្ឋាភិបាលឌីជីថលនៅកម្ពុជា ស្ថិតនៅក្នុងកម្រិតទី១នៅឡើយ ដោយមូលហេតុថា ឌីជីថលនីយកម្មតាមក្រសួងស្ថាប័ននាពេលបច្ចុប្បន្ន ផ្ដោតជាសំខាន់ក្នុងការអភិវឌ្ឍកម្មវិធីសម្រាប់សម្រួលដល់ការងារ ដោយគ្មានយុទ្ធសាស្ត្រសម្រាប់ការផ្លាស់ប្ដូរឌីជីថលរយៈពេលវែង និងការគិតគូរជាសំខាន់ដល់តម្លៃបន្ថែមដែលអាចកើតចេញពីទិន្នន័យប្រមូលផ្ដុំបាន។ ការអភិវឌ្ឍទៀតសោត នៅមានបញ្ហាប្រឈម និងគម្លាតច្រើនដែលត្រូវដោះស្រាយសម្រាប់ត្រៀមខ្លួនក្នុងការចូលរួមការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលបានពេញលេញ ទាំងនៅក្នុងការអភិវឌ្ឍប្រព័ន្ធកម្មវិធី ប្រព័ន្ធទិន្នន័យ សន្តិសុខឌីជីថល ហេដ្ឋារចនាសម្ព័ន្ធ អង្គភាពទទួលបន្ទុកបច្ចេកវិទ្យាតាមក្រសួងស្ថាប័ន បញ្ហាមូលធនជាធនមនុស្សជំនាញ និងការកំណត់អាទិភាពសេវាសាធារណៈសម្រាប់ឌីជីថលនីយកម្ម។

## II) ស្ថានភាពប្រព័ន្ធកម្មវិធីនិងប្រព័ន្ធទិន្នន័យ

ក្នុងចំណោមក្រសួងស្ថាប័នទាំង២៨ មានប្រព័ន្ធកម្មវិធីប្រមាណ១៨២ ត្រូវបាន និងកំពុងបង្កើតឡើងសម្រាប់បម្រើការងារក្នុងក្រសួងស្ថាប័នទាំងនោះ។ ក្នុងចំណោមកម្មវិធីទាំងនេះមាន ប្រព័ន្ធកម្មវិធីចំនួនប្រមាណ១៦៧ កំពុងត្រូវបានប្រើប្រាស់និងមានដំណើរការ ប្រព័ន្ធកម្មវិធីចំនួន៦ បានអភិវឌ្ឍរួចនិងកំពុងប្រើសាកល្បង កម្មវិធីចំនួន៧ កំពុងអភិវឌ្ឍ និងកម្មវិធីចំនួន២ទៀតលែងដំណើរការ(កម្មវិធីលែងដំណើរការនេះជាកម្មវិធីផ្ដល់ដល់ក្រសួង ក្នុងក្របខណ្ឌជំនួយក្នុងគម្រោងផ្សេងៗ ដែលមិនអាចកែប្រែកូដឡើងវិញបាន និងកង្វះខាតថវិកាសម្រាប់ថែទាំ)។

*តារាង១. ស្ថានភាពប្រព័ន្ធកម្មវិធីនៅតាមក្រសួងស្ថាប័ន*

| ស្ថានភាព | ចំនួនប្រព័ន្ធ | ភាគរយ |
|---|---|---|
| កំពុងប្រើប្រាស់ | ១៦៧ | ៩១,៧៥% |
| ឈប់ប្រើប្រាស់ | ២ | ១,០៩% |
| កំពុងអភិវឌ្ឍ | ៧ | ៣,៨៤% |
| កំពុងប្រើប្រាស់សាកល្បង | ៦ | ៣,២៩% |
| **សរុប** | **១៨២** | ១០០% |

និន្នាការនិងតម្រូវការនៃការប្រើប្រាស់បច្ចេកវិទ្យាកើនឡើងខ្ពស់បង្ហាញអំពីការយល់ដឹងនិងការទទួលស្គាល់ពីសារប្រយោជន៍នៃប្រព័ន្ធកម្មវិធីសម្រាប់ជំនួយដល់ការងារអង្គភាព និងរដ្ឋាភិបាល។ ជាគោលបំណងនៃការបង្កើតប្រព័ន្ធកម្មវិធីទាំងនេះ ធ្វើឡើងឆ្លើយតបទៅនឹងតម្រូវការនៃកំណែទម្រង់ការងារគ្រប់គ្រងផ្ទៃក្នុង និងការគ្រប់គ្រងវិស័យដែលជាការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន។ ប៉ុន្តែនិន្នាការនៃការប្រើប្រាស់ និងតម្រូវការទាំងនេះ មិនបានគិតគូរក្នុងបរិបទជាយុទ្ធសាស្ត្រផ្លាស់ប្តូរឌីជីថលរយៈពេលវែង និងការគិតគូរសារៈសំខាន់នៃទិន្នន័យការបង្កើតតម្លៃបន្ថែមពីការប្រមូលផ្តុំទិន្នន័យឡើយ។ ជាទូទៅ ការអនុវត្តនិងប្រើប្រាស់កម្មវិធីមានសណ្ឋាន និងបញ្ហាដូចខាងក្រោម៖

- ***ប្រព័ន្ធកម្មវិធីមានលក្ខណៈដាច់ដោយឡែករៀងខ្លួន និងច្រំដែល(Silo and Redundancy) :*** ប្រព័ន្ធកម្មវិធីស្ទើរតែទាំងអស់ត្រូវបានបង្កើតសម្រាប់បម្រើការងាររៀងៗខ្លួន មិនបានពិចារណាក្នុងការតភ្ជាប់ទំនាក់ទំនងរវាងកម្មវិធីនីមួយៗនោះជាមួយគ្នា ទោះជាក្នុងក្របខណ្ឌអង្គភាពក្រោមចំណុះក្រសួងតែមួយ ឬអន្តរក្រសួង។ ម្យ៉ាងវិញទៀត ក្រៅពីប្រព័ន្ធសម្រាប់គ្រប់គ្រងវិស័យ ប្រព័ន្ធកម្មវិធីដែលមានមុខងារទ្រទ្រង់ការគ្រប់គ្រងរដ្ឋបាល ជាពិសេស ការគ្រប់គ្រងបុគ្គលិកត្រូវបានបង្កើតឡើងជាន់គ្នាសម្រាប់ក្រសួងជាច្រើន និងសូម្បីតែក្នុងអង្គភាពដែលស្ថិតក្នុងក្រសួងតែមួយ។ កត្តាទាំងនេះកើតឡើងដោយសារគ្រប់ក្រសួងស្ថាប័នទាំងអស់មិនមានផែនការរួមសម្រាប់ការផ្លាស់ប្តូរឌីជីថល បង្ហាញជាទិសដៅនិងយុទ្ធសាស្ត្រជាក់លាក់សម្រាប់អង្គភាពក្រោមបង្គាប់អនុវត្តក្នុងការរៀបចំផែនការនិងបង្កើតប្រព័ន្ធកម្មវិធីរបស់ខ្លួននោះទេ។
- ***បញ្ហាភាពជាម្ចាស់លើប្រព័ន្ធកូដកម្មវិធីដែលបានកំពុងប្រើប្រាស់ :*** ក្នុងចំណោមប្រព័ន្ធកម្មវិធីដែលបានអភិវឌ្ឍរួច មានកម្មវិធីប្រមាណ២៤% ដែលក្រសួងស្ថាប័នសាមី មិនអាចមានលទ្ធភាពកែសម្រួលកូដដោយខ្លួនឯងក្នុងភាពជាម្ចាស់កម្មសិទ្ធិពេញលេញ។ កម្មវិធីទាំងនោះភាគច្រើនជាកម្មវិធីដែលបានជាវពីក្រុមហ៊ុនផ្តល់សេវាកម្មខាងក្រៅ ឬជាជំនួយផ្តល់ដោយដៃគូអភិវឌ្ឍ ផ្តល់លទ្ធភាពតិចតួចក្នុងការទទួលបានសិទ្ធិសម្រាប់កែលម្អកូដនៅពេលដែលគម្រោងអភិវឌ្ឍន៍ត្រូវបានបញ្ចប់។ កង្វះភាពជាម្ចាស់លើប្រព័ន្ធកូដនេះបានបង្កជាផលលំបាកក្នុងការថែទាំ កែសម្រួលមុខងារប្រព័ន្ធកម្មវិធី ឬភ្ជាប់ទំនាក់ទំនងនៃប្រព័ន្ធកម្មវិធីទាំងនោះទៅកាន់ប្រព័ន្ធកម្មវិធីដទៃទៀតក្នុងគោលបំណងណាមួយ។ នេះជាចំណុចដែលត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយនិរន្តរភាព។
- ***បញ្ហាភាពជាម្ចាស់លើប្រព័ន្ធទិន្នន័យ និងការគិតគូរពីទិន្នន័យដែលខ្លួនមាន :*** មានប្រព័ន្ធកម្មវិធីប្រមាណជាង៣០% ដែលម្ចាស់កម្មវិធីគ្មានសិទ្ធិពេញលេញក្នុងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ។ ប្រព័ន្ធទិន្នន័យត្រូវបានគ្រប់គ្រងដោយវិស័យឯកជនឬដៃគូអភិវឌ្ឍ។ កម្មវិធីប្រមាណជាង១៨% បានផ្ទុកទិន្នន័យលើ

ប្រព័ន្ធCloud នៅក្រៅប្រទេស ដែលប្រឈមខ្ពស់ក្នុងការលេចធ្លាយព័ត៌មាន និងទិន្នន័យរបស់ខ្លួន។ សំខាន់ជាងនេះ គ្មានក្រសួងស្ថាប័នណាមានបទដ្ឋានគតិយុត្តសម្រាប់ការចែករំលែកទិន្នន័យឬការគ្រប់គ្រងទិន្នន័យបានច្បាស់លាស់ឡើយ។

- ***ភាពងាយរងគ្រោះក្នុងការបាត់បង់ទិន្នន័យ*** : ហានិភ័យក្នុងការបាត់បង់ទិន្នន័យមានកម្រិតខ្ពស់ដោយសារការគិតគូរពីសន្តិសុខប្រព័ន្ធកម្មវិធីតាមក្រសួងស្ថាប័ននៅមានកម្រិតទាប។ ថ្វីត្បិតមានការគិតគូរពីសំណាក់អ្នកបច្ចេកទេសគ្រប់គ្រងប្រព័ន្ធរបស់ក្រសួងស្ថាប័នភាគច្រើន ក្នុងការដាក់លេខសម្ងាត់ និងការប្រើប្រាស់ Firewall( Network, Web Application ) សម្រាប់ការពារប្រព័ន្ធ និងការថតចម្លងទុកទិន្នន័យរបស់ខ្លួនក៏ដោយ ប៉ុន្តែនៅមានក្រសួងស្ថាប័នប្រមាណជាង៥៦% មិនដែលបានត្រួតពិនិត្យសុវត្ថិភាពលើប្រព័ន្ធវេបសាយ និងកម្មវិធី៧៧% មិនដែលបានត្រួតពិនិត្យពីការវាយប្រហារលើប្រព័ន្ធរបស់ខ្លួននោះដែរ និង៨៥%មិនបានអនុវត្តតាមការកំណត់ស្តង់ដានិយាមបឋមស្តីពីសន្តិសុខឌីជីថលឡើយ។ ទាំងអស់នេះជាសញ្ញាណបង្ហាញពីភាពងាយរងគ្រោះនៃប្រព័ន្ធបច្ចេកវិទ្យា ការបាត់បង់ទិន្នន័យអាចកើតមានឡើង ប្រសិនបើមានការលួចចូលទៅក្នុងប្រព័ន្ធទាំងនោះ។

- ***កង្វះអត្តសញ្ញាណកម្មឌីជីថលរបស់មន្ត្រីរាជការ*** : អត្តសញ្ញាណកម្មឌីជីថលរបស់មន្ត្រីរាជការមានសារៈសំខាន់នៅពេលដែលរដ្ឋាភិបាលឌីជីថលវិវត្តនៅកាន់កម្រិតខ្ពស់ ព្រោះអាចបញ្ជាក់អត្តសញ្ញាណមន្ត្រីចូលប្រើប្រាស់ ឬធ្វើការលើថ្នាលឌីជីថលរួម។ នៅក្នុងស្ថានភាពបច្ចុប្បន្ន ការអភិវឌ្ឍន៍ប្រព័ន្ធកម្មវិធីប្រើប្រាស់នាពេលកន្លងមក មិនបានគិតគូរដល់ការកំណត់អត្តសញ្ញាណឌីជីថលមន្ត្រីដែលបម្រើការងារតាមប្រព័ន្ធកម្មវិធីសព្វថ្ងៃ និងទៅពេលអនាគតនោះទេ។

## III ) ស្ថានភាពសន្តិសុខឌីជីថលទូទៅ

ក្រៅពីបញ្ហាសន្តិសុខក្នុងប្រព័ន្ធកម្មវិធីទាំងនោះ ស្ថានភាពអេកូស៊ីស្ទឹមនៃសន្តិសុខឌីជីថល ជាទូទៅនៅតាមក្រសួង ស្ថាប័ននានាក៏នៅមានកម្រិតទាបនៅឡើយ ជាពិសេស នៅលើកម្រិតអ្នកប្រើប្រាស់។

- ***ការប្រើប្រាស់សុសវែរគ្មានអាជ្ញាបណ្ណមានចំនួនច្រើនលើសលប់*** : ក្រសួងស្ថាប័នប្រមាណ៦៣% ប្រើប្រាស់សុសវែរគ្មានអាជ្ញាបណ្ណ រីឯ៣៧%ទៀតមានលទ្ធភាពជាវអាជ្ញាបណ្ណសុសវែរសម្រាប់តែប្រព័ន្ធទិន្នន័យ និងប្រព័ន្ធដំណើរការសំខាន់ៗប៉ុណ្ណោះ។ ក្រៅពីនេះ សុសវែរសម្រាប់ប្រើប្រាស់ទូទៅស្ទើរតែ១០០% មិនមានអាជ្ញាបណ្ណត្រឹមត្រូវនោះទេ។

- ***ភាពងាយរងគ្រោះដោយសារមេរោគពីសំណាក់អ្នកប្រើប្រាស់*** : អ្នកប្រើប្រាស់សម្ភារៈបរិក្ខារបច្ចេកវិទ្យានៅតាមក្រសួងស្ថាប័នប្រមាណជាង៧០% មិនបានប្រើប្រាស់កម្មវិធីកម្ចាត់មេរោគ មិនបានធ្វើបច្ចុប្បន្នភាព និងស្កេនជាទៀងទាត់។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងប្រមាណជាង៥៦% មិនដែលបានបណ្តុះបណ្តាល និងណែនាំពីវិធានសន្តិសុខដល់អ្នកប្រើប្រាស់នោះទេ។ ស្ថានភាពបែបនេះបើកចំហ ឱកាសសម្រាប់ការជ្រៀតចូល និងគ្រប់គ្រងប្រព័ន្ធទិន្នន័យនិងកម្មវិធីនានាតាមរយៈឧបករណ៍បរិក្ខារ បច្ចេកវិទ្យារបស់អ្នកប្រើប្រាស់។

- ***កង្វះមន្ត្រីទទួលបន្ទុកផ្នែកសន្តិសុខឌីជីថល*** : ថ្វីបើបញ្ហាសន្តិសុខឌីជីថលជាបញ្ហាសំខាន់ ជាគ្រឹះសម្រាប់ការផ្លាស់ប្តូរឌីជីថលប្រកបដោយជោគជ័យ និងមានទំនុកចិត្តខ្ពស់ មានក្រសួងស្ថាប័នប្រមាណតែ២២%ប៉ុណ្ណោះ ដែលមានមន្ត្រីទទួលបន្ទុកខាងផ្នែកសន្តិសុខឌីជីថល។ កង្វះមន្ត្រីទទួលបន្ទុកផ្នែកសន្តិសុខ

ឌីជីថល កម្រិតហានិភ័យនៃការរងគ្រោះស្ថិតក្នុងលំដាប់ខ្ពស់ និងមិនអាចឆ្លើយតបបានទាន់ពេលវេលានៅពេលដែលមានឧប្បត្តិហេតុណាមួយកើតឡើងលើប្រព័ន្ធទិន្នន័យនិងប្រព័ន្ធកម្មវិធីទាំងអស់នោះ។

## IV) ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់និងសម្ភារៈបរិក្ខារបច្ចេកទេស

ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងសេវាអ៊ីនធឺណិត គឺជាធាតុសំខាន់មិនអាចខ្វះបានទ្រទ្រង់ដល់ការផ្លាស់ប្តូរឌីជីថល។ នាពេលបច្ចុប្បន្ន គ្រប់ក្រសួងស្ថាប័នទាំងអស់សុទ្ធតែមានសេវាអ៊ីនធឺណិតសម្រាប់ប្រើប្រាស់និងបម្រើការងាររបស់ខ្លួន តាមរយៈការតភ្ជាប់បណ្តាញផ្តល់អ៊ីនធឺណិតផ្តល់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងការជាវបន្ថែមពី ក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិតឯកជនចំនួន១៦ក្រុមហ៊ុនបន្ថែមទៀត។ អ៊ីនធឺណិតដែលបានប្រើប្រាស់ដោយក្រសួងស្ថាប័នទាំងអស់មានទំហំ Bandwidth សរុបប្រមាណ7211 Mbps ក្នុងនោះអ៊ីនធឺណិតដែលផ្តល់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានទំហំ3496 Mbps។ ថ្វីបើការតភ្ជាប់បានធ្វើឡើងគ្រប់ក្រសួងស្ថាប័នក៏ពិតមែន ប៉ុន្តែមានផលលំបាកមួយចំនួនកើតមានឡើង ដែលធ្វើឱ្យការបែងចែកការប្រើប្រាស់អ៊ីនធឺណិតតាមក្រសួង ស្ថាប័ននីមួយៗ មិនបានដល់គ្រប់អង្គភាពក្រោមចំណុះ។




- ***កង្វះបណ្តាញផ្ទៃក្នុង :*** ក្រសួងស្ថាប័នប្រមាណ៤៦% ដែលមិនមានបណ្តាញផ្ទៃក្នុងសម្រាប់រៀបចំនិងបែងចែកការផ្តល់សេវាអ៊ីនធឺណិតបន្ត ជាហេតុធ្វើឱ្យការប្រើប្រាស់អ៊ីនធឺណិតដែលបានផ្តល់មិនអស់លទ្ធភាព និងការចំណាយលើការប្រើប្រាស់ពីក្រៅមានការកើនឡើង។ អង្គភាពចំណុះក្រសួងខ្លះបានសម្រេចជាវសេវាអ៊ីនធឺណិតពីក្រុមហ៊ុនខាងក្រៅដោយខ្លួនឯង។ កង្វះបណ្តាញផ្ទៃក្នុង និងការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិតច្បាស់លាស់ក៏ជាហានិភ័យលើបញ្ហាសន្តិសុខនៃការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតនេះដែរ។ កង្វះខាតក្នុងការរៀបចំបណ្តាញផ្ទៃក្នុងនេះកើតឡើងដោយសារកង្វះថវិកា ឧបករណ៍សម្ភារៈ និងមិនមានអង្គភាពបង្គោលសម្រាប់រៀបចំនិងគ្រប់គ្រងបណ្តាញ។

- ***កង្វះម៉ាស៊ីនមេសម្រាប់ផ្ទុកទិន្នន័យ និងមជ្ឈមណ្ឌលទិន្នន័យរួម :*** គឺជាបញ្ហាចោទចម្បងមួយសម្រាប់ក្រសួងស្ថាប័នទាំងអស់ក្នុងការដាក់ដំណើរការប្រព័ន្ធកម្មវិធីនិងរក្សាទុកទិន្នន័យ។ ក្នុងចំណោមក្រសួងស្ថាប័នទាំងអស់

មានក្រសួងស្ថាប័នប្រមាណ៣០% ដែលមានមជ្ឈមណ្ឌលទិន្នន័យខ្លួនឯង ប៉ុន្តែនិន្នាការបង្កើតមជ្ឈមណ្ឌលទិន្នន័យដោយឡែកសម្រាប់បម្រើការរបស់ក្រសួង ស្ថាប័នរៀងខ្លួននេះកំពុងតែកើតមានឡើង ដែលនឹងបង្កការចំណាយខ្ពស់ទាំងការវិនិយោគ ទាំងការថែទាំដាច់ដោយឡែកពីគ្នា។ ការវិនិយោគលើមជ្ឈមណ្ឌលទិន្នន័យរួមសម្រាប់រដ្ឋាភិបាល នឹងជួយកាត់បន្ថយបន្ទុកដ៏ធំរបស់ក្រសួង ស្ថាប័នទាំងអស់ សម្រាប់ដំណើរការផ្លាស់ប្តូរឌីជីថលនេះ

## V) អង្គភាពបច្ចេកវិទ្យា និងធនធានមនុស្ស

គ្រប់ក្រសួងស្ថាប័នទាំងអស់មានការរៀបចំ និងចាត់តាំងអង្គភាពទទួលបន្ទុកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងមានមន្ត្រីសម្រាប់បម្រើការងារលើមុខសញ្ញានេះ។ ប៉ុន្តែមានក្រសួងស្ថាប័នចំនួន១០ ស្មើនឹង**៤០%** បានរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការទទួលខុសត្រូវទទួលបន្ទុកការងារបច្ចេកវិទ្យាព័ត៌មានបានច្បាស់លាស់។ ក្រសួងស្ថាប័នក្រៅពីនេះ(**៦០%**ទៀត) បានចាត់ចែងអង្គភាពទទួលបន្ទុកបច្ចេកវិទ្យានេះដោយ មិនបានចែងពីការទទួលខុសត្រូវច្បាស់លាស់ និងលាយឡំជាមួយតួនាទីភារកិច្ចដទៃទៀត។

ភាពមិនច្បាស់លាស់ពីតួនាទីភារកិច្ចរបស់អង្គភាពបច្ចេកវិទ្យា នឹងបង្កផលលំបាកដល់ដំណើរការវិវត្តរបស់រដ្ឋាភិបាលឌីជីថល ជាពិសេស នៅពេលដែលការវិវត្តផ្តោតលើការធ្វើសមាហរណកម្មប្រព័ន្ធកម្មវិធីក្នុងចំណុះក្រសួងតែមួយ ការសម្របសម្រួលតភ្ជាប់ប្រព័ន្ធជាលក្ខណៈអន្តរក្រសួង ការផ្តោតលើការប្រមូលផ្តុំទិន្នន័យ និងការធានាបាននូវសន្តិសុខឌីជីថលដើម្បីឈានដល់កម្រិតចុងក្រោយនៃរដ្ឋាភិបាលឌីជីថល។

ក្រៅពីបញ្ហាតួនាទីភារកិច្ចនិងការទទួលខុសត្រូវរបស់អង្គភាពបច្ចេកវិទ្យា ចំនួនធនធានមនុស្សក្នុងវិស័យនេះសម្រាប់ទ្រទ្រង់ដំណើរការផ្លាស់ប្តូរឌីជីថលក្នុងក្រសួងស្ថាប័នមានចំនួនតិច។ ជាក់ស្តែង ក្រសួងស្ថាប័ន១០០% បានលើកឡើងពីកង្វះខាតធនធានមនុស្សខាងផ្នែកបច្ចេកវិទ្យាសម្រាប់បម្រើការងារ ទាំងបរិមាណ ទាំងគុណភាព។ លើសពីនេះ មន្ត្រីទទួលបន្ទុកបច្ចេកទេសមិនដែលទទួលបានការអភិវឌ្ឍជំនាញបច្ចេកវិទ្យាថ្មីៗដែលគាំទ្រពីក្រសួងស្ថាប័នរបស់ខ្លួននោះដែរ។ ភាគច្រើនការចំណាយលើការអភិវឌ្ឍជំនាញបច្ចេកវិទ្យាថ្មីៗ ឬការធ្វើតេស្តសមត្ថភាពដើម្បីទទួលបានវិញ្ញាបនបត្រជំនាញគឺជាបន្ទុករបស់មន្ត្រីខ្លួនឯង។ កង្វះការលើកទឹកចិត្តនិងផែនការអភិវឌ្ឍធនធានមនុស្ស នឹងធ្វើឱ្យដំណើរការផ្លាស់ប្តូរឌីជីថលជួបប្រទះផលលំបាកច្រើន។

ធនធានមនុស្សខាងផ្នែកបច្ចេកវិទ្យានៅតែមានតម្រូវការខ្ពស់នាថ្ងៃអនាគត។ តាមការឆ្លើយតបរបស់អង្គភាពជំនាញ ដើម្បីអាចទ្រទ្រង់ដំណើរការអភិវឌ្ឍ ថែទាំ និងគ្រប់គ្រងប្រព័ន្ធទាំងឡាយក្នុងអំឡុងពេល៣ឆ្នាំនេះ ត្រូវការមន្ត្រីជំនាញខ្ពស់ដែលអាចបំពេញការងារបានប្រមាណ**៧៨៤នាក់**បន្ថែមទៀត។ ជំនាញ ប.គ.ព. ដែលត្រូវការបំផុតនាពេលបច្ចុប្បន្នសម្រាប់បំពេញការងារមាន ផ្នែកបណ្តាញ ផ្នែកអភិវឌ្ឍកម្មវិធី ផ្នែកសន្តិសុខ ផ្នែកវិភាគនិងគ្រប់គ្រងទិន្នន័យ ដោយមិនទាន់មានតម្រូវការលើបច្ចេកវិទ្យាថ្មីៗនៅឡើយទេ។

## VI) ស្ថានភាពនៃការផ្តល់សេវាសាធារណៈ

នៅក្នុងចំណោមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលទាំងអស់ មានក្រសួងស្ថាប័នប្រមាណ១៨ប៉ុណ្ណោះដែលមានសេវាសាធារណៈច្រើនលើសពី២០។ ក្រសួងស្ថាប័នខ្លះមិនមានសេវាសាធារណៈ ហើយក្រសួងខ្លះទៀតមានសេវាប្រមាណ១ឬ២ប៉ុណ្ណោះ។ សេវាសាធារណៈសរុបមានចំនួន៣១៩៦សេវា។

ដោយហេតុថាគោលបំណងមួយនៃឌីជីថលនីយកម្មក្រសួងស្ថាប័ននានា គឺដើម្បីផ្តល់សេវាសាធារណៈបានកាន់តែរហ័សមានប្រសិទ្ធភាព ការសិក្សាពីស្ថានភាពបច្ចុប្បន្ននៃការផ្តល់សេវាគឺជារឿងចាំបាច់។ កន្លងមកក្នុងគោលបំណងដូចគ្នានេះ រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់លើការផ្តល់សេវាតាមការបង្កើតកម្មវិធីជាច្រើន មានដូចជា កម្មវិធីកំណែទម្រង់រដ្ឋបាល៥ឆ្នាំ(២០០៤-២០០៨) កម្មវិធីជាតិកំណែទម្រង់សេវាសាធារណៈ(២០១៥-២០១៨) និងបង្កើតយន្តការអនុវត្តជាច្រើនដូចជា៖

- យន្តការច្រកចេញចូលតែមួយ នៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវារដ្ឋបាល និងការងារនីត្យានុកូលកម្ម។
- ការិយាល័យច្រកចេញចូលតែមួយ(OWSO) ១) កន្លែងផ្តល់សេវាកម្មរដ្ឋបាលនៅតាមក្រុង ស្រុក ខណ្ឌ ២) កន្លែងប្រមូលផ្តុំសេវាកម្មរដ្ឋបាល(ពាណិជ្ជកម្ម វប្បធម៌ ទេសចរណ៍ រៀបចំដែនដី ឧស្សាហកម្ម រ៉ែ និងថាមពល សាធារណការ អប់រំ និងសុខាភិបាល) និងនីតិរដ្ឋបាល ៣) កន្លែងដែលអតិថិជនមកទទួលទម្រង់បែបបទ ព័ត៌មានផ្សេងៗ និងបង់កម្រៃសេវា និង៤) កន្លែងដែលអតិថិជនទទួលផលសម្រេចនៃសេវា។

ថ្វីបើមានការកែទម្រង់ក្នុងគោលបំណងពន្លឿនការផ្តល់សេវាសាធារណៈ យន្តការដែលដាក់ចេញអាចជួយសម្រួល និងកាត់បន្ថយភាពស្មុគស្មាញច្រើនសម្រាប់អ្នកស្នើសុំសេវាក៏ដោយ ការស្នើសុំនិងទទួលសេវានេះនៅធ្វើឡើងដោយជួបមុខផ្ទាល់ និងពឹងផ្អែកលើក្រដាសស្នាម។ ដំណើរការនៃប្រតិបត្តិឯកសារសម្រាប់អ្នកស្នើសុំនៅអនុវត្តតាមលំនាំដើមដដែល។

ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការអនុវត្តមួយកម្រិតទៀត ក្រសួង ស្ថាប័នមួយចំនួនបានផ្លាស់ប្តូររបៀបរបបនៃការផ្តល់សេវារបស់ខ្លួនតាមប្រព័ន្ធអនឡាញដាច់ដោយឡែកពីគ្នា ក្នុងនោះមានដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានពន្ធដារ) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ល។ ភាពដាច់ដោយឡែកពីគ្នានៃប្រព័ន្ធផ្តល់សេវាអនឡាញ នៅជាបញ្ហាស្មុគស្មាញដល់អ្នកស្នើសុំសេវាដែលត្រូវចូលទៅក្នុងគេហទំព័រផ្សេងៗគ្នា និងផ្តល់ព័ត៌មានច្រំដែលក្នុងការបំពេញបែបបទស្នើសុំ។ នេះជាមូលហេតុចម្បងមួយសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្តួចផ្តើមប្រព័ន្ធចុះបញ្ជីអាជីកម្មតាមថ្នាលបច្ចេកវិទ្យា(CamDX) សម្រាប់ភ្ជាប់ទំនាក់ទំនងប្រព័ន្ធផ្តល់សេវាអនឡាញ(ផ្តោតលើការចុះបញ្ជីអាជីវកម្ម) និងផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធដាច់ដោយឡែកពីគ្នានេះ។ តាមរយៈប្រព័ន្ធនេះ ធុរជនអាចចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ចុះបញ្ជីពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ និងធ្វើសេចក្តីប្រកាសផ្តល់ដំណឹងបើកសហគ្រាសជូនទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងពេលតែមួយ **ត្រូវការពេលវេលាយ៉ាងយូរត្រឹម៨ថ្ងៃ នៃថ្ងៃធ្វើការតែប៉ុណ្ណោះ ជាមួយនឹងចំណាយតិចជាងមុនជាងពាក់កណ្តាល**។ យន្តការ CamDX កំពុងពង្រីកដំណើរការរបស់ខ្លួនគ្របដណ្តប់លើសេវាចុះបញ្ជីអាជីវកម្មរបស់ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់។ នេះមានន័យថា សេវាសាធារណៈ(លើការចុះបញ្ជីអាជីវកម្ម) តំណាងឱ្យ៥២%នៃសេវាសាធារណៈទាំងអស់នឹងអាចដាក់ឱ្យដំណើរការក្នុងទម្រង់ជាឌីជីថល។

ថ្វីបើភាពជោគជ័យរបស់ CamDX ជាការបង្ហាញពីការវិវត្តគួរឱ្យកត់សម្គាល់នៃការផ្លាស់ប្តូរឌីជីថលក្នុងជួររាជរដ្ឋាភិបាល និងបង្កភាពងាយស្រួលកម្រិតខ្ពស់ដល់ធុរជន សេវាសាធារណៈសំខាន់ៗដទៃទៀតគួរត្រូវបានកំណត់អាទិភាពក្នុងការធ្វើឌីជីថលនីយកម្ម ជាពិសេសនោះ គឺសេវាសាធារណៈដែលមានតម្រូវការខ្ពស់ មានភាពស្មុគស្មាញ និងមានទំនាក់ទំនងផ្ទាល់ជាមួយប្រជាពលរដ្ឋម្នាក់ដូចបានកំណត់រួចជាស្រេចក្នុងកម្មវិធីជាតិកំណែទម្រង់សេវាសាធារណៈ មានដូចជា សុខាភិបាល អប់រំ ពាណិជ្ជកម្ម សាធារណការនិងដឹកជញ្ជូន ការចុះបញ្ជីដីធ្លី និងសំណង់អគ្រានុកូលដ្ឋាន លិខិតឆ្លងដែន និងអត្តសញ្ញាណបណ្ណ។ ឌីជីថលនីយកម្មសេវាទាំងអស់នេះមិនត្រឹមតែផ្តល់

ទំនុកចិត្ត ភាពងាយស្រួលដល់ប្រជាពលរដ្ឋនោះទេ ទិន្នន័យប្រមូលផ្តុំពីប្រព័ន្ធឌីជីថលលើសេវាទាំងនេះ គឺជាទិន្នន័យមូលដ្ឋាន(ជាទិន្នន័យគោលពាក់ព័ន្ធជាមួយប្រជាពលរដ្ឋ) មានសារៈសំខាន់សម្រាប់ការវិភាគពីបញ្ហាផ្សេងៗ រួមទាំងសង្គម សេដ្ឋកិច្ច ដែលអាចជំនួយដល់ការសម្រេចចិត្ត ការដាក់ចេញគោលនយោបាយ និងការរៀបចំផែនការនិងកម្មវិធីអភិវឌ្ឍចំទិសដៅ។

## VII) ទិសដៅ និងអនុសាសន៍គោលនយោបាយ

-តាមរយៈការសិក្សានេះ ស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជាស្ថិតនៅក្នុងដំណាក់កាលទី១ ដោយរាល់គោលបំណងនៃការប្រើប្រាស់បច្ចេកវិទ្យា គឺធ្វើឡើងដើម្បីសម្រួលដល់ការងារ និងការផ្តល់សេវាសាធារណៈ និងមានគោលដៅជាសំខាន់លើការអភិវឌ្ឍកម្មវិធី។ នៅក្នុងស្ថានភាពបែបនេះ ដើម្បីជំរុញការផ្លាស់ប្តូរឌីជីថលនៅកម្រិតខ្ពស់បន្ថែមទៀត តម្រូវឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត ជាពិសេស ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំបច្ចេកទេស ពីការគិតផ្តោតលើការអភិវឌ្ឍប្រព័ន្ធកម្មវិធី បែរគិតលើសារៈសំខាន់នៃទិន្នន័យ ការប្រមូល និងការប្រើប្រាស់ទិន្នន័យក្នុងជួររាជរដ្ឋាភិបាលសម្រាប់បង្កើតតម្លៃបន្ថែម និងជំរុញនវានុវត្តន៍លើទិន្នន័យប្រមូលផ្តុំទាំងនោះ ដែលការផ្លាស់ប្តូររបៀបនេះនឹងជំរុញឱ្យមានការផ្លាស់ប្តូររបៀបរបប និងរចនាសម្ព័ន្ធការងារនាពេលក្រោយទៀត។ ការផ្លាស់ប្តូរផ្នត់គំនិតនេះអាចធ្វើឡើងបាន តាមរយៈការបង្ហាញឱ្យឃើញជាក់ស្តែង នូវកម្មវិធីនវានុវត្តន៍ដែលបង្កើតឡើងឈរលើមូលដ្ឋានទិន្នន័យ ពីសារៈសំខាន់នៃការតភ្ជាប់ប្រព័ន្ធ និងការប្រើប្រាស់ទិន្នន័យប្រមូលផ្តុំក្នុងគ្រប់កម្រិត និងគ្រប់វិស័យផ្សេងៗ។

- ដើម្បីអាចបង្កើតតម្លៃបន្ថែមដែលជំរុញឱ្យមានការផ្លាស់ប្តូរ និងប្រមូលផ្តុំទិន្នន័យប្រកបដោយទំនុកចិត្ត បទដ្ឋានគតិយុត្តចម្បងដែលត្រូវបង្កើតឡើងជាបន្ទាន់មាន ច្បាប់ការពារទិន្នន័យឯកជនភាព យន្តការចែករំលែកទិន្នន័យក្នុងជួររាជរដ្ឋាភិបាល។ កង្វះខាតច្បាប់ទាំងនេះ នឹងបង្កភាពមិនច្បាស់លាស់លើអភិបាលកិច្ចទិន្នន័យ និងភាពមិនទុកចិត្តគ្នាដែលរាំងស្ទះដល់ដំណើរការចែករំលែកទិន្នន័យតាមក្រសួងស្ថាប័ន។ និយាមមូលដ្ឋានសន្តិសុខឌីជីថលគួរត្រូវបានបង្កើតឡើង និងលើកទឹកចិត្តឱ្យអនុវត្តនៅតាមក្រសួងស្ថាប័ន ចូលរួមលើកកម្ពស់សុវត្ថិភាពបច្ចេកវិទ្យា។

- ការផ្លាស់ប្តូរឌីជីថលទាមទារមានការរៀបចំច្បាស់លាស់ និងចូលរួមពីគ្រប់លំដាប់ថ្នាក់នៃអង្គភាពក្រោមចំណុះក្រសួងស្ថាប័ន និងរវាងអន្តរក្រសួង។ ក្រៅពីការរៀបចំគោលនយោបាយអភិវឌ្ឍរដ្ឋាភិបាលឌីជីថលរួមដើម្បីជំរុញការផ្លាស់ប្តូរឌីជីថលគ្រប់ក្រសួងស្ថាប័ន គួរតម្រូវឱ្យក្រសួងស្ថាប័ននីមួយៗ រៀបចំផែនការផ្លាស់ប្តូរឌីជីថលផ្ទៃក្នុងរបស់ខ្លួនដោយមានសង្គតិភាពជាមួយផែនការរបស់រាជរដ្ឋាភិបាលទាំងមូល។

- ការផ្លាស់ប្តូរឌីជីថលមិនអាចធ្វើបាន ប្រសិនបើអង្គភាពទទួលបន្ទុកបច្ចេកវិទ្យាមានតួនាទីនិងការទទួលខុសត្រូវមិនច្បាស់លាស់។ អាស្រ័យហេតុនេះ អន្តរាគមន៍គោលនយោបាយមួយចាំបាច់ គឺលើកទឹកចិត្តឱ្យមានការបង្កើតអង្គភាពច្បាស់លាស់ មានរួមបញ្ចូលការទទួលខុសត្រូវទាំងការរៀបចំផែនការ ការគ្រប់គ្រងបណ្តាញការអភិវឌ្ឍកម្មវិធី និងការទទួលខុសត្រូវលើផ្នែកសន្តិសុខឌីជីថល។

- បង្កើតយន្តការបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញមន្ត្រីទទួលបន្ទុកជាប្រចាំលើជំនាញចាំបាច់និងថ្មីៗទៅតាមការវិវត្តរបស់បច្ចេកវិទ្យា និងលើកទឹកចិត្តលើការធ្វើតេស្តសមត្ថភាពទទួលបានការបញ្ជាក់ជំនាញឯកទេសដែលមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។ ក្រៅពីជំនាញឯកទេសលើផ្នែកគ្រប់គ្រងបណ្តាញ អភិវឌ្ឍកម្មវិធី សន្តិសុខឌីជីថល ការគ្រប់គ្រងទិន្នន័យ មានជំនាញសំខាន់ៗជាច្រើនដែលគួរគិតគូរពិចារណាក្នុងការបណ្តុះបណ្តាល

មន្ត្រីបច្ចេកទេសទាំងសំដៅជានាប្រសិទ្ធភាពការងារ និងជំរុញការច្នៃប្រឌិត។ ជំនាញទាំងនោះមានដូចជា ការគ្រប់គ្រងគម្រោង Behavioral Science and Design Thinking និងការវិភាគទិន្នន័យ(Data Analytics & Data Science)។ល។

- ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធគាំទ្រ បណ្ដាញ និងមជ្ឈមណ្ឌលទិន្នន័យ គួរជាការវិនិយោគរួមរបស់ រដ្ឋាភិបាល សម្រាប់បម្រើដល់ការផ្លាស់ប្ដូរទាំងមូលរបស់ក្រសួងស្ថាប័នដទៃទៀត។ ការមានហេដ្ឋារចនាសម្ព័ន្ធរួម ចូលរួមកាត់បន្ថយបន្ទុកភាពស្មុគស្មាញក្នុងការគ្រប់គ្រង និងអាចធានាបាននូវសុវត្ថិភាពខ្ពស់។ មជ្ឈមណ្ឌលទិន្នន័យគួរត្រូវបានប្រើប្រាស់សម្រាប់ផ្ទុកទិន្នន័យរដ្ឋាភិបាល និងសេវា Hosting ចាំបាច់ផ្សេងៗដូចជាសេវាសារអេឡិចត្រូនិកជាដើម។ល។

- ពន្លឿនការធ្វើឌីជីថលនីយកម្មសេវាសាធារណៈអាទិភាព ជាពិសេស លើវិស័យសុខាភិបាល អប់រំ ការចុះបញ្ជីដីធ្លី និងសំណង់ អត្រានុកូលដ្ឋាន លិខិតឆ្លងដែន និងអត្តសញ្ញាណបណ្ណ ដើម្បីការគ្រប់គ្រង និងប្រមូលផ្តុំទិន្នន័យមូលដ្ឋានពាក់ព័ន្ធអត្តសញ្ញាណសំខាន់ៗរបស់ប្រជាពលរដ្ឋ និងជាសេវាដែលមានតម្រូវការខ្ពស់បានកាន់តែច្រើន។

- ផ្តល់អាទិភាពលើការបង្កើតប្រព័ន្ធកម្មវិធីដែលអាចប្រើប្រាស់ជារួមបាននៅគ្រប់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលទាំងអស់ដូចជា ប្រព័ន្ធគ្រប់គ្រងមន្ត្រី ប្រព័ន្ធហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងឯកសារ ប្រព័ន្ធស្នើសុំការអនុម័ត (Electronic Approval System)ជាដើម។ល។ ប្រព័ន្ធអាចត្រូវបានអភិវឌ្ឍតែម្តង និងចែករំលែកសម្រាប់ការប្រើប្រាស់ក្នុងជួរក្រសួងស្ថាប័នរាជរដ្ឋាភិបាលទាំងមូល។

- គួរផ្តួចផ្តើមឱ្យមានការបង្កើតថ្នាលឌីជីថលតែមួយសម្រាប់ផ្តល់សេវាសាធារណៈ(បន្ថែមលើការចុះបញ្ជីអាជីវកម្ម) ដែលប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការស្វែងរកនិងស្នើសុំសេវា ហើយដែលសេវាសាធារណៈថ្មីៗអាចត្រូវបានបន្ថែម កែប្រែ និងធ្វើទំនើបកម្មងាយស្រួល។

- ពិនិត្យលើលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ីមែលផ្លូវការរបស់ក្រសួងស្ថាប័ន ជាអត្តសញ្ញាណឌីជីថលសម្រាប់មន្ត្រីរាជការក្នុងការប្រើប្រាស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថល។

- គួរផ្តួចផ្តើមឱ្យមានកម្មវិធី "GovTech Startup" ដែលបើកចំហឱ្យមានការបង្កើតនូវដំណោះស្រាយឌីជីថលមានលក្ខណៈនវានុវត្តន៍សម្រាប់រាជរដ្ឋាភិបាល ហើយអាចពង្រីកការប្រើប្រាស់បាននៅតាមក្រសួងស្ថាប័នផ្សេងៗ ក្នុងគោលបំណងសន្សំសំចៃថវិកា និងធានាប្រសិទ្ធភាពនៃដំណោះស្រាយឌីជីថលទាំងនោះ។

- កំណត់ចក្ខុវិស័យតាមដំណាក់កាលដែលអាចធ្វើទៅបាន និងមានលក្ខណៈជាក់លាក់។ រដ្ឋាភិបាលឆ្លាត (Smart Government) អាចកើតមានឡើងបាន លុះត្រាតែក្រសួងស្ថាប័ន និងអង្គភាពចំណុះទាំងអស់បានបញ្ចប់ឌីជីថលនីយកម្មពេញលេញ។ ប៉ុន្តែតាមការអង្កេតពីស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន កម្ពុជានៅមានបញ្ហាប្រឈមច្រើន ដែលត្រូវដោះស្រាយដើម្បីគាំទ្រដល់ការធ្វើឌីជីថលនីយកម្មដ៏ពេញលេញនៅតាមក្រសួងស្ថាប័នទាំងអស់។ ក្នុងរយៈពេល៥ឆ្នាំខាងមុខ ជាមួយនឹងការខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធបាន រដ្ឋាភិបាលឌីជីថលនៅកម្ពុជា អាចឈានឡើងត្រឹមកម្រិតទី៣ប៉ុណ្ណោះ។

## ប្រព័ន្ធព័ត៌មានឌីជីថលក្រសួងស្ថាប័ន

| លេខរៀង | ក្រសួងស្ថាប័ន | បរិមាណ | ប្រព័ន្ធព័ត៌មានឌីជីថល | មុខងារសំខាន់ៗ |
|---|---|---|---|---|
| ១ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) | ៣ | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (Human Resource Management Information System – HRMIS) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| | | | កម្មវិធីទូរសព្ទដៃសម្រាប់ទីផ្សារកសិកម្មកម្ពុជា (Cambodia Agriculture Market Application) | ការធ្វើពាណិជ្ជកម្មផលិតផលកសិកម្ម |
| | | | ប្រព័ន្ធត្រួតពិនិត្យនិងរក្សាទុកទិន្នន័យកសិកម្ម (Agricultural Data Monitoring and Retention System - AgriSys) | ការគ្រប់គ្រងព័ត៌មានផលិតផលកសិកម្ម និងការសម្របសម្រួលតម្លៃ |
| ២ | ក្រសួងមុខងារសាធារណៈ (MCS) | ១០ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ (Civil Servant Data Management System) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់មន្ត្រីរាជការស៊ីវិលនៅក្នុងបណ្ណសារ (Information Management System for Civil Servants in the Archives) | ការគ្រប់គ្រងកំណត់ត្រាមន្ត្រីរាជការ |
| | | | ប្រព័ន្ធគ្រប់គ្រងការចូលនិវត្តន៍ (Retirement Management System) | ការគ្រប់គ្រងការចូលនិវត្តន៍ |
| | | | ប្រព័ន្ធគ្រប់គ្រងបន្ទប់និងកិច្ចប្រជុំ (Room and Meeting Management System) | ការគ្រប់គ្រងបន្ទប់និងការប្រជុំ |
| | | | ប្រព័ន្ធគ្រប់គ្រងលំហូរឯកសារ (File Flow Management System) | ប្រព័ន្ធតាមដានលំហូរឯកសារ (ទិន្នន័យ របាយការណ៍ និងស្ថិតិ) |
| | | | ប្រព័ន្ធគ្រប់គ្រងកិច្ចសន្យាសម្រាប់មន្ត្រីកិច្ចសន្យានិងគ្រូ | ការគ្រប់គ្រងព័ត៌មានកិច្ចសន្យា |

| | | | | |
|---|---|---|---|---|
| | | | (Contract Management System for Contract Officers and Teachers) | |
| | | | ប្រព័ន្ធគ្រប់គ្រងឯកសារព័ត៌មានមន្ត្រីរាជការ (Civil Servant Information Sheet Management System) | ការគ្រប់គ្រងឯកសារព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធគ្រប់គ្រងការថែមម៉ោងធ្វើការ (Overtime Management System) | ការគ្រប់គ្រងការថែមម៉ោងធ្វើការ |
| | | | ប្រព័ន្ធព័ត៌មានមន្ត្រីរាជការ (Civil Servant Information System) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធទូទាត់ប្រាក់ខែ (Salary Payment System) | ការគ្រប់គ្រងការទូទាត់ប្រាក់ខែ |
| ៣ | ក្រសួងពាណិជ្ជកម្ម (MOC) | ៧ | ប្រព័ន្ធម៉ុសក្លោដ (Moc Cloud) | ការគ្រប់គ្រងដោយប្រើប្រាស់បច្ចេកវិទ្យាក្លោដ |
| | | | ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម (Business Registration System) | ការចុះឈ្មោះធុរកិច្ច |
| | | | ប្រព័ន្ធព័ត៌មានម៉ុស (MoC News) | ព័ត៌មាននៃក្រសួង |
| | | | ប្រព័ន្ធគ្រប់គ្រងច្រកចេញចូលតែមួយ (National Single Window - ATIGA) | ការគ្រប់គ្រងច្រកចេញចូលតែមួយចម្រុះ |
| | | | ប្រព័ន្ធឯកសារអេឡិចត្រូនិក (e-Filing) | ការគ្រប់គ្រងឯកសារអេឡិចត្រូនិក |
| | | | ប្រព័ន្ធស្វែងរកម៉ាកពាណិជ្ជកម្ម (Trade Mark Search) | ការត្រួតពិនិត្យពាណិជ្ជនាម |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ (Civil Servant Information Management System) | ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| ៤ | ក្រសួងធម្មការនិងសាសនា (MOCAR) | 0 | អត់មាន | - |

| | | | | |
|---|---|---|---|---|
| ៥ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (MCFA) | ១ | ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HR Management System) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| ៦ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) | ១៣ | ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management Information System) | ការគ្រប់គ្រងថវិកាជាតិ |
| | | | ថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (Cambodia Data eXchange Platform - CamDX) | ការផ្លាស់ប្ដូរទិន្នន័យរវាងក្រសួង |
| | | | ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម (Business Registration System) | ការចុះឈ្មោះធុរកិច្ច |
| | | | ប្រព័ន្ធគ្រប់គ្រងឯកសារ (Document Management System) | ការគ្រប់គ្រងឯកសារ |
| | | | ប្រព័ន្ធគ្រប់គ្រងវត្តមានការិយាល័យរបស់ក្រសួង (Ministry Office Presence Management System) | ការគ្រប់គ្រងវត្តមាន |
| | | | ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋសម្រាប់កិច្ចការផ្ទៃក្នុង និងក្រសួងដទៃទៀត (Management System for State Property for Internal Affairs and Other Ministries) | ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ស្ថាប័នរដ្ឋាភិបាល (ក្រសួងផ្សេងៗ) |
| | | | ប្រព័ន្ធសំណួរ & ឆ្លើយតប (Q&A System) | សំណួរនិងចម្លើយនានា |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ (Personnel Management System Ministry Office) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (Customs Data Automation System - ASYCUDA) | ការទូទាត់គយតាមអេឡិចត្រូនិក |
| | | | ប្រព័ន្ធគយអេឡិចត្រូនិក (Electronic Customs System) | គយអេឡិចត្រូនិក |

| | | | | |
|---|---|---|---|---|
| | | | ប្រព័ន្ធគ្រប់គ្រងបុគ្គលិក ( Personnel Management System ) | ការគ្រប់គ្រងមន្ត្រីរាជការ |
| | | | ប្រព័ន្ធគ្រប់គ្រងវត្តមានបុគ្គលិក ( Attendance Management System ) | ការគ្រប់គ្រងវត្តមានបុគ្គលិក |
| | | | ប្រព័ន្ធចុះបញ្ជីពន្ធ ( Tax Registration System ) | ការចុះឈ្មោះពន្ធដារ |
| ៧ | ក្រសួងអប់រំ យុវជន និងកីឡា ( MOEYS ) | ៧ | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ( Educational Information Management System - EMIS ) | ការគ្រប់គ្រងព័ត៌មានអប់រំ |
| | | | កម្មវិធីគ្រប់គ្រងបុគ្គលិក ( Personnel Management Software ) | ការគ្រប់គ្រងធនធានមនុស្ស |
| | | | ប្រព័ន្ធចែកចាយសៀវភៅសិក្សាសាលារៀន ( Textbook Distribution System ) | ស្ថានភាពចែកចាយសៀវភៅតាមសាលានីមួយៗ |
| | | | ប្រព័ន្ធគ្រប់គ្រងអាហារូបករណ៍ ( Scholarship Management System ) | ការគ្រប់គ្រងព័ត៌មានអាហារូបករណ៍ ( ទិន្នន័យ របាយការណ៍ ការគ្រប់គ្រប់ស្ថិតិ ) |
| | | | ប្រព័ន្ធតាមដានព័ត៌មាននិស្សិត - ប្រព័ន្ធតាមដានសាលា ( Student Information Tracking System ) | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសិស្ស ( ទិន្នន័យ របាយការណ៍ ការគ្រប់គ្រប់ស្ថិតិ ) |
| | | | ប្រព័ន្ធគ្រប់គ្រងសាលារៀន ( School Management System ) | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសាលា ( ទិន្នន័យ របាយការណ៍ ការគ្រប់គ្រប់ស្ថិតិ ) |
| | | | ប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ ( Library Management System - Koha ) | ប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ |
| ៨ | ក្រសួងបរិស្ថាន ( MOE ) | ១ | ប្រព័ន្ធស្នើសុំនាំចូលគ្រឿងបរិក្ខារទូទឹកកកនិងសារធាតុបំផ្លាញ ( Application for Import of Refrigeration Equipment and Ozone Depleting Substances ) | ការគ្រប់គ្រងលើការអនុញ្ញាតនាំចូលឧបករណ៍ត្រជាក់កក និងសារធាតុបំផ្លាញស្រទាប់អូហ្សូន |

| | | | | |
|---|---|---|---|---|
| ៩ | ក្រសួងការបរទេស និង សហប្រតិបត្តិការ អន្តរជាតិ (MFAIC) | ៩ | បណ្ណាល័យឌីជីថលឬប្រព័ន្ធឯកសារ អេឡិចត្រូនិក (Digital Library or e-Document System) | បណ្ណាល័យឌីជីថល និងឯកសារអេឡិចត្រូនិកនានា |
| | | | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (Human Resources Management Information System) | ការបញ្ចូល និងការស្វែករកព័ត៌មានមន្ត្រីរាជការ |
| | | | ការគ្រប់គ្រងនៃពេលវេលាប្រជុំ (Meeting Utility - Sign Board) | ការបញ្ជាក់ព័ត៌មាននៃពេលវេលាប្រជុំ និងបន្ទប់ |
| | | | កម្មវិធីគ្រប់គ្រងសម្រាប់គ្រប់សម្ភារធនធានព័ត៌មាន (Management Software for IT Resources) | ការគ្រប់គ្រងធនធានឧបករណ៍ |
| | | | ប្រព័ន្ធគ្រប់គ្រងវត្តមានរបស់និយោជិក (Employee Attendance Management System) | ការគ្រប់គ្រងម៉ោងចូលនិងចេញធ្វើការរបស់មន្ត្រីរាជការ |
| | | | កម្មវិធីពិនិត្យការចូលនិងចេញរបស់បុគ្គលិកនៅអគារក្រសួង (Entry and Exit of Staff at the Ministry Building) | ការគ្រប់គ្រងកំណត់ត្រាចូលនៃមន្ត្រីរាជការ |
| | | | កម្មវិធីត្រួតពិនិត្យការចូលនិងចេញយានយន្តនិងម៉ូតូតូចនៅអាគារក្រសួង (Entry and Exit of Vehicle and Small Motorcycles at the Ministry Building) | ការគ្រប់គ្រងកំណត់ត្រានៃយានយន្ត |
| | | | ប្រព័ន្ធស្នើសុំទិដ្ឋាការសម្រាប់ជនបរទេសតាមរយៈការចុះឈ្មោះតាមអនឡាញ (Visa Application for Foreigners through Online Registration) | ការផ្តល់សេវាកម្មe-Visa តាមអនឡាញដល់ជនបរទេស |

| | | | | |
|---|---|---|---|---|
| | | | ប្រព័ន្ធស្នើសុំលិខិតឆ្លងដែនការទូត - ផ្លូវការតាមរយៈការចុះឈ្មោះតាមអនឡាញ ( Diplomatic Passport Application Program – Official via Online Registration ) | ការផ្តល់សេវា e-Passport តាមអនឡាញ |
| ១០ | ក្រសួងសុខាភិបាល ( MOH ) | ១៣ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានជំងឺគ្រុនចាញ់ ( Malaria Information Management System ) | ការគ្រប់គ្រងតំបន់ផ្ទុះជំងឺគ្រុនចាញ់ និងព័ត៌មានអ្នកជំងឺ ( ទិន្នន័យ របាយការណ៍ ការគ្រប់គ្រងស្ថិតិ ) |
| | | | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សសុខាភិបាល ( Management System of Human Resource for Health ) | ការគ្រប់គ្រង ប្រវត្តិរូប ប្រវត្តិការងារ ការផ្លាស់ប្តូរកន្លែងធ្វើការ ការដំឡើងតួនាទី ការចូលនិវត្តន៍ វគ្គបណ្តុះបណ្តាលមូលដ្ឋាន និងបណ្តុះបណ្តាលបន្តដល់មន្ត្រីរាជការ ( ការគ្រប់គ្រងចំណេះដឹងរបស់មន្ត្រីរាជការ ) |
| | | | ប្រព័ន្ធអេឡិចត្រូនិកកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ ( Patient Management and Registration System - PMRS ) | ការកត់ត្រា និងគ្រប់គ្រងនូវទិន្នន័យអ្នកជំងឺ ករណីប្រើប្រាស់សេវា តាមដាន ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងទូទាត់ការរាល់ចំណាយសេវាមូលនិធិសមធម៌សុខាភិបាល |
| | | | ប្រព័ន្ធចុះទិដ្ឋាការ-បញ្ជិកាឱសថ ឧបករណ៍បរិក្ខារពេទ្យ គ្រឹះស្ថានផលិតឱសថ និងចុះប្រវេទន៍គ្រឿងសំអាងតាមអនឡាញ ( Cambodia Pharmaceutical Online Registration System - CamPORS ) | ការគ្រប់គ្រងការចុះទិដ្ឋាការ-បញ្ជិកាឱសថ ឧបករណ៍បរិក្ខារពេទ្យ គ្រឹះស្ថានផលិតឱសថ និងចុះប្រវេទន៍គ្រឿងសំអាងតាមអ៊ីនធឺណិត ( ទិន្នន័យ របាយការណ៍ ការគ្រប់គ្រងស្ថិតិ ) |
| | | | ប្រព័ន្ធព័ត៌មានគ្រប់គ្រងឱសថ បរិក្ខារពេទ្យ និងការដឹកជញ្ជូន ( Logistic Management Information System – LMIS ) | ការគ្រប់គ្រងស្តុកនិងផ្គត់ផ្គង់ |

| | | | | |
|---|---|---|---|---|
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាសុខាភិបាលតាមគេហទំព័រ (Health Management Information System - HMIS) | ការកត់ត្រានិងផ្តល់ព័ត៌មានស្តីពីសកម្មភាពសេវាសុខាភិបាល និងបញ្ហាសុខភាពដែលឆ្លុះបញ្ចាំងនៅគ្រប់កម្រិតនៃមូលដ្ឋានសុខាភិបាលនៅក្នុងប្រព័ន្ធថែទាំសុខាភិបាលជាតិ |
| | | | ប្រព័ន្ធព័ត៌មានមន្ទីរពិសោធន៍កម្ពុជា (Cambodia Laboratory Information System - CamLIS) | ការគ្រប់គ្រងប្រព័ន្ធទិន្នន័យនៃលទ្ធផល និងស្តង់ដាលទ្ធផលក្នុងការធ្វើតេស្ត (តេស្តមន្ទីរពិសោធន៍ទូទៅ និង មីក្រូប៊ីយ៉ូឡូស៊ី) ក្នុងការវិភាគ និងបណ្តុះមេរោគ រួមទាំងការតាមដាន ការរាលត្បាត និងការធ្វើរោគវិនិច្ឆ័យដែលមានសារៈសំខាន់ចំពោះសុខភាពសាធារណៈ |
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ម្ចាស់ជំនួយ (Donor Data Management System) | ការគ្រប់គ្រងទីតាំងម្ចាស់ជំនួយ និងឈ្មោះផ្សេងៗ(ទិន្នន័យ របាយការណ៍ ការគ្រប់គ្រងស្ថិតិ) |
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧបករណ៍ពេទ្យវេជ្ជសាស្ត្រ (Medical Equipment Information Management System –Inventory) | ការគ្រប់គ្រងឧបករណ៍ពេទ្យ |
| | | | ប្រព័ន្ធ District Health Information Software- version 2 - DHIS2) | ការគ្រប់គ្រងទិន្នន័យកម្មវិធីបង្ការ ថែទាំ និង ព្យាបាលជំងឺអេដស៍ |
| | | | ប្រព័ន្ធព័ត៏មានគ្រប់គ្រងជំងឺរបេង (TB Management Information System - TBMIS) | ការគ្រប់គ្រង និងផ្តល់ព័ត៌មានស្តីពី ករណីជំងឺរបេងដែលបានស្រាវជ្រាវ និងព្យាបាល នៅគ្រប់កំរិត នៃមូលដ្ឋានសុខាភិបាល |
| | | | ប្រព័ន្ធព័ត៌មានយន្តការជាតិសម្រាប់តាមដានការបង្កើនគុណភាពសេវាសុខាភិបាល (Information Communication and Technology System for | ការគ្រប់គ្រងប្រព័ន្ធទិន្នន័យនៃលទ្ធផលលើការលើកកម្ពស់គុណភាពសេវាសុខាភិបាលនៅថ្នាក់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ការិយាល័យស្រុកប្រតិបត្តិ |

| | | | | |
|---|---|---|---|---|
| | | | National Quality Enhancement and Monitoring Program - NQEMP ICT System ) | មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព នៅទូទាំងព្រះរាជាណាចក្រកម្ពុជា តាមរយៈការវាយតម្លៃគុណភាពសេវាសុខាភិបាល |
| | | | ប្រព័ន្ធរបាយការណ៍សូន្យ ( Zero Reporting System ) | ការរាយការណ៍ករណីជំងឺឆ្លងអាទិភាពចំនួន ៧ រៀងរាល់សប្តាហ៍ ពីបណ្តាមណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែក និងមន្ទីរពេទ្យខេត្តទូទាំងប្រទេស |
| ១១ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនាវានុវត្តន៍ ( MISTI ) | ៥ | ប្រព័ន្ធអនុម័តតាមអនឡាញផ្ទៃក្នុង ( Internal Online Approval System ) | ការគ្រប់គ្រងការទទួលនិងផ្ញើឯកសារ និងការតាមដានលំហូរឯកសារ ( ទិន្នន័យ របាយការណ៍ ការគ្រប់គ្រងស្ថិតិ ) |
| | | | ប្រព័ន្ធគ្រប់គ្រងការចុះឈ្មោះសហគ្រាសខ្នាតតូចនិងមធ្យម ( SME Registration Management System ) | ការគ្រប់គ្រងការចុះបញ្ជីឈ្មោះតាមអ៊ីនធឺណិត នៃសហគ្រាសខ្នាតតូចនិងមធ្យម |
| | | | ប្រព័ន្ធគ្រប់គ្រងអាជីវកម្ម ( Business Management System ) | ការគ្រប់គ្រងការស្នើសុំគណនេយ្យ ស្តុក ការទូទាត់ប្រាក់ខែ កម្លាំងពលកម្ម ( ការគ្រប់គ្រងទិន្នន័យ របាយការណ៍ស្ថិតិ ) |
| | | | កម្មវិធីបោះពុម្ពវិក្កយបត្រទឹកចល័ត ( Mobile Water Billing Printing Program ) | ការបោះពុម្ពវិក្កយបត្រទឹកចល័ត ( ការគ្រប់គ្រងទិន្នន័យ របាយការណ៍ស្ថិតិ ) |
| | | | ប្រព័ន្ធត្រួតពិនិត្យការផ្គត់ផ្គង់ទឹក ( Water Supply Monitor System - WSMS ) | ការកត់ត្រាព័ត៌មាននៃប្រព័ន្ធផ្តល់សេវាផ្គត់ផ្គង់ទឹក ( ការគ្រប់គ្រងទិន្នន័យ របាយការណ៍ស្ថិតិ ) |
| ១២ | ក្រសួងព័ត៌មាន ( MINFO ) | ១ | ប្រព័ន្ធគ្រប់គ្រងអ្នកកាសែត ( Journalist Management System ) | ការគ្រប់គ្រងអ្នកយកព័ត៌មាន |

| | | | | |
|---|---|---|---|---|
| ១៣ | ក្រសួងមហាផ្ទៃ ( MOI ) | ២៨ | ប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល ( Administrative Document Management System - DMS ) | ការគ្រប់គ្រងឯកសារ |
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីពន្ធនាគារ ( Prison Officer Data Management System ) | ការគ្រប់គ្រងព័ត៌មានរបស់នគរបាលនៅពន្ធនាគារ |
| | | | ប្រព័ន្ធគ្រប់គ្រងនិងកំណត់ត្រាកិច្ចការ ( Task record and Management System ) | ការគ្រប់គ្រងកំណត់ត្រាកិច្ចការ |
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់មន្ត្រីរាជការស៊ីវិល ( Data Management System for Civil Servants ) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធគ្រប់គ្រងផលិតកម្មនិងលិខិតឆ្លងដែន ( Passport Production and Management System ) | ការគ្រប់គ្រងលិខិតឆ្លងដែន |
| | | | ប្រព័ន្ធផលិតនិងគ្រប់គ្រងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ( Khmer Nationality Identity Card Production and Management System ) | ការបោះពុម្ពនិងគ្រប់គ្រងអត្តសញ្ញាណបណ្ណ |
| | | | ប្រព័ន្ធច្បាប់និងស្រាវជ្រាវច្បាប់ ( Legal and Lagal Research System ) | កម្រងច្បាប់និងការស្រាវជ្រាវច្បាប់ |
| | | | ប្រព័ន្ធគ្រប់គ្រងនិស្សិត ( Student Management System ) | ការគ្រប់គ្រងសិស្ស |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានព្រហ្មទណ្ឌ ( Criminal Information Management System ) | ការគ្រប់គ្រងព័ត៌មានព្រហ្មទណ្ឌ |
| | | | ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណអង្គរក្ស ( Bodyguard Identity Management System ) | ការគ្រប់គ្រងអត្តសញ្ញាណអង្គរក្ស |
| | | | ប្រព័ន្ធគ្រប់គ្រងបណ្ណសារ | ការគ្រប់គ្រងបណ្ណសារ |

| | | | | |
|---|---|---|---|---|
| | | | ( Archive Management System ) | |
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧក្រិដ្ឋកម្មគ្រឿងញៀន ( Drug Crimes Data Management System ) | ការគ្រប់គ្រងទិន្នន័យឧក្រិដ្ឋកម្មគ្រឿងញៀន |
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យចរាចរណ៍យានយន្តល្មើស ( Traffic Violation Vehicle Data Management System ) | ការគ្រប់គ្រងយានយន្តបំពានចរាចរណ៍ |
| | | | ប្រព័ន្ធចុះបញ្ជីនិងគ្រប់គ្រងអាវុធ ( Weapons Registration and Management System ) | ការចុះបញ្ជីនិងការគ្រប់គ្រងអាវុធ |
| | | | ប្រព័ន្ធគ្រប់គ្រងបណ្ណព្រំដែនកម្ពុជា ( Cambodia Border Pass Management System ) | ការគ្រប់គ្រងបណ្ណព្រំដែនកម្ពុជា |
| | | | ប្រព័ន្ធគ្រប់គ្រងការអនុវត្តគម្រោងរដ្ឋបាលថ្នាក់ក្រោមជាតិ ( Sub-National Administration Project Implementation Management System ) | ការគ្រប់គ្រងការអនុវត្តគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ |
| | | | កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងនិងផ្តល់សេវានៅក្នុងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ ( One Window Service Office for Service Delivery Management Information System – Municipality, District, Khan ) | ការគ្រប់គ្រងនិងផ្តល់សេវានៅក្នុងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ OWSOSDMIS |
| | | | កម្មវិធីព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងនិងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត ( One Window Service Office for Service Delivery Management Information System – Capital and Pronice ) | ការគ្រប់គ្រងនិងផ្តល់សេវានៅក្នុងអង្គភាពច្រកចេញចូលតែមួយរាជធានីខេត្ត OWSUSDMIS |

| | | | | |
|---|---|---|---|---|
| | | | ប្រព័ន្ធគ្រប់គ្រងព្រំដែនកម្ពុជា (Cambodia Border Management System - CBMS) | ការគ្រប់គ្រងព័ត៌មានព្រំដែន |
| | | | ប្រព័ន្ធទិដ្ឋាការមកដល់ (Arrival Visa System) | ការផ្តល់ទិដ្ឋាការមកដល់ |
| | | | ប្រព័ន្ធគ្រប់គ្រងគោលដៅ (Target Management System) | ការគ្រប់គ្រងគោលដៅ |
| | | | ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពអ្នកដំណើរ (Passenger Safety System) | ការគ្រប់គ្រងសុវត្ថិភាពអ្នកដំណើរ |
| | | | ប្រព័ន្ធពន្យាទិដ្ឋាការ (Visa Extension System) | ការពន្យារសុពលភាពទិដ្ឋាការ |
| | | | ប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស (Foreigner Presence Management System - FPCS) | ការគ្រប់គ្រងការស្នាក់នៅជនបរទេស |
| | | | ប្រព័ន្ធព័ត៌មានក្រសួងមហាផ្ទៃ (Ministry of Interior Information System – MOI Mobile App) | ការផ្តល់ព័ត៌មាន |
| | | | កម្មវិធីសេវាកម្មកំណត់អត្តសញ្ញាណ (Identification Services Program - e-Service App) | ព័ត៌មានណែនាំអំពីការចេញអត្តសញ្ញាណបណ្ណ |
| | | | ប្រព័ន្ធស្វែងរកព័ត៌មានអត្តសញ្ញាណ (Identity Information Search System) | ការស្វែងរកព័ត៌មានអត្តសញ្ញាណ |
| | | | ប្រព័ន្ធដាក់ពាក្យសុំទិដ្ឋាការតាមអនឡាញ (Online Visa Application System) | ការស្នើសុំទិដ្ឋាការអនឡាញ |
| ១៤ | ក្រសួងយុត្តិធម៌ (MOJ) | ៣ | ប្រព័ន្ធគ្រប់គ្រងលិខិតវិនិច្ឆ័យ - របាយការណ៍គ្រប់គ្រងព្រហ្មទណ្ឌ (Judgement Letter Management System – Criminal Management Report) | ការគ្រប់គ្រងការស្នើសុំលិខិតថ្កោលទោស |
| | | | ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ (Civil Servant Management System) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការនៃក្រសួងយុត្តិធម៌ |

| | | | | |
|---|---|---|---|---|
| | | | កម្មវិធីគ្រប់គ្រងរដ្ឋបាល ( Administrative Management Software ) | ការគ្រប់គ្រងឯកសារអេឡិចត្រូនិក ( e-Document ) |
| ១៥ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ( MLVT ) | ១១ | ប្រព័ន្ធគ្រប់គ្រងកណ្តាលរបស់ពលករបរទេស ( Foreign Worker Centralized Management System - FWCMS ) | ការគ្រប់គ្រងពលករបរទេស |
| | | | សេវាកម្មការងារសាធារណៈនៅកម្ពុជា ( Cambodia Public Empolyment Service - CPES ) | ការស្វែងរកការងារនិងការផ្តល់ព័ត៌មានជ្រើសរើសបុគ្គលិក |
| | | | ប្រព័ន្ធគ្រប់គ្រងប្រាក់ខែ ( Salary Management System ) | ការគ្រប់គ្រងប្រាក់ខែ |
| | | | ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ( Civil Servants Management System ) | ព័ត៌មានមន្ត្រីរាជការ និងការគ្រប់គ្រងចូលនិវត្តន៍ |
| | | | ប្រព័ន្ធបេឡាជាតិរបបសន្តិសុខសង្គម ( National Social Security Fund System ) | ការគ្រប់គ្រងព័ត៌មាននៃមូលនិធិសន្តិសុខសង្គមជាតិ ( ការគ្រប់គ្រងទិន្នន័យ របាយការណ៍ ស្ថិតិ ) |
| | | | ការបណ្តុះបណ្តាលបុគ្គលិកនិងក្រុមប្រឹក្សាបញ្ជូនទៅក្រៅប្រទេស ( Manpower Training and Overseas Sending Board - MTSOB ) | ការគ្រប់គ្រងព័ត៌មានរបស់កម្មករដែលគ្រោងនឹងត្រឡប់មកពីប្រទេសកូរ៉េ |
| | | | ប្រព័ន្ធចេញកាតសម្រាប់កម្មករ - កាតពលករនៅក្រៅប្រទេសកម្ពុជា ( Card Issuance System for Workers – Oversea Cambodia Worker Card ) | ប្រព័ន្ធចេញកាតកម្មករ ( ការគ្រប់គ្រងទិន្នន័យ របាយការណ៍ ស្ថិតិ ) |
| | | | ប្រព័ន្ធព្យួរកិច្ចសន្យា ( Contract Suspension System ) | ការបញ្ឈប់កិច្ចសន្យាការងារកម្មករ |
| | | | ប្រព័ន្ធរបាយការណ៍ផ្ទៃក្នុងរបស់ក្រសួង - ប្រព័ន្ធរាយការណ៍ឌីជីថល ( Ministry Internal Reporting | ការគ្រប់គ្រងការបញ្ចូលរបាយការណ៍ការងាររបស់អង្គភាពផ្សេងៗ |

| | | | | |
|---|---|---|---|---|
| | | | System – Digital Reporting System ) | |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ( Technical Vocational Education and Training Management Information System – TVETMIS ) | ការគ្រប់គ្រងស្ថិតិថ្នាក់ដឹកនាំ បុគ្គលិកសិក្សា មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត របស់គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ |
| | | | ប្រព័ន្ធជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ពីចម្ងាយ ឬតាមអនឡាញ ( បញ្ជាក់៖ ប្រព័ន្ធជាតិនេះបានអភិវឌ្ឍចាប់ផ្ដើមខែតុលា ឆ្នាំ២០២០ និងកំពុងដាក់ប្រើប្រាស់សាកល្បង ) ( National Technical Vocational Education and Training E-Learning Platform – TVET E-Learning ) | ការគាំទ្រដល់ការបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញ របស់សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ |
| ១៦ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ( MLMUPC ) | ៩ | ប្រព័ន្ធគ្រប់គ្រងដីធ្លី ( Land Management System ) | ការគ្រប់គ្រងដីធ្លី |
| | | | ប្រព័ន្ធចេញកម្មសិទ្ធិអចលនវត្ថុ ( Real Estate Ownership Printing System ) | ការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុ |
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ ២.០ ( Civil Servant Data Management System 2.0 ) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យឌីជីថលសំណង់ ( Construction Digital Data Management System ) | ការគ្រប់គ្រងទិន្នន័យសំណង់ |
| | | | ប្រព័ន្ធតាមដានឯកសារសំណង់ ( Construction Document Tracking System ) | ការគ្រប់គ្រងតាមដានឯកសារសាងសង់ |

| | | | | |
|---|---|---|---|---|
| | | | ប្រព័ន្ធគ្រប់គ្រងការស្នើសុំសេវាកម្មសាធារណៈ (Public service request management system) | ការគ្រប់គ្រងស្នើសុំសេវាសាធារណៈ |
| | | | ប្រព័ន្ធសេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក (e- Casastral Information Service Providing System) | ការផ្តល់ព័ត៌មានអចលនវត្ថុអេឡិចត្រូនិក |
| | | | កម្មវិធីព័ត៌មានសំណង់កម្ពុជា (Cambodia Construction Information Program - App Cambodia Construction) | ការផ្តល់ព័ត៌មានសាងសង់នៅកម្ពុជា |
| | | | ប្រព័ន្ធចុះបញ្ជីក្រុមហ៊ុនសាងសង់អេឡិចត្រូនិក (E-Construction Business Registration System) | ការចុះបញ្ជីក្រុមហ៊ុនសាងសង់អេឡិចត្រូនិក |
| ១៧ | ក្រសួងរ៉ែ និងថាមពល (MME) | ៤ | ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ (Civil Servants Management System) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធតាមដានឯកសារក្នុងនិងក្រៅ (Inbound and Outbound File Tracking System) | ការគ្រប់គ្រងការទទួលនិងការបញ្ជូនឯកសារអេឡិចត្រូនិក |
| | | | ប្រព័ន្ធគ្រប់គ្រងគណនេយ្យ (Accounting Management System) | ការគ្រប់គ្រងគណនេយ្យ |
| | | | ប្រព័ន្ធវាស់កាំរស្មីបរិយាកាស (Atmospheric Radiation Measurement System) | ការកត់ត្រាព័ត៌មានអំពីបរិស្ថាន (ការវាស់វិទ្យុសកម្មបរិយាកាស) (ការគ្រប់គ្រងទិន្នន័យ របាយការណ៍ ស្ថិតិ) |
| ១៨ | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា -ព្រឹទ្ធសភា | ៤ | ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ | ការគ្រប់គ្រងមន្ត្រីរាជការផ្ទៃក្នុងក្រសួង |
| | | | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |

| | | | | |
|---|---|---|---|---|
| | និងអធិការកិច្ច (MONASRI) | | ប្រព័ន្ធគ្រប់គ្រង់លិខិតបទដ្ឋានគតិយុត្តតាមគេហទំព័រ (e-Library) | ការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត |
| | | | ប្រព័ន្ធការទទួលពាក្យបណ្ដឹងតាមអនឡាញ | ការទទួលពាក្យបណ្ដឹងតាម អនឡាញ |
| ១៩ | ក្រសួងការពារជាតិ (MOD) | ២ | ប្រព័ន្ធគ្រប់គ្រងឯកសារ (File Management System) | ការគ្រប់គ្រងឯកសារអេឡិចត្រូនិក |
| | | | ការគ្រប់គ្រងទិន្នន័យបុគ្គលិក (Personnel Database Management) | ការគ្រប់គ្រងព័ត៌មានបុគ្គលិក |
| ២០ | ក្រសួងផែនការ (MOP) | ៤ | ប្រព័ន្ធដំណើរការទិន្នន័យសម្រាប់ការស្ទង់មតិនិងជំរឿន (Data Processing System for Surveying and Census - CSPro) | ការស្រាវជ្រាវ និងជំរឿនដើម្បីប្រព័ន្ធរៀបចំទិន្នន័យ |
| | | | ការគ្រប់គ្រងឯកសារទិន្នន័យនិងប្រព័ន្ធវិភាគស្ថិតិ (Data File Management and Statistical Analysis System - Stata & SPSS) | ការគ្រប់គ្រងឯកសារព័ត៌មាននិងវិភាគស្ថិតិ |
| | | | ប្រព័ន្ធប្រមូលទិន្នន័យអេឡិចត្រូនិក (Electronic Data Collection System - Survey Solution) | ការប្រមូលទិន្នន័យ |
| | | | ប្រព័ន្ធគ្រប់គ្រងទិន្នន័យមេតា (Metadata Management System - NADA) | ការគ្រប់គ្រងទិន្នន័យមេតា (Metadata) |
| ២១ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (MPTC) | ៤ | ប្រព័ន្ធគ្រប់គ្រងអ៊ីមែល (Email Management System) | ការប្រើប្រាស់អ៊ីមែល |
| | | | ប្រព័ន្ធគ្រប់គ្រងសារពើភណ្ឌ (Inventory Management System) | ការគ្រប់គ្រងឧបករណ៍សម្ភារៈ |
| | | | ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនិងប្រព័ន្ធបើកប្រាក់ខែ (HR Management and Payroll System) | ការគ្រប់គ្រងបុគ្គលិក |

| | | | ប្រព័ន្ធគ្រប់គ្រងមាតិកាសម្រាប់ស្ថាប័នសាធារណៈ (Content Management Platform for Public Institutions) | ការគ្រប់គ្រងមាតិកាសម្រាប់ស្ថាប័នសាធារណៈ |
|---|---|---|---|---|
| ២២ | ក្រសួងសាធារណការនិងដឹកជញ្ជូន (MPWT) | ២០ | ប្រព័ន្ធនិងកម្មវិធីព័ត៌មាននិងដឹកជញ្ជូនសាធារណៈ (Public Information and Transportation Information Systems and Programs) | កម្មវិធីព័ត៌មានសាធារណការនិងដឹកជញ្ជូន |
| | | | ប្រព័ន្ធចុះបញ្ជីយានយន្តនិងប្រព័ន្ធបណ្ណបើកបរ (Vehicle Registration and Driver's License System) | ការគ្រប់គ្រងការចុះបញ្ជីយានយន្ត និងផ្តល់បណ្ណបើកបរយានយន្ត |
| | | | វេបសាយក្រសួង (Ministry Website) | គេហទំព័រក្រសួង |
| | | | ប្រព័ន្ធគ្រប់គ្រងលំហូរឯកសាររដ្ឋបាល (Administrative File Flow Management System) | ការគ្រប់គ្រងការទទួលនិងបញ្ជូនឯកសារផ្លូវការ |
| | | | ប្រព័ន្ធគ្រប់គ្រងវត្តមានរបស់មន្ត្រីរាជការស៊ីវិល (Civil Servant Attendance Management System) | ការគ្រប់គ្រងមន្ត្រីរាជការ ដោយកំណត់លាភការដល់មន្ត្រីរាជការឬការគ្រប់គ្រងវត្តមាននិងអវត្តមានដោយប្រើការស្គាល់ស្នាមម្រាមដៃ |
| | | | ប្រព័ន្ធគ្រប់គ្រងរបាយការណ៍រួម (Joint Report Management System) | ការគ្រប់គ្រងរបាយការណ៍ និងការត្រួតពិនិត្យ |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្លូវ (Road Information Management System) | ការគ្រប់គ្រងព័ត៌មានផ្លូវ |
| | | | ប្រព័ន្ធបំពេញបន្ថែមសម្រាប់ការផ្តល់សេវាដឹកជញ្ជូនតាមផ្លូវ (Complementary System for Providing Road Transport Services) | ការផ្តល់សេវាដឹកជញ្ជូនផ្លូវគោក |

| | | | | |
|---|---|---|---|---|
| | | | ប្រព័ន្ធផ្តល់សិទ្ធិដល់កប៉ាល់នៃព្រះរាជាណាចក្រកម្ពុជា ( Ship Authorization System of the Kingdom of Cambodia ) | ការផ្តល់លិខិតអនុញ្ញាតឱ្យនាវាចូល ( អន្តោប្រវេសន៍ ) |
| | | | ប្រព័ន្ធអនុម័តច្រកផែចេញចូលរបស់កប៉ាល់ ( អន្តោប្រវេសន៍ ) | ការគ្រប់គ្រងការចូលរបស់នាវានៅតាមកំពង់ផែនៅកម្ពុជា ដើម្បីរក្សាសន្តិសុខ និងរួមចំណែកការពារបរិស្ថាន |
| | | | ប្រព័ន្ធតេស្តបើកបរទ្រឹស្តី ( Theoretical Driving Test System ) | ការប្រឡងទ្រឹស្តីនៃការបើកបរយានយន្ត |
| | | | ប្រព័ន្ធទូទាត់ ( Payment System ) | ការទូទាត់តាមរយៈធនាគារដែលមានសម្ព័ន្ធភាព |
| | | | ប្រព័ន្ធពាក្យសុំចុះបញ្ជីយានយន្ត ( Vehicle Registration Application System ) | ការដាក់ពាក្យស្នើសុំ និងលក់ដេញថ្លៃលេខចុះបញ្ជីយានយន្ត |
| | | | កម្មវិធីយល់ដឹងអំពីការបើកបរ ( Driving Theory Awareness Program ) | ការយល់ដឹងអំពីទ្រឹស្តីនៃការបើកបរលើទូរសព្ទដៃ |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានយានយន្ត ( Vehicle Information Checker ) | ការត្រួតពិនិត្យព័ត៌មានអំពីយានយន្ត |
| | | | ប្រព័ន្ធចែករំលែកទិន្នន័យដឹកជញ្ជូនតាមផ្លូវគោក ( Road Trandport Data Sharing System ) | ការចែករំលែកព័ត៌មានជាមួយស្ថាប័នខាងក្រៅ |
| | | | ប្រព័ន្ធគ្រប់គ្រងកាលវិភាគប្រជុំ ( Meeting Schedule Management System ) | ការគ្រប់គ្រងពេលវេលាប្រជុំរបស់ក្រសួង |
| | | | ប្រព័ន្ធនិងកម្មវិធីថែទាំផ្លូវ ( Road Maintenance System and Program ) | របាយការណ៍ស្ថានភាពផ្លូវ និងសម្រេចការថែទាំ |
| | | | ប្រព័ន្ធពាក្យសុំអាជីវកម្មដឹកជញ្ជូនតាមផ្លូវគោក ( Road Transport Business Application System ) | ការគ្រប់គ្រងនិងដាក់ពាក្យស្នើសុំផ្តល់លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មដឹកជញ្ជូន |

| | | | | |
|---|---|---|---|---|
| | | | ប្រព័ន្ធពាក្យសុំធ្វើអធិការកិច្ចបច្ចេកទេសយានយន្ត (Vehicle Technical Inspection Application System) | ការគ្រប់គ្រងនិងដាក់ពាក្យស្នើសុំត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត |
| | | | ប្រព័ន្ធដាក់ពាក្យស្នើសុំបណ្ណបើកបរ (Driving License Application System) | ការដាក់ពាក្យស្នើសុំផ្តល់បណ្ណបើកបរយានយន្ត |
| ២៣ | ក្រសួងអភិវឌ្ឍន៍ជនបទ (MORD) | ២ | ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ (HR Management Database) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធគ្រប់គ្រងផ្លូវជនបទ (Rural Road Management System) | ការគ្រប់គ្រងព័ត៌មានផ្លូវជនបទ |
| ២៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSVY) | ៨ | ប្រព័ន្ធគ្រប់គ្រងបុគ្គលិក (Personnel Management System) | ការបញ្ចូលនិងការស្វែងរកព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (Child Protection Management Information System) | ការគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារទូទាំងប្រទេស |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានកន្លែងថែទាំកុមារ (Residential Care Facilities Digital Inspection System) | ការគ្រប់គ្រងព័ត៌មានកន្លែងថែទាំកុមារទូទាំងប្រទេស |
| | | | ប្រព័ន្ធគ្រប់គ្រងករណីព្រីមេរ៉ូ (Primero) | ការគ្រប់គ្រងករណីកុមាររងគ្រោះ និងងាយរងគ្រោះទូទាំងប្រទេស |
| | | | ប្រព័ន្ធគ្រប់គ្រងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារក្រោម២ឆ្នាំ (Program Management System for Cash Transfer for Pregnant Women and Children under 02 years old | ការគ្រប់គ្រងព័ត៌មានស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម០២ឆ្នាំ ក្នុងគ្រួសារក្រីក្រទូទាំងប្រទេស |

| | | | | |
|---|---|---|---|---|
| | | | ប្រព័ន្ធព័ត៌មាននិវត្តជន ( Retired Information Database ) | ការគ្រប់គ្រងព័ត៌មានអតីតមន្ត្រីរាជការ និងគ្រួសារទូទាំងប្រទេស |
| | | | ប្រព័ន្ធព័ត៌មានអតីតយុទ្ធជនជាតិ ( Veteran Information Database ) | ការគ្រប់គ្រងអតីតយុទ្ធជន និងគ្រួសារទូទាំងប្រទេស |
| | | | ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព ( Disabilities Management Information System ) | ការគ្រប់គ្រងព័ត៌មានជនមានពិការភាពទូទាំងប្រទេស |
| ២៥ | ក្រសួងទេសចរណ៍ ( MOT ) | ២ | ប្រព័ន្ធគ្រប់គ្រងសម្រាប់ការបណ្តុះបណ្តាលនិងការគ្រប់គ្រងជំនាញក្នុងវិស័យទេសចរណ៍ ( Management System for Training and Management of Skills in Tourism ) | ការគ្រប់គ្រងសម្រាប់ការបណ្តុះបណ្តាលនិងជំនាញទេសចរណ៍ |
| | | | ប្រព័ន្ធអាជ្ញាបណ្ណធ្វើដំណើរ តាមអនឡាញ ( Online Travel License System ) | ការផ្តល់អាជ្ញាបណ្ណអនឡាញ |
| ២៦ | ក្រសួងធនធានទឹកនិងឧតុនិយម ( MOWRAM ) | ១ | ប្រព័ន្ធគ្រប់គ្រងអាកាសធាតុនិងប្រព័ន្ធធារាសាស្ត្រ ( Meteorological and Irrigation Management System ( Xconnect Meteorology and Climatology ) ) | ការគ្រប់គ្រងអាកាសធាតុនិងប្រព័ន្ធធារាសាស្ត្រ |
| ២៧ | ក្រសួងកិច្ចការនារី ( MOWA ) | ២ | ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ ( Civil Servant Information Management System ) | ការគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ |
| | | | ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ ( Financial management Information System FMIS ) | ការគ្រប់គ្រងចំណាយជាតិឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងការប្រមូលចំណូលឱ្យកាន់តែប្រសើរឡើង |

| | | | | |
|---|---|---|---|---|
| ២៨ | ទីស្តីការគណៈរដ្ឋមន្ត្រី ( OCM ) | ៤ | ប្រព័ន្ធត្រួតពិនិត្យព័ត៌មានគ្រោះមហន្តរាយ ( Disaster Information and Monitoring System ) | ការត្រួតពិនិត្យព័ត៌មានគ្រោះមហន្តរាយ |
| | | | ប្រព័ន្ធគ្រប់គ្រងឯកសារច្បាប់ ( Legal Document Management System ) | ការគ្រប់គ្រងឯកសារច្បាប់ |
| | | | ប្រព័ន្ធគ្រប់គ្រងការប្រជុំ ( E-Meeting ) | ការគ្រប់គ្រងការប្រជុំ |
| | | | ប្រព័ន្ធគ្រប់គ្រងឯកសារអេឡិចត្រូនិក ( Electronic Document Management System ) | ការគ្រប់គ្រងឯកសារអេឡិចត្រូនិក |
| ២៩ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC ) | ៤ | QIP Online Application | |
| | | | Master List Online Application | |
| | | | Supplier database with sustainability Dimensions ( SD2 ) | |
| | | | CRDB's ODA Database | |
| **សរុប** | | **ចំនួន១៨២** | | |

# ឧបសម្ព័ន្ធ៣ សទ្ទានុក្រម

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ១ | Carbon Emission Reductions | កាត់បន្ថយផលប៉ះពាល់បរិស្ថាន | ការកាត់បន្ថយការសាយភាយនៃឧស្ម័នកាបូនទៅក្នុងបរិយាកាស ដោយប្រើប្រាស់វិធីផ្សេងៗដូចជាកាត់បន្ថយការប្រើប្រាស់ចរន្តអគ្គិសនី ឬយានយន្តជាដើម ឬជំនួសដោយការប្រើធនធានធម្មជាតិដែលមិនប៉ះពាល់ដល់បរិស្ថាន |
| ២ | Chat | ឆែត | ការជជែកគ្នាជាលក្ខណៈមិត្តភាពឬមិនផ្លូវការ |
| ៣ | Cloud Technology | បច្ចេកវិទ្យាក្លោដ | បច្ចេកវិទ្យានៃហេដ្ឋារចនាសម្ព័ន្ធ ដែលផ្តល់សេវាកម្មផ្ទុកទិន្នន័យនិងធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ព័ត៌មាន តាមប្រព័ន្ធអ៊ីនធឺណិត |
| ៤ | Data-centric Government | រដ្ឋាភិបាលផ្តោតលើទិន្នន័យ | រដ្ឋាភិបាលក្នុងយុគ្គសម័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយបានប្រមូលយកទិន្នន័យដែលបានរក្សាទុកមកធ្វើការវិភាគនិងផលិតចេញជាចំណេះដឹងជាជំនួយសម្រាប់ការសម្រេចចិត្ត |
| ៥ | Digitalization | ឌីជីថលនីយកម្ម ឬឌីជីថលល្អូបនីយកម្ម | ដំណើរការនៃការកែសម្រួលអភិបាលកិច្ច ឬធុរកិច្ច ឬដំណើរការសកម្មភាពអ្វីមួយឲ្យមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល |
| ៦ | Enterprise Architecture | និម្មាបនកម្មសហគ្រាស | វិន័យដែលនាំឲ្យសហគ្រាសឆ្លើយតបទៅនឹង ការប្រែប្រួលដោយធ្វើការកំណត់និងវិភាគលើប្រតិបត្តិការបច្ចុប្បន្ននិងលើការកែសម្រួល ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងលទ្ធផលរំពឹងទុករបស់សហគ្រាស |
| ៧ | Fully Digital Government | រដ្ឋាភិបាលឌីជីថលពេញលេញ | ក្រសួងស្ថាប័នក្នុងជួររដ្ឋាភិបាលទាំងអស់ផ្តោតសារៈសំខាន់លើទិន្នន័យ ដើម្បីអភិវឌ្ឍប្រព័ន្ធឌីជីថលនវានុវត្តន៍សម្រាប់ការងារ ការគ្រប់គ្រង និងការផ្តល់សេវានានាបានប្រសើរជាងមុន ដោយទាញយកនិងផ្អែកលើទិន្នន័យប្រមូលផ្តុំ |
| ៨ | Government as a Platform | រដ្ឋាភិបាលដំណើរការលើថ្នាលឌីជីថល | ប្រព័ន្ធអេកូឡូស៊ីនៃហេដ្ឋារចនាសម្ព័ន្ធរួម (ប្រព័ន្ធឌីជីថលចែករំលែក, API, ស្តង់ដា និងមូលដ្ឋានទិន្នន័យរួម) ដែលមានសេវាកម្មដូចជា ការអភិវឌ្ឍប្រតិបត្តិការ ការគ្រប់គ្រងលើហេដ្ឋារចនាសម្ព័ន្ធរួមខាងលើ ក្នុងគោលបំណងផ្តល់នូវសេវាសាធារណៈកាន់តែប្រសើរកាន់តែរហ័សនិងមានប្រសិទ្ធភាព |

| | | | |
|---|---|---|---|
| ៩ | GovTech | បច្ចេកវិទ្យារដ្ឋាភិបាល | បច្ចេកវិទ្យាថ្មីៗដែលអាចជ្រើសរើសយកមកប្រើប្រាស់នៅក្នុងមជ្ឈដ្ឋានរដ្ឋាភិបាលសំដៅលើកកម្ពស់ ការផ្តល់សេវាសាធារណៈ |
| ១០ | Interoperability | អន្តរប្រតិបត្តិការ | សមត្ថភាពនៃប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលអាចធ្វើសន្ធានកម្មជាមួយគ្នាក្នុងការផ្លាស់ប្តូរ និងការប្រើប្រាស់ទិន្នន័យដែលជាទូទៅកើតឡើងដោយស្វ័យប្រវត្តិក្រោមលក្ខខណ្ឌច្បាស់លាស់ |
| ១១ | Interoperability as an Ecosystem Principle | គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ | គោលការណ៍នេះធានាថាគ្រប់ប្រព័ន្ធព័ត៌មានឌីជីថលទាំងអស់ក្នុងក្របខណ្ឌរដ្ឋាភិបាលអាចមានប្រតិបត្តិការឯករាជ្យ ប៉ុន្តែអាចធ្វើប្រតិបត្តិការជាមួយគ្នាបានប្រកបដោយសុវត្ថិភាពជាមួយប្រព័ន្ធដទៃទៀត ក្នុងលក្ខណៈជាប្រព័ន្ធប្រព័ន្ធអេកូឡូស៊ីមួយ ដើម្បីបំពេញមុខងារឱ្យគ្នាទៅវិញទៅមក ក្នុងការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព |
| ១២ | Land and Expand for Efficiency Principle | គោលការណ៍ផ្តើមនិងពង្រីកដើម្បីប្រសិទ្ធភាព | គោលការណ៍នៃការចាប់ផ្តើមអ្វីមួយពីទ្រង់ទ្រាយតូចជាមុនសិន មុននឹងពង្រីកទៅជាខ្នាតធំ នាំឲ្យការចំណាយលើការអនុវត្តការងារ និងលទ្ធផលទទួលបានប្រកបដោយប្រសិទ្ធភាព |
| ១៣ | Last Miles Delivery | ការចែកបញ្ជើគោលដៅចុងក្រោយ | សេវាចែកបញ្ជើពីកន្លែងផ្គត់ផ្គង់ទំនិញទៅកាន់គោលដៅចុងក្រោយរបស់អតិថិជនបានយ៉ាងឆាប់រហ័ស |
| ១៤ | Once Only Principle | គោលការណ៍តែមួយលើក | ជាគោលការណ៍ដែលច្រើនប្រើនៅក្នុងឌីជីថលនីយកម្មសេវាសាធារណៈ ដែលអ្នកទទួលសេវាតម្រូវឲ្យផ្តល់ទិន្នន័យរបស់ខ្លួនតែម្តងគត់ ចំណែកទិន្នន័យដែលទទួលបាននឹងត្រូវបានចែករំលែក និងប្រើប្រាស់ឡើងវិញជាលក្ខណៈផ្ទៃក្នុងនៅក្នុងរង្វង់ក្រសួងស្ថាប័នរដ្ឋាភិបាល ឬឆ្លងប្រទេស ដោយគោរពតាមបទប្បញ្ញត្តិនៃការការពារទិន្នន័យឬបទដ្ឋានគតិយុត្តពាក់ព័ន្ធ |
| ១៥ | Open Government | រដ្ឋាភិបាលបើកចំហ | គំរូអភិបាលកិច្ចដែលឈរលើគោលការណ៍តម្លាភាពផ្តល់នូវទំនុកចិត្តជូនប្រជាពលរដ្ឋ និងមានការចូលរួមពីប្រជាពលរដ្ឋនៅក្នុងការសម្រេចចិត្តនានាដូចជា ការអនុម័តគោលនយោបាយ ឬការអនុវត្តគម្រោងអ្វីមួយស្របតាមតម្រូវការរបស់ប្រជាជន |
| ១៦ | Public Value | គុណតម្លៃសាធារណៈ | គុណតម្លៃដែលបង្កើតឡើងដោយរដ្ឋាភិបាលតាមរយៈការផ្តល់សេវាសាធារណៈ ការបង្កើតនិងអនុវត្តច្បាប់បទបញ្ញានិងសកម្មភាពផ្សេងទៀត ស្របតាមតម្រូវការរបស់ប្រជាជន |

| | | | |
|---|---|---|---|
| ១៧ | Reusability | ធនធានដែលមានស្រាប់ ដែលអាចប្រើឡើងវិញបាន | លទ្ធភាពនៃការប្រើប្រាស់ធនធានដែលមានឡើងវិញ ដូចជា ផ្នែកខ្លះនៃកូដ ឬសម្ភារៈប្រើប្រាស់ជាដើម |
| ១៨ | Smart Citizen | ប្រជាជនឆ្លាត | បុគ្គលដែលមានចំណេះដឹងអំពីបច្ចេកវិទ្យាឌីជីថល និងអាចទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាដើម្បី ចូលរួមនៅក្នុងបរិស្ថានទីក្រុងឆ្លាត ចូលរួមដោះស្រាយបញ្ហាក៏ដូចជាចូលរួមនៅក្នុងការសម្រេចចិត្តនានា |
| ១៩ | Smart Devices | ឧបករណ៍ឆ្លាត | ឧបករណ៍អេឡិចត្រូនិកដែលអាចធ្វើការគណនា ដោយស្វ័យប្រវត្តិនិងភ្ជាប់ទៅឧបករណ៍ផ្សេងទៀត ដោយប្រើខ្សែឬឥតខ្សែសម្រាប់ការផ្លាស់ប្តូរទិន្នន័យ |
| ២០ | Smart Government | រដ្ឋាភិបាលឆ្លាត | រដ្ឋាភិបាលដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បី បង្កើនសមត្ថភាពប្រតិបត្តិការរដ្ឋាភិបាលតាមរយៈការ ចែករំលែកព័ត៌មានជាមួយនឹងសាធារណជននិងកែ លម្អគុណភាពសេវាសាធារណៈ ព្រមទាំងសុខុមាលភាពសង្គម |
| ២១ | Web Portal | វិបផតថល | វិបសាយដែលត្រូវបានរចនាឡើងយ៉ាងពិសេស ជាមាត់ច្រកនៃការផ្តល់ និងទទួលបានព័ត៌មានច្រើនប្រភេទ។ ជាទូទៅ វិបផតថលមានមុខងារស្វែងរក ជូនដំណឹងនិងសមាហរណកម្មព័ត៌មាន ជាដើម |

# គោលនយោបាយ
# រដ្ឋាភិបាលឌីជីថលកម្ពុជា
# ២០២១-២០៣៥

ខែ វិច្ឆិកា ឆ្នាំ ២០២១